**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economies

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការឃុំខ្លួនបណ្ដោះអាសន្ន ក្នុងដំណាក់កាលស៊ើបសួរ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះលោក **សូត្រ សុវណ្ណ៉ាក់**

ណែនាំដោយ

**បណ្ឌិត អ៊ឹង រដ្ឋា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំបញ្ចប់សិក្សា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economies

Royal University of Law and Economics


**សារណាបញ្ចប់ការសិក្សា**

# ការឃុំខ្លួនបណ្តោះអាសន្ន ក្នុងដំណាក់កាលស៊ើបសួរ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះលោក **សូត្រ សុខណ្ណ៉ាក់**

ណែនាំដោយ

**បណ្ឌិត អ៊ឹង រដ្ឋា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំបញ្ចប់សិក្សា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **សូត្រ សុវណ្ណរ៉ាក់** និស្សិតថ្នាក់ L4C6 ជានិស្សិតមកពីមហាវិទ្យាល័យ **នីតិសាស្ត្រ** ជំនាន់ទី២៤ ក្នុងឆ្នាំសិក្សា២០២៣-២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណនូវការដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

- លោកឪពុក និងអ្នកម្តាយទាំងពីរដែលលោកបានផ្តត់ផ្គង់គាំទ្រលើការសិក្សារបស់កូនទាំងពីរក្នុងរយៈពេល៤ឆ្នាំមកនេះដោយលោកបានអប់រំ ទូន្មាន ប្រៀនប្រដៅ ជំរុញលើកទឹកចិត្តដល់កូន ទាំងលោកឪពុក និងអ្នកម្តាយបានពុះពារនៅក្នុងការរកប្រាក់ដើម្បីជួយទំនុកបម្រុងការសិក្សារៀនសូត្ររបស់កូនដោយពុំខ្លាចនឿយហត់ មិនខ្លាចការលំបាកឡើយ។
- ឯកឧត្តម **បណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការ និងសាកលវិទ្យាធិការង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរងនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ដោយទទួលខុសត្រូវយ៉ាងខ្ពង់ខ្ពស់លើការសិក្សារបស់និស្សិត និងជំរុញការសិក្សាដោយពុំខ្លាចនឿយហត់ពុំខ្លាចភាពលំបាកថែមទាំងអប់រំទូន្មានដល់និស្សិតគ្រប់រូបឱ្យខិតខំសិក្សារៀនសូត្រ ហើយការសិក្សាស្រាវជ្រាវនេះដែរគឺដើម្បីជាស្ពានក្នុងការពង្រឹងសមត្ថភាពចំណេះដឹងរបស់និស្សិត។
- ជាពិសេសខ្ញុំបាទ សូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅដល់លោកសាស្ត្រាចារ្យ **បណ្ឌិត អ៊ឹង រដ្ឋា** ដែលបានព្យាយាមពន្យល់ណែនាំបង្ហាត់បង្ហាញញអស់ពីកម្លាំងកាយចិត្ត ជួយតម្រង់ទិស និងកែតម្រូវនូវរាល់កំហុសឆ្គង ចំណុចខ្វះខាតជាច្រើន និងលើកទឹកចិត្តដល់ក្រុមនាងខ្ញុំក្នុងការចងក្រងនូវស្នាដៃមួយនេះអាចបង្កើតឡើងបានចេញជារូបរាង។

ជាចុងបញ្ចប់នាងខ្ញុំទាំងពីរនាក់ សូមប្រសិទ្ធពរជ័យសិរីបវរជូនដល់លោកអ្នកមានគុណ ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ និងអ្នកសិក្សាស្រាវជ្រាវទាំងអស់ សូមឱ្យជោគជ័យគ្រប់ភារកិច្ចការងារ ជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចជាសាកលវិទ្យាល័យមួយដែលបានផ្តល់នូវចំណេះដឹងប្រកបដោយគុណភាព សេចក្តីថ្លៃថ្នូរ សមត្ថភាព និងជាជម្រកដ៏សែនកក់ក្តៅដល់ខ្ញុំបាទក្នុងការសិក្សាថ្នាក់បរិញ្ញបត្រ **នីតិសាស្ត្រ** អស់រយៈពេលបួនឆ្នាំកន្លងមកនេះ។

ខ្ញុំបាទឈ្មោះ **សូត្រ សុវណ្ណារ៉ាក់** ជានិស្សិតថ្នាក់ L4C6 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២៤ ក្នុងឆ្នាំសិក្សា ២០២៣-២០២៤។ ខ្ញុំបាទពិតជាមានសេចក្តីសោមនស្ស និងរីករាយយ៉ាងក្រៃលែងដែលទទួលបានឱកាសក្នុងការសរសេរសារណាដើម្បីបញ្ចប់ការសិក្សានៅឆ្នាំទី៤នេះ។ ការជ្រើសរើសយកប្រធានបទនេះមកធ្វើការស្រាវជ្រាវ ពុំមែនជារឿងចៃដន្យនោះទេប៉ុន្តែជាការពិចារណាយ៉ាងហ្មត់ចត់តាមរយៈការសិក្សាលើអត្ថបទច្បាប់ដែលពាក់ព័ន្ធ គឺដោយសារតែយល់ឃើញថាការឃុំខ្លួនបណ្តោះអាសន្ន ក្នុងដំណាក់កាលស៊ើបសួរ គឺដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ ចាប់តាំងពីដំណើរការស៊ើបសួររហូតដល់ការបិទស៊ើបសួរ។

ខ្ញុំបាទសង្ឃឹមថាការស្រាវជ្រាវលើប្រធានបទមួយនេះ អាចជាឯកសារមួយចំណែកក្នុងជំនួយស្មារតីដល់មិត្តនិស្សិតទទួលបានចំណេះដឹងបន្ថែមក្នុងការសិក្សាស្រាវជ្រាវទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្នក្នុងដំណាក់កាលស៊ើបសួរ និងជាគន្លឹះខ្លះដល់មិត្តនិស្សិតយកទៅស្វែងយល់បន្ត។

ចំពោះប្រធានបទខាងលើនាងខ្ញុំជឿជាក់ថានៅមានចំណុចមួយចំនួននៅមានការខ្វះចន្លោះ និងមានកំហុសខុសឆ្គង ឬមានខុសនៅអក្ខរាវិរុទ្ធមួយចំនួនដោយអចេតនាជាក់ជាពុំខានឡើយ។ ហេតុដូចនេះហើយខ្ញុំបាទសូមទទួលនូវការរិះគន់គ្រប់ចំណុចក្នុងន័យស្ថាបនាពីសំណាក់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់គ្នា។

ជាចុងបញ្ចប់ខ្ញុំបាទសូមសំដែងនូវការគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅក្រៃលែងចំពោះលោកឯកឧត្តម លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់ដែលចំណាយពេលវេលាដ៏មានតម្លៃដើម្បីធ្វើការអាន និងស្វែងយល់លើឯកសារមួយនេះ។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........................................................................................ ១


## ជំពូកទី១
## ការសិក្សាលើលិខិតតុបករណ៍ និង ទ្រឹស្តីគតិយុត្តដែលពាក់ព័ន្ធទៅនឹងការឃុំខ្លួនបណ្តោះអាសន្នក្នុងដំណាក់កាលស៊ើបសួរ


**១.១ គោលការណ៍នានាទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន** ..................... ៤

១.១.១ គោលការណ៍សច្ចាធារនៃនិរទោស ......................................................៤

១.១.២ គោលការណ៍សេរីភាពរបស់បុគ្គល.......................................................៦

**១.២. មូលដ្ឋានគតិយុត្តនៃការឃុំខ្លួនបណ្តោះអាសន្ន** ...................................... ៨

១.២.១ លក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន ..............................................៨

១.២.១.១. លក្ខខណ្ឌទាក់ទងនឹងបទល្មើស.............................................៨

១.២.១.២ លក្ខខណ្ឌនៃទោសដែលត្រូវដាក់ពន្ធនាគារ.................................៩

១.២.១.៣ លក្ខខណ្ឌទាក់ទងនឹងអាយុរបស់ជនត្រូវចោទ.............................. ១០

១.២.២ មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ............................................ ១១

១.២.២.១ មូលហេតុទូទៅនៃការឃុំខ្លួនបណ្តោះអាសន្ន ............................ ១១

១.២.២.២ មូលហេតុផ្សេងទៀតនៃការឃុំខ្លួនបណ្តោះអាសន្ន ........................១២

១.២.៣. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ............................................ ១៤

១.២.៣.១. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះនីតិជន..................... ១៥

១.២.៣.២. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជន .....................១៧

**១.៣. នីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន**.................................................១៩

១.៣.១. ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យ.................................. ១៩

១.៣.២. កិច្ចពិភាក្សាដេញដោលចំពោះការឃុំខ្លួនបណ្តោះអាសន្ន ....................................................២០
១.៣.២.១ ការផ្តើមគំនិតក្នុងការសម្រេចឃុំខ្លួនបណ្តោះអាសន្ន....................................................២១
១.៣.២.២ នីតិវិធីមុនការសម្រេច និងបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ..........................................២៤
១.៣.៣ ការតាក់តែងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន .............................................................. ២៧
១.៣.៣.១ ដើមដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន...........................................................................២៨
១.៣.៣.២ ស្ថានភាពអង្គហេតុ និងអង្គច្បាប់.....................................................................................២៩
១.៣.៣.៣ សំអាងហេតុសម្រេចឃុំខ្លួនបណ្តោះអាសន្ន .......................................................................២៩
១.៣.៣.៤ ការសម្រេចឃុំខ្លួនបណ្តោះអាសន្ន......................................................................................២៩
១.៣.៤ ការបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ................................................................................... ៣២
១.៣.៤.១ ដីកាបង្គាប់ឱ្យឃុំខ្លួន ......................................................................................................... ៣២
១.៣.៤.២ សិទ្ធិរបស់ជនត្រូវចោទដែលមានក្នុងដំណាក់កាលឃុំខ្លួនបណ្តោះអាសន្ន...................៣៤

## ជំពូកទី២

## ការអនុវត្តជាក់ស្តែង និង ការប្រៀបធៀបជាមួយនឹងទ្រឹស្តីគតិយុត្ត

**២.១ ការអនុវត្តជាក់ស្តែង** .......................................................................................... ៣៩
២.១.១ ការដាក់ឱ្យស្ថិតក្រោមការពិនិត្យ.......................................................................................៣៩
២.១.២ កិច្ចពិភាក្សាដេញដោលចំពោះការឃុំខ្លួនបណ្តោះអាសន្ន................................................... ៤០
២.១.៣ ការសម្រេចឃុំខ្លួនបណ្តោះអាសន្ន ...................................................................................... ៤០
២.១.៤ ការបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន .......................................................................................៤២
**២.២ ការវិភាគប្រៀបធៀបជាមួយនឹងទ្រឹស្តីគតិយុត្ត**.................................................... ៤៣
២.២.១ ចំណុចដែលតុលាការអនុវត្តបានពេញលេញ ......................................................................៤៣
២.២.១.១ ការដាក់ឱ្យស្ថិតក្រោមការពិនិត្យ ........................................................................................៤៣
២.២.១.២ ការសម្រេចឃុំខ្លួនបណ្តោះអាសន្ន ...................................................................................... ៤៤

២.២.១.៣ ការបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ........................................................ ៤៤
២.២.២ ចំណុចដែលតុលាការអនុវត្តមិនបានពេញលេញ ........................................................ ៤៥
**សេចក្តីសន្និដ្ឋាន** ........................................................ ៤៧
**អនុសាសន៍** ........................................................ ៤៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសង្គមនីតិរដ្ឋ ការគោរពច្បាប់ គឺជាសកម្មភាពមួយដែលចាំបាច់បំផុតរបស់បុគ្គលម្នាក់ៗដែលជាសមាជិកក្នុងសង្គមនៃរដ្ឋនោះ។ កាលណាដែលបុគ្គលណាម្នាក់បានប្រព្រឹត្តអំពើណាមួយដែលត្រូវបានច្បាប់កំណត់ថាជាបទល្មើសព្រហ្មទណ្ឌ បុគ្គលនោះត្រូវទទួលខុសត្រូវនូវអំពើដែលខ្លួនបានប្រព្រឹត្តនោះនៅចំពោះមុខច្បាប់។ ដើម្បីកំណត់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌរបស់បុគ្គលណាម្នាក់ ចៅក្រមត្រូវតែគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ តាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ កាលណាពុំមានវិធានដោយឡែកចែងដោយច្បាប់ពិសេសទេនោះ។

ជាគោលការណ៍គតិយុត្ត គេអាចដកហូតសិទ្ធិសេរីភាពរបស់បុគ្គលណាម្នាក់បាន លុះត្រាតែបុគ្គលនោះត្រូវបានតុលាការសម្រេចផ្តន្ទាទោសដោយសាលក្រមស្ថាពរ។ យ៉ាងណាមិញ នៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏ដូចជារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់យកគោលការណ៍សេរីភាពបុគ្គល និងគោលការណ៍សន្មតជាមុនថាគ្មានទោសក្នុងការដំណើរការរឿងក្តីព្រហ្មទណ្ឌ។ តាមរយៈគោលការណ៍នេះ បុគ្គលម្នាក់នឹងត្រូវសន្មតថាគ្មានទោស និងត្រូវមានសេរីភាពពេញលេញ បើទោះបីជាបុគ្គលនោះត្រូវបានចោទប្រកាន់ពីបទល្មើសណាមួយក៏ដោយ ហើយបុគ្គលនោះត្រូវបានគេដកហូតសិទ្ធិសេរីភាពបាន លុះត្រាតែមានសាលក្រមស្ថាពរដែលប្រកាសពីពិរុទ្ធភាពរបស់បុគ្គលនោះ។ តែទោះបី ជាយ៉ាងណាក៏ដោយ ប្រសិនបើមានលក្ខខណ្ឌក៏ដូចជាមានមូលហេតុដែលច្បាប់បានកំណត់ទុកជាមុននោះ មិនថាច្បាប់ជាតិឬច្បាប់អន្តរជាតិនោះទេ គឺបានផ្តល់អំណាចយ៉ាងខ្លាំងទៅដល់ចៅក្រមស៊ើបសួរក្នុងការដកហូតសិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ បើទោះបីជាបុគ្គលនោះមិនទាន់ត្រូវបានតុលាការរកឃើញពីពិរុទ្ធភាព និងប្រកាសទោសចំពោះបុគ្គលនោះនៅឡើយក៏ដោយ។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

ដោយហេតុថាក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្តល់សិទ្ធិអំណាចផ្តាច់មុខដល់ចៅក្រមស៊ើបសួរអាចធ្វើការឃុំខ្លួនបុគ្គលណាម្នាក់នៅក្នុងដំណាក់កាលនៃការស៊ើបសួរ ហេតុនេះហើយក្នុងនាមជាចៅក្រមស៊ើបសួរម្នាក់ចាំបាច់ត្រូវតែស្វែងយល់ឱ្យបានច្បាស់លាស់អំពីបទបញ្ញត្តិនានាទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ននេះ ដើម្បីជៀសវាងការឃុំខ្លួនបណ្តោះអាសន្នបុគ្គលណាម្នាក់ដោយពុំមានភាពត្រឹមត្រូវតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឬ ច្បាប់ពិសេសផ្សេងទៀតដែលបានកំណត់។ ហេតុនេះហើយទើបបានជាមានការស្រាវជ្រាវលើប្រធានបទ "**ការឃុំខ្លួនបណ្តោះអាសន្នក្នុងដំណាក់កាលស៊ើបសួរ**" នេះឡើង។

តើការឃុំខ្លួនបណ្តោះអាសន្ននៅដំណាក់កាលស៊ើបសួរ ចាំបាច់ត្រូវគោរពនូវលក្ខខណ្ឌអ្វីខ្លះ? មានរយៈពេលប៉ុន្មាន និងនីតិវិធីបែបណាខ្លះដើម្បីឱ្យបានត្រឹមត្រូវតាមច្បាប់?

## ៣. គោលបំណងនៃការស្រាវជ្រាវ

រាល់ការស្រាវជ្រាវសុទ្ធតែផ្សារភ្ជាប់មកជាមួយនឹងគោលបំណង និងការខិតខំធ្វើយ៉ាងណាឱ្យសម្រេចបាននូវសមិទ្ធផលដ៏ល្អមួយ។ មូលហេតុដែលក្រុមខ្ញុំបាទស្រាវជ្រាវលើប្រធានបទ៖ ការឃុំខ្លួនបណ្តោះអាសន្នក្នុងដំណាក់កាលស៊ើបសួរ ខាងលើព្រោះក្រុមខ្ញុំបាទមានគោលបំណងដូចខាងក្រោម៖

- ដើម្បីយល់ដឹងអំពីនីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន។
- ដើម្បីយល់ដឹងអំពីរយៈពេលនៃការឃុំខ្លួន។
- មានគោលបំណងផ្សព្វផ្សាយ និងជួយជំរុញឱ្យមានការយល់ដឹងកាន់តែច្បាស់ពីការឃុំខ្លួនបណ្តោះអាសន្ន។
- ដើម្បីរក្សាទុកជាឯកសារសម្រាប់ប្អូនៗ មិត្តនិស្សិត ឬមិត្តអ្នកអានធ្វើការស្រាវជ្រាវបន្ត។

## ៤. វិសាលភាពសារណា

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ យើងសង្កេតឃើញថាការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើឡើងទាំងនៅក្នុងដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះក្តីផងដែរ។ ក៏ប៉ុន្តែការស្រាវជ្រាវលើប្រធានបទនៃការឃុំខ្លួននេះ ខ្ញុំបាទនឹងធ្វើការស្រាវជ្រាវតែទៅលើការឃុំខ្លួនបណ្តោះអាសន្នដែលធ្វើឡើងក្នុងដំណាក់កាលនៃការស៊ើបសួរតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតការស្រាវជ្រាវប្រធានបទមួយនេះ ផ្តោតសំខាន់លើលំហូរនីតិវិធីនៃការឃុំខ្លួនបណ្តោះ អាសន្នចំពោះតែការចោទប្រកាន់ទាំងឡាយណាដែលមានខ្លួនបុគ្គលដែលជាកម្មវត្ថុនៃការចោទប្រកាន់តែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី "ការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដំណាក់កាលស៊ើបសួរ" ធ្វើឡើង ក្នុងគោលបំណងស្វែងយល់អំពីការគោរព និងធានាឱ្យបាននូវនីត្យានុកូលភាពនៃការឃុំខ្លួនបណ្តោះអាសន្ន។ មានន័យថា មុននឹងធ្វើការឃុំខ្លួនបណ្តោះអាសន្នចៅក្រមស៊ើបសួរ ត្រូវគិតអំពីគោលការណ៍សេរីភាពរបស់ជនត្រូវចោទហើយប្រសិនបើសម្រេចថានឹងឃុំ ត្រូវតែគោរពឱ្យបានអំពីលក្ខខណ្ឌដែលមានកំណត់នៅក្នុងច្បាប់ជាធរមាន។

ក្នុងការស្រាវជ្រាវនេះ ក៏បានជួយឱ្យក្រុមខ្ញុំបាទបានស្វែងយល់កាន់តែច្រើនពីការឃុំខ្លួនបណ្ដោះអាសន្ន ក្នុងដំណាក់កាលស៊ើបសួរ និងបានយល់ដឹងអំពីសិទ្ធិរបស់ជនជាប់ចោទ។

ក្រៅពីការសិក្សាស្វែងយល់ហើយ ការស្រាវជ្រាវសារណាមួយនេះក៏មានសារៈប្រយោជន៍ផ្សេងៗទៀត ដូចជាទុកជាឯកសារសម្រាប់មិត្តអ្នកអាន និងសិស្សច្បង សិស្សប្អូន អ្នកសិក្សាទុកជាគ្រឹះមួយចំណែកក្នុងការយក ទៅអនុវត្ត ឬ យកទៅសិក្សាស្វែងយល់បន្ថែមទៀតបាន។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវដើម្បីចងក្រងរបាយការណ៍នេះ ខ្ញុំបាទផ្អែកលើការសិក្សាពីប្រភព លិខិតតុបករ ណ៍អន្តរជាតិ និង ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាដែលពាក់ព័ន្ធទៅនឹងប្រធានបទនេះជាពិសេស គឺក្រមនីតិវិធី ព្រហ្មទណ្ឌតែម្ដង។

## ៧. រចនាសម្ព័ន្ធនៃសារណា

ក្រោយពីបានពិភក្សាគ្នា និងស្វែងរកនូវឯកសារដែលពាក់ព័ន្ធនានាព្រមទាំងទទួលបាននូវការណែនាំ និងឯកភាពពីសាស្ត្រាចារ្យណែនាំរួចមកក្រុមខ្ញុំបាទបានសម្រេចបែងចែករចនាសម្ព័ន្ធនៃការស្រាវជ្រាវ ដូចខាង ក្រោម៖

- **សេចក្ដីផ្ដើម៖** និយាយពី លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការដោះស្រាយ គោល បំណងនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការ សិក្សាស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

- **ជំពូកទី១៖** ពន្យល់ពីអត្ថន័យ និង សិក្សាពីខ្លឹមសារនៃពាក្យ សច្ចធារនៃនិរទោស។ បន្ថែមពី នេះទៀត ក៏មាននិយាយអំពីគោលការណ៍ផ្សេងៗដែលទាក់ទងទៅនឹងការឃុំខ្លួនបណ្ដោះអាសន្ន និងមូលដ្ឋាន គតិយុត្តនៃការឃុំខ្លួនបណ្ដោះអាសន្ន។

- **ជំពូកទី២៖** និយាយអំពីការអនុវត្តជាក់ស្ដែងនៅតាមស្ថាប័នតុលាការ និងមានការប្រៀបធៀប រវាងទ្រឹស្ដី ទៅនឹងការអនុវត្តជាក់ស្ដែងថា តើចំណុចណាខ្លះដែលតុលាការបានអនុវត្តយ៉ាងឃ្លាប់ឃ្លួនទៅតាម ទ្រឹស្ដីដែលកំណត់ដោយច្បាប់ និងចំណុចណាខ្លះដែលតុលាការមិនបានអនុវត្តទៅតាមទ្រឹស្ដីដែលច្បាប់បាន កំណត់។

ដើម្បីឱ្យកាន់តែច្បាស់លាស់ និងស៊ីជម្រៅលើប្រធានបទ យើងនឹងពិនិត្យទៅលើខ្លឹមសារទាំងស្រុងនៃ ប្រធានបទដូចខាងក្រោមនេះ៖

# ជំពូកទី១

# ការសិក្សាលើលិខិតគុបករណ៍

# និងទ្រឹស្តីគតិយុត្តដែលពាក់ព័ន្ធទៅ

# នឹងការឃុំខ្លួនបណ្តោះអាសន្នក្នុង

# ដំណាក់កាលស៊ើបសួរ

# ជំពូកទី១
# ការសិក្សាលើលិខិតតុបករណ៍ និងទ្រឹស្តីគតិយុត្តដែលពាក់ព័ន្ធទៅនឹងការឃុំខ្លួនបណ្តោះអាសន្នក្នុងដំណាក់កាលស៊ើបសួរ

## ១.១ គោលការណ៍នានាទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន

### ១.១.១ គោលការណ៍សច្ចាធារនៃនិរទោស

អ្វីទៅជា គោលការណ៍សច្ចាធារនៃនិរទោស?

ពាក្យថា **សច្ចាធារ** មានន័យថាជាការសន្មតជាមុន រីឯពាក្យថា **និរទោស** មានន័យថាគ្មានទោស ដូច្នេះហើយគោលការណ៍សច្ចាធារនៃនិរទោស **គឺសំដៅទៅលើការសន្មតជាមុនថាគ្មានទោស**។ មិនថាក្នុងក្របខណ្ឌនៃច្បាប់អន្តរជាតិ ឬ ច្បាប់ជាតិនោះទេសុទ្ធតែបានទទួលស្គាល់នូវគោលការណ៍នេះ ហើយគោលការណ៍នេះគឺជាសិទ្ធិមូលដ្ឋានរបស់មនុស្សម្នាក់ៗដែលត្រូវបានគេយកទៅប្រើប្រាស់ក្នុងដំណើរការនៃការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ។តាមរយៈគោលការណ៍នេះ គឺទាមទារឱ្យមានការយកចិត្តទុកដាក់ជាពិសេសពីបុគ្គលគ្រប់រូប បើទោះបីជាបុគ្គលម្នាក់នោះបានទទួលរងការចោទប្រកាន់ហើយក៏ដោយ ក៏បុគ្គលនោះត្រូវបានគេសន្មតថាគ្មានទោសនៅឡើយ ដរាបណាមិនទាន់មានសេចក្តីសម្រេចផ្តន្ទាទោសជាស្ថាពរពីតុលាការនោះទេ។ ការកំណត់យកគោលការណ៍មួយនេះយកមកប្រើប្រាស់នៅក្នុងនីតិវិធីព្រហ្មទណ្ឌនោះ ក៏ដោយសារតែមិនមែនសុទ្ធតែជាអំពើដែលបានប្រព្រឹត្តផ្ទុយនឹងច្បាប់ទាំងអស់សុទ្ធ តែត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនោះទេ ពីព្រោះមានករណីខ្លះច្បាប់ក៏បានចែងអំពីករណីមួយចំនួនដែលអាចនាំឱ្យមានការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ ដែលករណីនោះស្ថិតនៅក្រោមអំពើយុត្តិកម្ម និងគោលការណ៍ដែលមិនអាចទម្លាក់កំហុសបាន។

គោលការណ៍នេះត្រូវបានការពារយ៉ាងរឹងមាំបំផុតដោយច្បាប់កំពូលនៃព្រះរាជណាចក្រកម្ពុជា ពោលគឺរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានេះតែម្តង។ នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា"*ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ*"។[1] ក្រៅពីរដ្ឋធម្មនុញ្ញ គេក៏សង្កេតឃើញថាគោលការណ៍នេះមានកំណត់ផងដែរនៅក្នុងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ដែលជាបទដ្ឋានគតិយុត្តមួយទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[2] ដោយបានកំណត់ថា "*ជនដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌត្រូវបានសម្មត់ជាមុនថាជាជនគ្មាន*

[1] មាត្រា៣៨ កថាខណ្ឌទី៧, រដ្ឋធម្មនុញ្ញកម្ពុជា ប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

[2] មាត្រា៣១, រដ្ឋធម្មនុញ្ញកម្ពុជា ប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

*ទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់*”។[3] លើសពីនេះទៅទៀត នៅក្នុងសេក្តីប្រកាសជាសកលស្តពីសិទ្ធិមនុស្សក៏បានកំណត់ផងដែរថា “ **ជនណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌត្រូវសន្មតជាជនគ្មានទោសរហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញនៅក្នុងសវនាការជាសាធារណៈដែលមានការធានាចាំបាច់ដើម្បីឱ្យជននោះការពារខ្លួន**”។[4] ដោយផ្អែកលើបទបញ្ញត្តិជាតិ និងអន្តរជាតិទាំងអស់នេះហើយទើបនាំឱ្យមានការពិភាក្សា ក៏ដូចជាមានការខ្វែងគំនិតគ្នាយ៉ាងច្រើនពីសំណាក់អ្នកច្បាប់មួយចំនួន ជាពិសេសដោយផ្អែកលើគំនិតរៀងៗខ្លួន ដែលនាំឱ្យតំណាងរាស្រ្តដែលជាអ្នកមានសិទ្ធិចំនួនមួយភាគដប់ អាចដាក់ពាក្យប្តឹងទៅកាន់ក្រុមប្រឹក្សាធម្មនុញ្ញសុំឱ្យពិនិត្យពីធម្មនុញ្ញភាពនៃច្បាប់នានាបាន។[5] តួយ៉ាងកាលពីអំឡុងឆ្នាំ១៩៩៩ មានសមាជិកសភាមួយចំនួនបានដាក់ពាក្យប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងគោលបំណងពិនិត្យពីធម្មនុញ្ញភាពនៃ ច្បាប់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ដែលត្រូវបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៩៩ នាសម័យប្រជុំវិសាមញ្ញនីតិកាលទី១ ដោយសមាជិកសភាទាំង១៧រូប នោះបានប្តឹងថាការឃុំខ្លួនបណ្តោះអាសន្ននេះមានអធម្មនុញ្ញភាពទៅនឹងមាត្រា៣៨ កថាខណ្ឌ ទី៧ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៩។ ជាលទ្ធផលនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចថា **ការឃុំខ្លួនបណ្តោះ អាសន្ននោះ មិនមានភាពអធម្មនុញ្ញភាពទេ ដោយសម្អាងថា ការឃុំខ្លួនបណ្តោះអាសន្នរយៈពេលប៉ុណ្ណាក៏ដោយឱ្យតែមានកំណត់ក្នុងច្បាប់ហើយអនុវត្តត្រឹមត្រូវតាមនីតិវិធីឃុំខ្លួនបណ្តោះអាសន្ននោះ មិនចាត់ទុកថាជាមនុស្សមានទោសទេព្រោះក្នុងរយៈពេលនោះតុលាការគ្រាន់តែធ្វើការស៊ើបអង្កេត ឱ្យបានគ្រប់ជ្រុងជ្រោយមុននឹងឈានដល់ការជំនុំជម្រះថាតើខ្លួនមានទោស ឬមិនមានទោសប៉ុណ្ណោះ។**[6]

ហេតុនេះហើយ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានធ្វើការកំណត់នូវឋានៈរបស់បុគ្គលដែលត្រូវបានគេសង្ស័យ ថាបានប្រព្រឹត្តបទល្មើសទៅតាមដំណាក់កាលនៃនីតិវិធីនីមួយៗ ចាប់តាំងពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ រហូតដល់ចេញសេចក្តីសម្រេចស្ថាពរ។ ក្នុងការកំណត់នូវឋានៈរបស់បុគ្គលដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសនោះ គឺដើម្បីបង្កើនភាពងាយស្រួលក្នុងការកំណត់អំពីនីតិវិធី ក៏ដូចជាបង្កើនភាពងាយស្រួលក្នុងការស្វែងយល់ថា តើបុគ្គលនោះកំពុងស្ថិតក្នុងដំណាក់កាលណានៃនីតិវិធី ហើយបុគ្គលនោះអាចត្រូវបានចាត់ទុកថាជាជនដែលមានទោសហើយឬនៅ។ ក្រមនីតិវិធីបានកំណត់ឋានៈថាជា **ជន**

[3] មាត្រា១៤ កថាខណ្ឌទី២, កាតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុម័តនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦។

[4] មាត្រា១១ កថាខណ្ឌទី១, សេចក្តីប្រកាសជាសកលស្តីពី សិទ្ធិមនុស្ស អនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។

[5] មាត្រា១៤១ ថ្មី, រដ្ឋធម្មនុញ្ញកម្ពុជា ប្រកាសឱ្យប្រើនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៩៣។

[6] សេចក្តីសម្រេច ក្រុមប្រឹក្សាធម្មនុញ្ញ លេខ១៣ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៩។

**សង្ស័យ**[7] នៅក្នុងដំណាក់កាល មន្ត្រីនគរបាលយុត្តិធម៌ ចំណែកឯនៅក្នុងដំណាក់កាលស៊ើបសួរវិញជននោះត្រូវបានកំណត់ថាជា **ជនត្រូវចោទ**[8] ហើយនៅក្នុងដំណាក់កាលជំនុំជម្រះវិញជននោះត្រូវបានកំណត់ថាជា **ជនជាប់ចោទ**[9]។ មួយវិញទៀតជននោះត្រូវបានកំណត់ថាជា **ពិរុទ្ធជន**[10] កាលណាបុគ្គលនោះត្រូវបានតុលាការប្រកាសពីពិរុទ្ធភាព ហើយជននោះនឹងក្លាយជា **ទណ្ឌិត**[11] បើកាលណាសាលក្រមដែលបានប្រកាសពីពិរុទ្ធភាពនោះត្រូវបានចូលជាស្ថាពរ។

### ១.១.២ គោលការណ៍សេរីភាពរបស់បុគ្គល

ជាទូទៅមនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរ និងសិទ្ធិ[12] ហើយសិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ក៏ត្រូវបានធានាយ៉ាងរឹងមាំនៅក្នុងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់រដ្ឋនីមួយៗផងដែរ។ យ៉ាងណាមិញ រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ក៏បានបញ្ញត្តិថា "ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់"។[13] លើសពីនេះទៅទៀត ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានបញ្ញត្តិផងដែរថា "ជាគោលការណ៍ ជនត្រូវចោទត្រូវមានសេរីភាព។ ក្នុងករណីពិសេសជនត្រូវចោទត្រូវឃុំខ្លួនបណ្តោះអាសន្ននៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងជំពូកនេះ"។[14] ក្រៅពីនេះគោលការណ៍សេរីភាពនេះ ក៏មានកំណត់នៅក្នុងច្បាប់អន្តរជាតិមួយចំនួនផងដែរ ដោយក្នុងនោះនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សបានកំណត់ថា "គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬ និរទេសខ្លួនតាមអំពើចិត្តឡើយ"។[15] មិនតែប៉ុណ្ណោះគោលគារណ៍នេះក៏មានចែងនៅក្នុងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយផងដែរ ដោយខ្លឹមសារថា "ជនគ្រប់រូប មានសិទ្ធិ មានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ត្រូវចាប់ខ្លួន ឬ ឃុំខ្លួនតាមអំពើ

---

[7] ពាក្យទី៣៣៦ នៃ ៩០៤ពាក្យ, សន្ទានុក្រមនៃវិធានផ្ទៃក្នុង អ.វ.ត.ក (វិសោធនកម្មលើកទី៩) នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។

[8] ពាក្យទី៣៣៤ នៃ ៩០៤ពាក្យ, សន្ទានុក្រមនៃវិធានផ្ទៃក្នុង អ.វ.ត.ក (វិសោធនកម្មលើកទី៩) នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។

[9] ពាក្យទី៣៣៣ នៃ ៩០៤ពាក្យ, សន្ទានុក្រមនៃវិធានផ្ទៃក្នុង អ.វ.ត.ក (វិសោធនកម្មលើកទី៩) នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។

[10] ពាក្យទី៥៤២ នៃ ៩០៤ពាក្យ, សន្ទានុក្រមនៃវិធានផ្ទៃក្នុង អ.វ.ត.ក (វិសោធនកម្មលើកទី៩) នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។

[11] ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ដែលប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ១៧ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩២០ និងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា ស្តីពីការផ្ទេរទណ្ឌិត, លេខៈ នស/រកម/០៨០៩/០១៤, ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[12] មាត្រា១ វាក្យខណ្ឌទី១, សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។

[13] មាត្រា៣៨, រដ្ឋធម្មនុញ្ញកម្ពុជា ប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

[14] មាត្រា២០៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[15] មាត្រា៩, សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។

ចិត្តឡើយ។ គ្មានជនណាម្នាក់ត្រូវដកហូតសេរីភាពបានឡើយលើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់”។[16]

ដោយផ្អែកទៅលើគោលការណ៍ខាងលើនេះ យើងឃើញថាសេរីភាពរបស់បុគ្គលម្នាក់ត្រូវបានច្បាប់ការពារយ៉ាងខ្លាំង ហើយសេរីភាពរបស់បុគ្គលមិនអាចត្រូវបានរំលោភបំពាន ឬ ដកហូតដោយខុសច្បាប់នោះទេ ក៏ប៉ុន្តែការប្រើប្រាស់សេរីភាពរបស់ខ្លួន គឺមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សេរីភាព និងសេចក្តីថ្លៃថ្នូររបស់អ្នកដទៃនោះទេ ដោយត្រូវរក្សាស្ថេរភាព និងសណ្តាប់ធ្នាប់សាធារណៈនៅក្នុងសង្គម។ ដូចនេះក្នុងការការពារសណ្តាប់ធ្នាប់សាធារណៈ រដ្ឋនីមួយៗត្រូវតែមានច្បាប់ដើម្បីកំណត់ពីព្រំដែនក្នុងការប្រើប្រាស់សិទ្ធិសេរីភាពឱ្យបានត្រឹមត្រូវ ជនណាដែលប្រព្រឹត្តល្មើសបំពាន ឬ ប៉ះពាល់ដល់អ្នកដទៃត្រូវតែទទួលទោសតាមច្បាប់ ដែលបានកំណត់ពីអត្ថិភាពនៃបទល្មើស និងទោសជាធរមាន។ ក្នុងករណីនេះសិទ្ធិរបស់បុគ្គលនោះត្រូវបានដកហូតដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ។

ហេតុដូច្នេះហើយនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ទោះបីជាបុគ្គលម្នាក់ក្លាយជាជនត្រូវចោទដោយសារការចោទប្រកាន់របស់ព្រះរាជអាជ្ញាក៏ដោយ ជាគោលការណ៍ជនត្រូវចោទត្រូវមានសេរីភាពដែររហូតដល់មានសាលក្រមប្រកាសពីពិរុទ្ធភាពរបស់បុគ្គលនោះ ទើបគេអាចដកហូតសិទ្ធិសេរីភាពបុគ្គលលនោះបាន។ ប៉ុន្តែនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាក៏បានផ្តល់សិទ្ធិអំណាចយ៉ាងធំធេងដល់ចៅក្រមស៊ើបសួរក្នុងការដកហូតសិទ្ធិសេរីភាពរបស់បុគ្គលម្នាក់បានបើទោះបីជាមិនទាន់រកឃើញពីពិរុទ្ធភាពរបស់បុគ្គលនោះនៅឡើយក្តី។ តែទោះបីជាយ៉ាងណាក៏ដោយក៏ការដកហូតសិទ្ធិសេរីភាពរបស់បុគ្គលណាម្នាក់នោះ ត្រូវគោរពគោលការណ៍ច្បាប់ដែលបានកំណត់ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌជាធរមានផងដែរ។ ក្នុងន័យនេះ ទោះបីជាចៅក្រមស៊ើបសួរមានសិទ្ធិអំណាចក្នុងការសម្រេច ឃុំខ្លួនបណ្តោះអាសន្នចំពោះជនណាម្នាក់ក៏ពិតមែន ក៏ការសម្រេចឃុំខ្លួនរបស់បុគ្គលណាម្នាក់បាន លុះត្រាតែបានគោរពនូវលក្ខខណ្ឌដែលមានកំណត់នៅក្នុងមាត្រា២០៤[17] និងមានមូលហេតុតាមមាត្រា២០៥[18] ឬ មាត្រា២៣០[19] នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

---

[16] មាត្រា៩ កថាខណ្ឌទី១, កាតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុម័យនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦។

[17] មាត្រា២០៤, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[18] មាត្រា២០៥, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[19] មាត្រា២៣០, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

## ១.២. មូលដ្ឋានគតិយុត្តនៃការឃុំខ្លួនបណ្ដោះអាសន្ន

### ១.២.១ លក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្ន

ជាគោលការណ៍មូលដ្ឋានបុគ្គលគ្រប់រូបត្រូវមាននូវសិទ្ធិសេរីរបស់ខ្លួន ហើយបើទោះបីជាបុគ្គលម្នាក់ត្រូវបានចោទប្រកាន់ដោយតំណាងអយ្យការ ក៏ដោយក៏គេមិនទាន់អាចចាត់ទុកបុគ្គលនោះថាមានទោសដែរដរាបណាដែលមិនទាន់មានការប្រកាសទោសពីតុលាការ។ ប៉ុន្តែដើម្បីងាយស្រួលក្នុងការបំពេញកិច្ចរបស់ខ្លួន តុលាការអាចសម្រេចឃុំខ្លួនជាបណ្ដោះអាសន្នបានដើម្បីឱ្យតុលាការស្វែងរកថាជននោះមានទោសដែរឬទេតែប៉ុណ្ណោះ។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់យ៉ាងជាក់លាក់នូវមូលដ្ឋានគតិយុត្តក្នុងការឃុំខ្លួនបណ្ដោះអាសន្ន ទៅលើជនត្រូវចោទណាមួយនៅក្នុងដំណាក់កាលនៃការស៊ើបសួរ។ ក្នុងន័យនេះមានន័យថា មិនមែនគ្រប់បទល្មើសទាំងអស់ដែល ស្ថាប័នអយ្យការបានបើកការស៊ើបសួរសុទ្ធតែជាកម្មវត្ថុដែលចៅក្រមស៊ើបសួរត្រូវធ្វើការពិភាក្សាដេញដោលសម្រេចចំពោះការឃុំខ្លួនបណ្ដោះអាសន្ននោះទេ ពោលគឺចៅក្រមស៊ើបសួរអាចសម្រេចពីការឃុំខ្លួនបណ្ដោះអាសន្នលើបុគ្គលជនត្រូវចោទណាម្នាក់លុះត្រាតែបំពេញនូវលក្ខខណ្ឌក៏ដូចជាមូលហេតុដែលច្បាប់បានកំណត់ជាមុនសិន។

#### ១.២.១.១. លក្ខខណ្ឌទាក់ទងនឹងបទល្មើស

ជម្រើសនៃការចោទប្រកាន់របស់តំណាងអយ្យការ ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានកំណត់យកគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ដែលព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់ឡើងតាមរយៈការបើកការស៊ើបសួរ ការបញ្ជូនទៅជម្រះផ្ទាល់ ឬ តាមនីតិវិធីបង្គាប់ឱ្យចូលខ្លួនភ្លាម[20] ឬ សម្រេចតម្កល់រឿងទុកឥតចាត់ការ[21]។ ដូចយើងបានដឹងហើយថា នីតិវិធីនៃការបញ្ជូនរឿងទៅជម្រះផ្ទាល់ ឬ ការបង្ហាញខ្លួនភ្លាម គឺមិនឆ្លងកាត់ដំណាក់កាលចៅក្រមស៊ើបសួរនោះទេ ពោលគឺជាបញ្ជាឱ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូងតែម្តងមិនឆ្លងកាត់ដំណាក់កាលចៅក្រមស៊ើបសួរនោះទេ[22]។

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា "ការឃុំខ្លួនបណ្ដោះអាសន្ន អាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមដែលកំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១(មួយ)ឆ្នាំ"។[23] ដូច្នេះយើងឃើញថា ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចធ្វើចំពោះបទលហុបាននោះទេ ដោយសារតែបទលហុ គឺជាបទល្មើសដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវទទួលរងនោះមានរយៈពេលក្រោម ឬស្មើនឹង ៦

---

[20] មាត្រា៤៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[21] មាត្រា៤១, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[22] មាត្រា៤៦ និង មាត្រា៤៧, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[23] មាត្រា២០៤, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

(ប្រាំមួយ)ថ្ងៃ និងពិន័យជាប្រាក់ ឬ ជាបទល្មើសដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ។[24] ផ្ទុយទៅវិញ ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើបានគ្រប់បទល្មើសឧក្រិដ្ឋទាំងអស់ដោយសារតែបទឧក្រិដ្ឋគឺជាបទល្មើសដែលអតិបរមានៃទោសដាក់ពន្ធនាគារត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ឬ ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥(ប្រាំ)ឆ្នាំ និងក្រោម ឬ ស្មើនឹង ៣០(សាមសិប)ឆ្នាំ។[25] ក៏ប៉ុន្តែ ចំពោះបទមជ្ឈិមវិញនោះមិនមែនគ្រប់បទមជ្ឈិមទាំងអស់សុទ្ធតែជាកម្មវត្ថុនៃការសម្រេចឃុំខ្លួនបណ្តោះអាសន្ននោះទេ ដោយសារតែបទមជ្ឈិម គឺជាបទល្មើសដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះមានរយៈពេលលើសពី ៦(ប្រាំមួយ) ថ្ងៃ និងក្រោម ឬ ស្មើនឹង ៥(ប្រាំ)ឆ្នាំ។[26]

### ១.២.១.២ លក្ខខណ្ឌនៃទោសដែលត្រូវដាក់ពន្ធនាគារ

ការឃុំខ្លួនបណ្តោះអាសន្នតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ១(មួយ) [27]ឆ្នាំ ចំណុចនេះបញ្ជាក់អំពីគោលការណ៍ដែលច្បាប់បានកំណត់ចំពោះការ ឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមអាចធ្វើទៅបាន លុះត្រាបទល្មើសដែលត្រូវចោទប្រកាន់មិនមែនជាបទលហុដែលត្រូវជាបទមជ្ឈិម ឬ បទឧក្រិដ្ឋដោយមិនពិចារណាទៅលើទោសពិន័យជាប្រាក់ឡើយ។

តាមខ្លឹមសារនៃមាត្រានេះ ការឃុំខ្លួនបណ្តោះអាសន្នអនុវត្តបានតែក្នុងករណីដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារ មានន័យថាជាទោសដែលច្បាប់កំណត់សម្រាប់បទល្មើសនីមួយៗ មិនមែនទោសដែលត្រូវបានប្រកាសដោយសាលក្រមនោះទេ។ តួយ៉ាងដូចជាបទឧក្រិដ្ឋផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ដូចជាបទឃាតកម្មគិតទុកជាមុន[28] ផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ដូច្នេះចំពោះបទឧក្រិដ្ឋប្រភេទខាងលើនេះបានបំពេញលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្នដោយស្វ័យប្រវត្តិ។ ចំណែកឯបទមជ្ឈិមវិញ មានការបកស្រាយពីទោសអតិបរមា ឬ អប្បបរមាដែលច្បាប់បានកំណត់អាស្រ័យទៅតាមបទល្មើសនីមួយៗ។ បទល្មើសលួចដែលបញ្ញត្តិដោយច្បាប់ឱ្យផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ) ខែ ទៅ ៣(បី)ឆ្នាំ[29] ប្រសិនបើគិតពីអប្បបរមានៃទោស បទល្មើសនេះបានកម្រិតអប្បបរមាដាក់ពន្ធនាគារ ៦(ប្រាំមួយ)ខែ ចៅក្រមស៊ើបសួរមិនអាចឃុំខ្លួនបណ្តោះអាសន្នបានទេ ព្រោះមិនបានបំពេញលក្ខខណ្ឌអប្បបរមានៃទោសដាក់ពន្ធនាគារ។

---

[24] មាត្រា៤៨, ក្រមព្រហ្មទណ្ឌ ប្រកាសឱ្យប្រើថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
[25] មាត្រា៤៦, ក្រមព្រហ្មទណ្ឌ ប្រកាសឱ្យប្រើថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
[26] មាត្រា៤៧, ក្រមព្រហ្មទណ្ឌ ប្រកាសឱ្យប្រើថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
[27] មាត្រា២០៤, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[28] មាត្រា២០០, ក្រមព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
[29] មាត្រា៣៥៦, ក្រមព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

ជារួមមក សម្រាប់លក្ខខណ្ឌដែលទាក់ទងទៅនឹងបទល្មើសដែលត្រូវចោទប្រកាន់ខាងលើនេះ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទបាន លុះត្រាណាតែបទល្មើសដែលត្រូវចោទប្រកាន់នោះ បានបញ្ញត្តិទោសដាក់ពន្ធនាគារជាអតិប្បបរមាស្មើ ឬ លើសពី ១(មួយ)ឆ្នាំ ដូចដែលមានបញ្ញត្តិក្នុងមាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។ប៉ុន្តែទោះបីជាលក្ខខណ្ឌនេះត្រូវបានបំពេញក៏ដោយការសម្រេចឃុំខ្លួនបណ្ដោះ អាសន្នរបស់ចៅក្រមស៊ើបសួរត្រូវតែមានមូលហេតុច្បាស់លាស់ដែលមានកំណត់នៅក្នុងច្បាប់។

**១.២.១.៣ លក្ខខណ្ឌទាក់ទងនឹងអាយុរបស់ជនត្រូវចោទ**

អនីតិជន សំដៅដល់ជនដែលមានអាយុតិចជាង ១៨(ដប់ប្រាំបី)ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស[30]។ ចំណែកឯនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌគឺចាប់ពីអាយុ ១៨(ដប់ប្រាំបី)ឆ្នាំឡើងទៅ។ ការកំណត់បែបនេះ ជាគោលការណ៍មួយដែលគិតពីឧត្តមប្រយោជន៍ដល់អនីតិជន ទៅតាមការកំណត់របស់លិខិតុបករណ៍អន្តរជាតិនានា ដែលកម្ពុជាបានផ្ដល់សច្ចាប័ន។

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ថាអនីតិជនអាយុតិចជាង ១៤(ដប់បួន)ឆ្នាំ មិនត្រូវបានឃុំខ្លួនបណ្ដោះអាសន្នទេ។ ប៉ុន្តែចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះឱ្យទៅ ឪពុកម្ដាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមណ្ឌលអប់រំថែរក្សាបណ្ដោះអាសន្នរង់ចាំសេចក្ដីសម្រេចរបស់តុលាការ។[31] ទន្ទឹមនឹងនេះ នៅក្នុងច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ក៏បានកំណត់ផងដែរថាអនីតិជនអាយុក្រោម ១៤(ដប់បួន)ឆ្នាំ មិនត្រូវបានឃុំខ្លួនបណ្ដោះអាសន្នឡើយ។ ក្នុងករណីអនីតិជនដែលកំពុងជាប់ឃុំត្រូវបានរកឃើញថាអាយុក្រោម ១៤(ដប់បួន)ឆ្នាំ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងការចោទប្រកាន់ និងបង្គាប់ឱ្យដោះលែងអនីតិជននោះជាបន្ទាន់ ទោះបីជាមានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះទៅអ្នកតំណាងដែលច្បាប់បានកំណត់។[32] ដូចនេះយើងអាចសន្និដ្ឋានបានថា ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនអាយុក្រោម ១៤(ដប់បួន)ឆ្នាំ មិនមែនជាកម្មវត្ថុនៃការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ហើយអនីតិជនអាយុក្រោយ ១៤(ដប់បួន)ឆ្នាំ ក៏មិនអាចត្រូវបានធ្វើការឃុំខ្លួនបណ្ដោះអាសន្ននោះដែរ។ ប្រសិនបើ អនីតិជនដែលមានអាយុតិចជាង ១៤(ដប់បួន) ឆ្នាំ មិនទទួលខុសត្រូវព្រហ្មទណ្ឌផងនោះ (ត្រូវផ្ដល់សំណងរដ្ឋប្បវេណីចំពោះព្យសនកម្មតាមរយៈវិធាននៃអំពើអនីត្យានុកូល) បើច្បាប់បញ្ញត្តិអនុញ្ញាតឱ្យមានការឃុំខ្លួននោះវាហាក់បីជាពុំសមហេតុផលឡើយ ឬ អាចនិយាយបានថាជាការរំលោភ

[30] មាត្រា៤ ចំណុច៣, យុត្តិធម៌អនីតិជន ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦។

[31] មាត្រា២១២, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[32] មាត្រា៣៩ កថាខណ្ឌទី៣, ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦។

លើសិទ្ធិកុមារដូចដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ចំពោះករណីអនីតិជនដែលមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ឡើងទៅ គឺតម្រូវឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ ហើយក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាក៏តម្រូវឱ្យមានការឃុំខ្លួនផងដែរក្នុងករណីចាំបាច់និងមានមូលហេតុស្របតាមច្បាប់[33]។ រីឯនីតិជនវិញ[34] គឺមិនមានការហាមឃាត់មិនឱ្យធ្វើការឃុំខ្លួនបណ្តោះអាសន្នឡើយ ប៉ុន្តែទោះបីជាលក្ខខណ្ឌអាយុនេះត្រូវបានបំពេញយ៉ាងណាក្តី ក៏ចៅក្រមស៊ើបសួរគប្បីពិចារណាឱ្យបានច្បាស់លាស់ថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានចាំបាច់ និងចុងក្រោយបំផុត ហើយការសម្រេចនេះក៏ត្រូវផ្អែកលើមូលហេតុដែលមានបញ្ញត្តិក្នុងច្បាប់ផងដែរ។

### ១.២.២ មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្ន ជានីតិវិធីមួយដែលធ្វើឡើងនៅមុនពេលជម្រះក្តី ក្នុងពេលដែលសំណុំរឿងព្រហ្មទណ្ឌស្ថិតនៅក្នុងដំណាក់កាលរបស់ចៅក្រមស៊ើបសួរ ។ ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើឡើងបានក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬមជ្ឈិម ដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំឡើងទៅ។ ជាទូទៅការឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើឡើងតាមរយៈគំនិតផ្តើមពីចៅក្រមស៊ើបសួរ ឬ តាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដោយយោងតាមការពិចារណា ការស្វែងយល់ដោយផ្ទាល់ទៅលើបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ ឬស្ថានភាពជាក់ស្តែងនៃបទល្មើសដែលបានប្រព្រឹត្ត។ នៅពេលដែលចៅក្រមស៊ើបសួរសម្រេចពីការឃុំខ្លួនបណ្តោះអាសន្ន នោះគឺត្រូវធ្វើឡើងតាមរយៈ «ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន» ដែលត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ចំពោះថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ដាច់ដោយឡែកពីគ្នាទៅតាមស្ថានភាពនៃជនត្រូវចោទ (នីតិជន ឬ អនីតិជន) ឬលក្ខណៈនៃបទល្មើស (បទមជ្ឈិម ឬបទឧក្រិដ្ឋ)។ បន្ថែមពីលើនេះទៀត ដើម្បីធ្វើការឃុំខ្លួនបានចៅក្រមស៊ើបសួរត្រូវបង្ហាញនូវមូលហេតុនៃការឃុំខ្លួនដូចមានចែងនៅក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយពន្យល់អំពីសម្អាងហេតុសម្រាប់គាំទ្រទៅលើមូលហេតុនីមួយៗ។

#### ១.២.២.១ មូលហេតុទូទៅនៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្តោះអាសន្ននេះជាការចាំបាច់៖[35]

១. ដើម្បីបញ្ចប់បទល្មើស ឬ បង្ការបទល្មើសកុំឱ្យកើតជាថ្មី។

[33] មាត្រា២០៥, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[34] តាមន័យច្បាប់ព្រហ្មទណ្ឌនីតិជន គឺបុគ្គលដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។ នីតិជនផ្ទុយពីអនីតិជន។ អនីតិជនគឺជាជនមានអាយុក្រោម១៨ឆ្នាំ។

[35] មាត្រា ២០៥, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

២. ដើម្បីកុំឱ្យមានការគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ ដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។

៣. ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។

៤. ដើម្បីរក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។

៥. ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ។

៦. ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស។

មួយវិញទៀត បន្ថែមពីលើបទប្បញ្ញត្តិស្តីពីលក្ខខណ្ឌ មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរមុននឹងសម្រេចឃុំខ្លួនបណ្តោះអាសន្នត្រូវពិចារណាលើរបាយការណ៍ ប៉ាន់ប្រមាណសុខមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនផងដែរប្រសិនបើមាន[36] ហើយចៅក្រមស៊ើបសួរត្រូវឈរលើគោលគារណ៍មួយថាការឃុំខ្លួនអនីតិជនបណ្តោះអាសន្នជាវិធានការចុងក្រោយ។[37]

### ១.២.២.២ មូលហេតុផ្សេងទៀតនៃការឃុំខ្លួនបណ្តោះអាសន្ន

នៅពេលដែលបុគ្គលណាម្នាក់បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះព្រះរាជអាជ្ញា និងធ្វើការចោទប្រកាន់រួច បញ្ជូនជននោះទៅចៅក្រមស៊ើបសួរដើម្បីធ្វើកិច្ចស៊ើបសួរដាក់បន្ទុក ឬដោះបន្ទុក ហើយប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាអំពើដែលបានប្រព្រឹត្តជាបទឧក្រិដ្ឋ ឬបទមជ្ឈឹម បានបង្កព្យសនកម្មធ្ងន់ធ្ងរដល់សង្គម នោះចៅក្រមស៊ើបសួរអាចធ្វើការឃុំខ្លួនបុគ្គលនោះដើម្បីបញ្ចប់ឬបង្ការបទល្មើសកុំឱ្យកើតឡើងជាថ្មី និងកុំឱ្យប៉ះពាល់ដល់នីតិវិធីស៊ើបសួរ។ ប៉ុន្តែប្រសិនបើអំពើនោះបានបង្កព្យសនកម្មតិចតួចដល់សង្គមជាតិ ហើយមានមូលហេតុសមស្របតាមច្បាប់ ដែលមិនធ្វើឱ្យប៉ះពាល់ដល់នីតិវិធីស៊ើបសួរទេ នោះចៅក្រមស៊ើបសួរអាចសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលាដោយស្ថិតក្នុងដំណាក់កាលស៊ើបសួរ។ជាផ្នែកមួយនៃវិធានការនិរន្តរាយ ដើម្បីធានាសម្រួលដល់ដំណើរការនៃកិច្ចស៊ើបសួរ ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ (នៅក្រៅឃុំ) ឬសម្រេចឃុំខ្លួនបណ្តោះអាសន្ន (នៅក្នុងឃុំ)។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ការត្រួតពិនិត្យតាមផ្លូវតុលាការមានអានុភាពបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំឱ្យ គោរពកាតព្វកិច្ចមួយ ឬច្រើនដែលរួមមានដូចជា៖

១៖ មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ។

២៖ មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

[36] មាត្រា៣៩ កថាខណ្ឌទី២, ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦។

[37] មាត្រា៣៩ កថាខណ្ឌទី១, ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦។

៣៖ មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ។

៤៖ ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៥៖ ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៦៖ ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ។

៧៖ មិនត្រូវបើកបររថយន្ត។

៨៖ មិនត្រូវទទួល ឬ ជួបបុគ្គលមួយចំនួន ដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ។

៩៖ ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងថិរវេលាបង់ប្រាក់នេះត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ។

១០៖ មិនត្រូវកាន់កាប់ ឬ យកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់។

១១៖ ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុ ដាក់ឱ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ។

១២៖ មិនត្រូវធ្វើសកម្មភាពវិជ្ជាជីវៈខ្លះ។

ចៅក្រមស៊ើបសួរអាចជ្រើសរើសយកកាតព្វកិច្ចមួយ ឬ ច្រើនក្នុងចំណោមកាតព្វកិច្ចខាងលើដើម្បីដាក់ទៅលើជនត្រូវចោទណាម្នាក់ដែលខ្លួនសម្រេចមិនឃុំខ្លួន។ ដើម្បីអនុវត្តចំណុចទាំង១២ខាងលើ ចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការអនុវត្តនៅអាណត្តិបោះឆ្នោត ឬ សកម្មភាពសហជីពបានទេ[38]។ ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការតាមគំនិតផ្តើមរបស់ខ្លួន ឬ តាមសេចក្តីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរ បញ្ជាក់នៅក្នុងដីការបស់ខ្លួន អំពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ។ ដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ[39]។

ប្រសិនបើជនត្រូវចោទគេចវេះដោយចេតនា ពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឱ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នបាន ទោះបីទោសជាប់ពន្ធនាគារដែលត្រូវរងនោះមានថិរវេលាប៉ុន្មានក៏ដោយ ហើយទោះបីជាជនត្រូវចោទត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលអតិបរិមាដែលមាន

[38] មាត្រា២២៣ កថាខណ្ឌទី៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[39] មាត្រា២២៦, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ចែងដោយមាត្រា២០៨ (ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋ) ដល់មាត្រា ២១០ (ចិរវេលានៃការឃុំខ្លួនបណ្ដោះ អាសន្ននៅក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិជាអាទិ៍) មាត្រា២១៣ (ចិរវេលានៃការឃុំខ្លួនបណ្ដោះ អាសន្នក្នុងបទឧក្រិដ្ឋទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤(ដប់បួន) ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី) ឆ្នាំ និងមាត្រា ២១៤ (ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទមជ្ឈិមទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤(ដប់បួន) ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី) ឆ្នាំ)។[40]

កាលណាចៅក្រមស៊ើបសួរ សម្រេចថានឹងឃុំខ្លួនបណ្ដោះអាសន្នដោយមូលហេតុខាងលើនេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជននោះ។ ប្រសិនបើជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវជូនមធ្យោបាយការពារកូនក្ដីរបស់ខ្លួន។[41]

ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទ តាមដីកាដែលមានសំអាងហេតុ។ ដីកាសម្រេចនេះត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។[42]

ការឃុំខ្លួនបណ្ដោះអាសន្នដែលសម្រេចតាមមាត្រានេះ មិនអាចឱ្យលើសពី ៤(បួន) ខែ ចំពោះនីតិជន និង ២(ពីរ) ខែ ចំពោះអនីតិជន។[43]

### ១.២.៣. ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

ថ្វីត្បិតតែនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្ដល់អំណាចដល់ចៅក្រមស៊ើបសួរអាចធ្វើការឃុំខ្លួនបណ្ដោះ អាសន្នចំពោះបុគ្គលណាម្នាក់បាន បើទោះបីជាមិនទាន់មានសាលក្រមព្រហ្មទណ្ឌប្រកាសពីពិរុទ្ធភាពរបស់បុគ្គលនោះនៅឡើយក៏ដោយ ក៏ប៉ុន្តែចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នត្រូវបានកំណត់យ៉ាងច្បាស់លាស់ដោយច្បាប់។ ក្នុងន័យនេះ ចៅក្រមស៊ើបសួរមិនអាចធ្វើការឃុំខ្លួនបណ្ដោះអាសន្នហួសពីចិរវេលាដែលច្បាប់បានកំណត់នោះទេ។ ការឃុំខ្លួនបណ្ដោះអាសន្នចំពោះជនត្រូវចោទណាម្នាក់មិនមានភាពដូចគ្នានោះទេ ពោលគឺវាអាស្រ័យទៅលើប្រភេទនៃបទល្មើស និងអាយុរបស់ជនត្រូវចោទដែលប្រព្រឹត្តបទល្មើសនោះផងដែរ។ ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នដូចខាងក្រោមនេះ៖

[40] មាត្រា២៣០ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[41] មាត្រា២៣០ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[42] មាត្រា២៣០ កថាខណ្ឌទី៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[43] មាត្រា២៣០ កថាខណ្ឌទី៤, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

### ១.២.៣.១. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះនីតិជន

អនីតិជន គឺសំដៅដល់បុគ្គលដែលមានអាយុចាប់ពី ១៨ (ដប់ប្រាំបី)ឆ្នាំ ឡើងទៅបើតាមន័យនៃច្បាប់ព្រហ្មទណ្ឌ។

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់យ៉ាងជាក់លាក់នូវថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះជនត្រូវចោទដែលជានីតិជន ដោយក្នុងនោះយើងសង្កេតឃើញមានថិរវេលាពីរផ្សេងគ្នាដែលអាចយកមកអនុវត្តចំពោះ ជនត្រូវចោទដែលជានីតិជន។ ក្នុងន័យនេះ ចៅក្រមស៊ើបសួរអាចសម្រេចយកថិរវេលាណាមួយយកមកអនុវត្តលើជនត្រូវចោទជានីតិជនបាន វាអាស្រ័យទៅតាមប្រភេទនៃបទល្មើសដែលបានចោទប្រកាន់លើជនត្រូវចោទ ថាតើជាបទមជ្ឈិម ឬបទឧក្រិដ្ឋ។

### ក. ករណីការចោទប្រកាន់ជាបទឧក្រិដ្ឋ

នៅក្នុងករណីដែលការចោទប្រកាន់ជាបទឧក្រិដ្ឋចំពោះជនត្រូវចោទដែលជានីតិជន ក្រមនីតិវិធីព្រហ្មទណ្ឌអនុញ្ញាតឱ្យចៅក្រមស៊ើបសួរអាចធ្វើការសម្រេចឃុំខ្លួនបណ្តោះអាសន្នបានចំពោះជនត្រូវចោទបានរយៈពេល៦(ប្រាំមួយ)ខែ។ ប៉ុន្តែ ដើម្បីសម្រួលដល់កិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ និងដំណើរការនៃការស្វែងរកយុត្តធម៌ជូនជនរងគ្រោះនោះនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យាពេលនៃការឃុំខ្លួនបណ្តោះអាសន្នបានចំនួន ២(ពីរ) ដងទៀត ដោយការពន្យាពេលម្តងបាន ៦(ប្រាំមួយ)ខែ ហើយការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ននេះមិនអាចលើសពី ២(ពីរ)ដងបានឡើយ។[44]

មួយវិញទៀតក្នុងករណីមានការចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋសង្គ្រាម ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ១(មួយ)ឆ្នាំ បានទេ ចំពោះបទល្មើសនីមួយៗ។ ប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យាពេលការឃុំខ្លួនបណ្តោះអាសន្នម្តងបាន១(មួយ)ឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យពន្យាការឃុំខ្លួនបណ្តោះអាសន្នបានតែ ២(ពីរ) ដងគត់។[45]

[44] មាត្រា២០៨, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[45] មាត្រា២១០, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

### ខ. ករណីការចោទប្រកាន់ជាបទមជ្ឈិម

ចំពោះនីតិជនដែលត្រូវចោទប្រកាន់ពីបទមជ្ឈិម ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤(បួន)ខែ បានទេ។ ប៉ុន្តែប្រសិនបើផុតរយៈពេលនេះ ចៅក្រមស៊ើបសួរអាចពន្យាការឃុំខ្លួនបណ្តោះអាសន្នបាន តែម្តងគត់មិនឱ្យលើសពី ២(ពីរ)ខែ ដោយដីកាដែលមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។[46]

អ្វីដែលគួរឱ្យគត់សម្គាល់នោះ គឺថាថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នខាងលើនេះមិនអាចលើសពី ពាក់ កណ្តាលនៃទោសដែលបានកំណត់ឡើយ។[47] ក្នុងន័យនេះថ្វីត្បិតតែក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់អំណាចឱ្យ ចៅក្រមស៊ើបសួរ មានរយៈពេលអតិបរមារហូតដល់ ៤(បួន)ខែ ក្នុងការឃុំខ្លួនបណ្តោះអាសន្ន ចំពោះជនត្រូវ ចោទដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈិមក៏ដោយ ក៏ប៉ុន្តែប្រសិនបើរយៈពេលពាក់កណ្តាលនៃអប្បរមានៃ ទោសដាក់ពន្ធនាគារចំពោះបទមជ្ឈិម ដែលជនត្រូវចោទបានចោទប្រកាន់នោះមានរយៈពេលតិចជាង ៤(បួន) ខែ នោះ ក្នុងករណីនេះចៅក្រមស៊ើបសួរមិនអាចធ្វើការឃុំខ្លួនបណ្តោះអាសន្នលើជននោះលើសពីរយៈពេល ពាក់កណ្តាលនោះបានទេ។

ជាឧទាហរណ៍ បុគ្គលម្នាក់បានប្រព្រឹត្តបទល្មើសលួចដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ) ខែ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ទៅ ៦.០០០.០០០(ប្រាំមួយលាន)រៀល។[48] ក្នុងករណីនេះយើងឃើញថារយៈពេលពាក់កណ្តាលអប្បរមានៃបទល្មើសនេះមានរយៈពេល ៣(បី) ខែ ដូច្នេះ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ននោះ ចៅក្រមស៊ើបសួរអាចសម្រេចឃុំ ខ្លួនជនត្រូវចោទនោះជាអតិបរមាបានត្រឹមតែរយៈពេល ៣(បី) ខែ តែប៉ុណ្ណោះ ហើយការពន្យាការឃុំខ្លួនក៏មិន អាចយកមកប្រើបាននោះដែរ។

### គ. ការពន្យារពេលការឃុំខ្លួនបណ្តោះអាសន្ន

ចំពោះការពន្យារពេលការឃុំខ្លួនបណ្តោះអាសន្ន ក្រមនីតិវិធីព្រហ្មទណ្ឌបានអនុញ្ញាតឱ្យធ្វើការពន្យារ ពេលការឃុំខ្លួនបណ្តោះអាសន្នបានតែក្នុងករណីដែលជនត្រូវចោទ ជានីតិជនត្រូវបានសម្រេចឃុំខ្លួន បណ្តោះអាសន្នតែប៉ុណ្ណោះ ក្នុងន័យនេះចំពោះជនត្រូវចោទដែលជាអនីតិជនវិញនោះក្រមនីតិវិធីព្រហ្មទណ្ឌមិន អនុញ្ញាតឱ្យធ្វើការពន្យារការឃុំខ្លួននោះទេ។

---

[46] មាត្រា២០៩, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[47] មាត្រា២០៩, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[48] មាត្រា៣៥៦, ក្រមព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

កាលណាចៅក្រមស៊ើបសួរសម្រេចថាពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជននេះ។ កាលណាជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួនកូនក្តីរបស់ខ្លួន។ ចៅក្រមស៊ើបសួរពន្យារពេលការឃុំខ្លួនបណ្តោះអាសន្នតាមដីកាដោយ មានសំអាងហេតុ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងទៅតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដីកានេះត្រូវឱ្យដំណឹងជាបន្ទាន់ដល់ជនត្រូវចោទ។[49]

### ១.២.៣.២. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជន

អនីតិជនអាយុតិចជាង ១៤(ដប់បួន)ឆ្នាំ មិនអាចត្រូវបានឃុំខ្លួនបណ្តោះអាសន្នទេ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននោះឱ្យឪពុកម្តាយ អ្នកអាណាព្យាបាល ឬ ក្នុងករណីគ្មានអ្នកអាណាព្យាបាលត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្ន រង់ចាំសេចក្តីសម្រេចរបស់តុលាការ។[50] ការឃុំខ្លួនអនីតិជនជាវិធានការចុងក្រោយ។[51]

**ចំណាំ៖** កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ៖

១- អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល។

២- ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០(ម្ភៃ)ឆ្នាំ។

៣- អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១(មួយ)ថ្ងៃ។

៤- អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬ តិចជាង ៥(ប្រាំ)ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល។[52]

---

[49] មាត្រា២១១, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[50] មាត្រា២១២, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[51] មាត្រា៣៩ កថាខណ្ឌទី១, ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦។

[52] មាត្រា១៦០, ក្រមព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

**ក. ករណីការចោទប្រកាន់ជាបទឧក្រិដ្ឋ**

ចំពោះអនីតិជនអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ និងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នមានដូចតទៅ៖

១. ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤(បួន)ខែ បានទេ កាលណាអនីតិជននេះមានអាយុតិចជាង ១៦(ដប់ប្រាំមួយ)ឆ្នាំ។

២. ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦(ប្រាំមួយ)ខែ បានទេ កាលណាអនីតិជននេះមានអាយុចាប់ពី ១៦(ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ។[53]

**ខ. ករណីការចោទប្រកាន់ជាបទមជ្ឈិម**

ចំពោះអនីតិជនអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ និងត្រូវចោទប្រកាន់ពីបទមជ្ឈិម ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នមានដូចតទៅ៖

១. ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ២(ពីរ)ខែ បានទេ កាលណាអនីតិជននេះមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម ១៦(ដប់ប្រាំមួយ)ឆ្នាំ។

២. ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤(បួន)ខែ បានទេកាលណាអនីតិជននេះមានអាយុចាប់ពី ១៦(ដប់ប្រាំមួយ)ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ។

ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នតាមចំណុចទី១ និងចំណុចទី២ ខាងលើនេះមិនត្រូវលើសពីពាក់កណ្ដាល នៃអប្បរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ។[54]

ឧទាហរណ៍ទី១ អនីតិជនម្នាក់អាយុ ១៥(ដប់ប្រាំ)ឆ្នាំ ឬ ១៧(ដប់ប្រាំពីរ)ឆ្នាំ បានប្រព្រឹត្តបទល្មើសលួចដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣(បី)ខែ ទៅ ១(មួយ)ឆ្នាំ និង ៦(ប្រាំមួយ)ខែ និងពិន័យជាប្រាក់ពី ៥០០.០០០(ហាសិបម៉ឺន)រៀល ទៅ ៣.០០០.០០០(បីលាន)រៀល។[55] ក្នុងករណីនេះឃើញថា រយៈពេលពាក់កណ្ដាលអប្បរមានៃបទល្មើសនេះមានរយៈពេល ១(មួយ)ខែ និង ១៥(ដប់ប្រាំ)ថ្ងៃ ដូច្នេះចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនជនត្រូវចោទនោះជាអតិបរមាបានត្រឹមតែ រយៈពេល ១(មួយ)ខែ និង១៥(ដប់ប្រាំ)ថ្ងៃ តែប៉ុណ្ណោះ។

---

[53] មាត្រា២១៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[54] មាត្រា២១៤, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[55] មាត្រា១៦០ និង មាត្រា៣៥៦, ក្រមព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

❖ **សម្គាល់៖**

អនីតិជនអាយុក្រោម ១៤(ដប់បួន)ឆ្នាំ មិនអាចឃុំខ្លួនបណ្តោះអាសន្នបានឡើយ[56]។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះ ឱ្យឪពុកម្តាយ អ្នកអាណាព្យាបាល ឬ ក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្នរងចាំសេចក្តីសម្រេចរបស់តុលាការ[57]។

ករណីការចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬឧក្រិដ្ឋសង្រ្គាម ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ០១(មួយ)ឆ្នាំបានទេ ចំពោះបទល្មើសនីមួយៗ។ ប៉ុន្តែនៅពេលផុតចិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្តោះអាសន្នបានម្តង ០១(មួយ)ឆ្នាំ ដោយដីកាដោយមានសម្អាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្តោះអាសន្ននេះបានតែ ០២(ពីរ)ដងគត់[58]។

## ១.៣. នីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន

ជាធម្មតាអំណាចក្នុងការសម្រេចឃុំខ្លួនបណ្តោះអាសន្ននៅដំណាក់កាលស៊ើបសួរ គឺជាអំណាចផ្តាច់មុខរបស់ចៅក្រមស៊ើបសួរក្នុងការសម្រេចឃុំខ្លួនជនត្រូវចោទណាម្នាក់នោះក៏ប៉ុន្តែការប្រើប្រាស់អំណាចឃុំខ្លួនបណ្តោះ អាសន្ននេះត្រូវស្ថិតនៅក្នុងក្របខណ្ឌស្របច្បាប់ ពោលគឺត្រូវគោរពនូវលក្ខខណ្ឌក៏ដូចជាត្រូវមានមូលហេតុមួយចំនួនដែលច្បាប់បានកំណត់ទុក។ លើសពីនេះទៅទៀត បើទោះបីជាបទល្មើសដែលតំណាងអយ្យការបានធ្វើការចោទប្រកាន់នោះបានបំពេញលក្ខខណ្ឌ ដូចមានចែងនៅក្នុងមាត្រា២០៤ និងមានមូលហេតុតាមមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌក៏ដោយ ក៏ការឃុំខ្លួនបណ្តោះអាសន្នមិនអាចធ្វើតាមការនឹកឃើញរបស់ចៅក្រមស៊ើបសួរដែលមានសមត្ថកិច្ចក្នុងការចាត់ការលើសំណុំរឿងណាមួយនោះទេ គឺចាំបាច់គោរពទៅតាមនិតិវិធីដែលក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ផងដែរ។ ហេតុនេះដើម្បីឃុំខ្លួនជនត្រូវចោទណាម្នាក់បាន ចៅក្រមស៊ើបសួរចាំបាច់បំពេញកាតព្វកិច្ចមួយចំនួននៅក្នុងនីតិវិធីដូចខាងក្រោមនេះ៖

### ១.៣.១. ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យ

ការដាក់ឱ្យបុគ្គលណាម្នាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ គឺជាអំណាចមួយរបស់ចៅក្រមស៊ើបសួរក្នុងការដាក់ឱ្យបុគ្គលណាម្នាក់មានឋានៈជាជនត្រូវចោទ ដែលជាកម្មវត្ថុនៃការបើកការស៊ើបសួរប្រឆាំងទៅលើជននោះ។ ចៅក្រមស៊ើបសួរត្រូវតែដាក់ឱ្យស្ថិតក្រោមការពិនិត្យនូវបុគ្គលដែលបានចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋាន

[56] មាត្រា៣៩ កថាខណ្ឌទី៣, ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦។
[57] មាត្រា២១២, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[58] មាត្រា២១០, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

បញ្ជូនរឿងឱ្យស៊ើបសួរ។ លើសពីនេះចៅក្រមស៊ើបសួរមានអំណាចដាក់ឱ្យស្ថិតក្រោមការពិនិត្យនូវបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថាបានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាគ្មានការចង្អុលបង្ហាញប្រាប់ឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ។ ហើយចៅក្រមស៊ើបសួរអាចដាក់បុគ្គលនោះឱ្យស្ថិតនៅក្រោមការពិនិត្យក្នុងឋានៈជាចារី ជាអ្នកផ្ដើមគំនិត ឬជាអ្នកសមគំនិត។[59]

នៅពេលចូលបង្ហាញខ្លួនលើកដំបូងរបស់ជនត្រូវចោទ ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទ ប្រាប់ជននេះឱ្យបានដឹងរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថាខ្លួនអាចឆ្លើយ ឬមិនឆ្លើយបានដោយសេរី។ និទ្ទេសស្ដីពីការប្រាប់នេះត្រូវចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង។[60]

មួយវិញទៀតនៅក្នុងករណីដែលអនីតិជនបង្ហាញខ្លួនលើកដំបូង ក្រៅពីការពិនិត្យអត្តសញ្ញាណអនីតិជនហើយប្រាប់ជននោះឱ្យបានដឹងពីរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់ឈ្មោះបទល្មើសដែលកំណតដោយច្បាប់ព្រមទាំងប្រាប់ពីសិទ្ធិមួយចំនួនដែលច្បាប់បានកំណត់ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ចអំពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យក្នុងករណីដែលជននោះជាអនីតិជន។[61] អ្វីដែលគួរឱ្យគត់សម្គាល់នោះ គឺថាប្រសិនបើចៅក្រមស៊ើបសួរមិនបានបំពេញកិច្ចទាំងនេះទេនោះ នឹងនាំឱ្យមានមោឃភាពនៃនីតិវិធី។[62]

### ១.៣.២. កិច្ចពិភាក្សាដេញដោលចំពោះការឃុំខ្លួនបណ្ដោះអាសន្ន

ក្រោយពីការដាក់បុគ្គលណាម្នាក់ឱ្យស្ថិតក្រោមការពិនិត្យរួចហើយ ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាកិច្ចការមួយដែលមានភាពចាំបាច់បំផុតដែលចៅក្រមស៊ើបសួរត្រូវធ្វើ។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ពុំបានកំណត់ឱ្យបានច្បាស់លាស់អំពីការពិភាក្សាដេញដោលចំពោះការឃុំខ្លួនបណ្ដោះអាសន្ននោះទេ ក៏ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា "ចៅក្រមស៊ើបសួរដែលសម្រេចថានឹងត្រូវឃុំខ្លួនបណ្ដោះអាសន្នដោយគំនិតផ្ដួចផ្ដើមរបស់ខ្លួនផ្ទាល់ ឬតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជននេះ។ កាលណាជនត្រូវចោទមានមេធាវីអមផងនោះមេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួន"។[63]

[59] មាត្រា១២៦, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[60] មាត្រា១៤៣ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[61] មាត្រា៣៣ កថាខណ្ឌទី២, ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦។
[62] មាត្រា៣៣ កថាខណ្ឌទី៣, ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦។
[63] មាត្រា២០៦ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ហេតុដូច្នេះហើយមុននឹងសម្រេចពីការឃុំខ្លួនជាបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវធ្វើនីតិវិធីសួរដេញដោលចំពោះមុខមួយដើម្បីទទួលបានការកត់សម្គាល់របស់ជនត្រូវចោទ និងមធ្យោបាយការពារខ្លួនរបស់មេធាវីប្រសិនបើជនត្រូវចោទមានមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទអមផងនោះ។ គួរបញ្ជាក់ផងដែរថា ក្នុងករណីដែលជនត្រូវចោទគឺជាអនីតិជនចាំបាច់ត្រូវមានមេធាវីអមជានិច្ច[64] ក្នុងនីតិវិធីសួរដេញដោលចំពោះមុខគប្បីមានការចូលរួមពីតំណាងអយ្យការ ជនត្រូវចោទ និង/ឬ មេធាវីជនត្រូវចោទដើម្បីបង្ហាញអំពីការអះអាងរបស់ពួកគេរៀងៗខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីគាំទ្រ ឬប្រឆាំងនឹងការសម្រេចឃុំខ្លួន។[65]

ការចូលរួមពីតំណាងអយ្យការ ដែលជាម្ចាស់បណ្តឹងអាជ្ញាមានតួនាទីយ៉ាងសំខាន់ក្នុងលើកឡើងនូវទឡ្ហីករណ៍ទាំងឡាយដែលបង្ហាញពីអត្ថិភាពនៃមូលហេតុដែលមាននៅក្នុងមាត្រា២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌហើយក៏ជាមូលដ្ឋាននៃការស្នើសុំដល់ចៅក្រមស៊ើបសួរឱ្យសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នផងដែរ។ រីឯជនត្រូវចោទនិងមេធាវីការពារសិទ្ធិរបស់ជនត្រូវចោទត្រូវធ្វើការកត់សម្គាល់ចំពោះការដេញដោលអំពីការឃុំខ្លួនបណ្តោះអាសន្ន ដោយព្យាយាមទាញយកទឡ្ហីករណ៍ទាំងឡាយណាដែលបង្ហាញពីនត្ថិភាពនៃមូលហេតុដែលតំណាងអយ្យការបានលើកឡើងដោយធ្វើយ៉ាងណាឱ្យចៅក្រមស៊ើបសួរយល់ឃើញថា ការឃុំខ្លួនជនត្រូវចោទពុំមានភាពចាំបាច់នោះទេ។ បន្ថែមពីលើទឡ្ហីករណ៍ដែលភាគីទាំងសងខាងបានលើកឡើងនោះចៅក្រមស៊ើបសួរមុននឹងសម្រេចឃុំខ្លួន ឬមិនឃុំខ្លួនបណ្តោះអាសន្នចំពោះជនត្រូវចោទណាម្នាក់នោះ ចៅក្រមស៊ើបសួរគប្បីត្រូវព្យាយាមសួរព័ត៌មានឱ្យបានច្រើនពាក់ព័ន្ធនឹងស្ថានភាពរស់នៅរបស់ជនត្រូវចោទដើម្បីជាមូលដ្ឋានក្នុងការសម្រេចឃុំខ្លួន ឬមិនឃុំខ្លួន ដូចជាជនត្រូវចោទជាអនីតិជនជាស្ត្រីមានផ្ទៃពោះ ជាស្ត្រីមានកូនតូចៗនៅជាមួយ ដោយគ្មានអ្នកណាផ្សេងទៀតជួលមើលថែរក្សាកូនតូចៗទាំងនោះ ឬជនត្រូវចោទជាចាស់ជរា -ល-។ ក្នុងស្ថាភាពបែបនេះបើអាចជៀសវាងបានមិនគប្បីសម្រេចឃុំខ្លួននោះឡើយ។[66]

### ១.៣.២.១ ការផ្តើមគំនិតក្នុងការសម្រេចឃុំខ្លួនបណ្តោះអាសន្ន

#### ក. ការឃុំខ្លួនតាមការស្នើសុំរបស់តំណាងអយ្យការ

ជាការអនុវត្តជាក់ស្តែងនៅពេលព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមកចៅក្រមស៊ើបសួរ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាការឃុំខ្លួនបណ្តោះអាសន្នជាករណីចាំបាច់ និងចុងក្រោយគាត់តែងតែភ្ជាប់មកជាមួយនូវដីកាសន្និដ្ឋានស្នើសុំឱ្យឃុំខ្លួនជនត្រូវចោទនោះ។ ក៏ប៉ុន្តែក្នុងករណីខ្លះទៀតដែលព្រះរាជអាជ្ញា

[64] មាត្រា១៤៣ កថាខណ្ឌទី៤ វាក្យខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[65] លិខិតលេខ១២០ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់រូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

[66] លិខិតលេខ១២០ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់រូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

យល់ឃើញថាការឃុំខ្លួនបណ្ដោះអាសន្នមិនតម្រូវ គាត់អាចស្នើឱ្យជនត្រូវចោទស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬពុំស្នើសុំអ្វីទាំងអស់គ្រាន់តែដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតែប៉ុណ្ណោះ។ មួយវិញទៀត ព្រះរាជអាជ្ញាអាចមានវត្តមាននៅក្នុងគ្រប់កិច្ចស៊ើបសួរ ជាពិសេសក្នុងការសួរចម្លើយជនត្រូវចោទក្នុងការសួរតទល់ និងក្នុងការស្ដាប់ចម្លើយ67។ បញ្ញត្តិនៃមាត្រា ១៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌមិនមែនជាបញ្ញត្តិដាច់ខាតដែលព្រះរាជអាជ្ញាត្រូវតែមានវត្តមានគ្រប់កិច្ចរបស់ចៅក្រមស៊ើបសួរនោះទេ។ ដោយហេតុថា ការសន្និដ្ឋានរបស់តំណាងអយ្យការនៅក្នុងដីកាសន្និដ្ឋានស្នើសុំឱ្យឃុំខ្លួនបណ្ដោះអាសន្នរបស់គាត់ គឺបង្ហាញជាស្រេចនូវសេចក្ដីសម្រេចរបស់គាត់ នៅពេលដែលគាត់ទទួលបានសំណុំរឿងព្រហ្មទណ្ឌណាមួយ បើទោះបីជាគាត់មានវត្តមាននៅក្នុងការសួរតទល់ និងការស្ដាប់ចម្លើយរបស់ជនត្រូវចោទ ក៏គាត់នៅតែរក្សាការសន្និដ្ឋានឃុំខ្លួនរបស់គាត់ដដែល ។

ដូចនេះការបញ្ញត្តិមិនដាច់ខាតបែបនេះ ជាការជួយសម្រួលដល់តំណាងអយ្យការក្នុងការយកពេលវេលានេះទៅបំពេញកិច្ចផ្សេងៗទៀត។ ប៉ុន្ដែការបញ្ញត្តិបែបនោះ ក៏មិនហាមឃាត់វត្តមានរបស់តំណាងអយ្យការនោះដែរ ។

បើទោះបីជាក្រោយពីទទួលបានសំណុំរឿងដោយមានការសន្និដ្ឋានដោយការស្នើសុំបែបនេះក្ដី ក៏ចៅក្រមស៊ើបសួរមិនជាប់កាតព្វកិច្ចក្នុងការគោរពតាមសេចក្ដីសន្និដ្ឋានសុំឱ្យឃុំខ្លួនបណ្ដោះអាសន្នរបស់តំណាងអយ្យការឡើយ ។ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនជនត្រូវចោទតាមការស្នើសុំរបស់តំណាងអយ្យការគាត់ត្រូវចេញដីកាមួយដែលឱ្យឈ្មោះថា ***ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន*** ដោយមិនចាំបាច់មានសំអាងហេតុឡើយ[68]។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ទៅដល់អ្នកប្ដឹងដែលអ្នកប្ដឹងនៅទីនេះ គឺសំដៅទៅដល់តំណាងអយ្យការនោះឯង។

ប៉ុន្ដែប្រសិនបើចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្ដោះអាសន្ន លើជនត្រូវចោទចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេច និងដីកាបង្គាប់ឱ្យឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន។ មុននឹងចេញដីកានេះបាន ចៅក្រមស៊ើបសួរត្រូវតែគោរពលក្ខខណ្ឌផ្សេងៗដែលបានកំណត់ក្នុងច្បាប់។ នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នចៅក្រមស៊ើបសួរត្រូវតែមានសំអាងលើមូលហេតុនីមួយៗ[69]ដូចខាងក្រោម៖

១. ដើម្បីបញ្ចប់បទល្មើស ឬ បង្ការបទល្មើសកុំឱ្យកើតជាថ្មី។

[67] មាត្រា១៣៦, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[68] មាត្រា២០៧, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[69] មាត្រា២០៥, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

២. ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ ដើម្បីរារាំងដើម្បីកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនល្មើស និងអ្នកសមគំនិត។

៣. រក្សាភស្តុតាង ឬ តម្រុយជាសម្ភារៈ។

៤. ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។

៥. ដើម្បីធានាការពារសន្តិសុខជនត្រូវចោទ។

៦. ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។

**ខ. ការផ្តើមគំនិតដោយចៅក្រមស៊ើបសួរ**

បើទោះបីជាមាន ឬ មិនមានការស្នើសុំឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទក៏ដោយ ក៏ចៅក្រមស៊ើបសួរអាចមានសិទ្ធិក្នុងការសម្រេចឃុំ ឬ មិនឃុំខ្លួនបណ្តោះអាសន្នបានដែរ។ អ្វីដែលសំខាន់ ចៅក្រមស៊ើបសួរយល់ឃើញថា ប្រសិនបើការឃុំខ្លួនជាករណីចាំបាច់ ឬ មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន ដូចមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ហើយគួបផ្សំតំណាងអយ្យការមានការស្នើសុំឱ្យឃុំខ្លួនបណ្តោះអាសន្នផងនោះ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្តោះអាសន្នក្រោយពីបន្តនីតិវិធីដោយចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នដោយ មានសំអាងហេតុ យោងទៅលើមូលហេតុដូចមានចែងនៅក្នុងមាត្រា ២០៥[70]។ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះ អាសន្នត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

ប៉ុន្តែប្រសិនបើមានការស្នើសុំឱ្យឃុំខ្លួនបណ្តោះអាសន្នដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរពីតំណាងអយ្យការ ប៉ុន្តែចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ នោះចៅក្រមស៊ើបសួរនឹងចេញដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នទេ។ កាលដែលចៅក្រមមិនព្រមឃុំខ្លួនបណ្តោះអាសន្នតាមការស្នើសុំរបស់ព្រះរាជអាជ្ញាបែបនេះ គាត់ត្រូវមានកាតព្វកិច្ចត្រូវចេញដីកាសម្រេចមិនឃុំខ្លួនជនត្រូវចោទក្នុងរយៈពេល  ៥ (ប្រាំ) ថ្ងៃ ប៉ុន្តែដីកាសម្រេចមិនឃុំខ្លួននេះមិនចាំបាច់មានសំអាងឡើយ[71]។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចនៅក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរដែលនឹងសម្រេចជំនួសចៅក្រមស៊ើបសួរ។

[70] មាត្រា២០៦ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[71] មាត្រា២០៧, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

### ១.៣.២.២ នីតិវិធីមុនការសម្រេច និងបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន

មុននឹងធ្វើការសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទណាម្នាក់ ចៅក្រមស៊ើបសួរត្រូវបំពេញកិច្ចមួយចំនួនជាមុនសិន ដែលកិច្ចនោះមានដូចជា ការបង្ហាញខ្លួនលើកដំបូង និងការពិភាក្សាដេញដោលចំពោះមុខ។

**ក. ការបង្ហាញខ្លួនលើកដំបូង**

បន្ទាប់ពីជនត្រូវចោទបានបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូងដែលនៅក្នុងកំណត់ហេតុនេះត្រូវបំពេញកិច្ចមួយចំនួនដូចខាងក្រោម៖[72]

ចៅក្រមស៊ើបសួរត្រូវធ្វើការពិនិត្យអត្តសញ្ញាណជនត្រូវចោទដែលត្រូវបានបង្ហាញខ្លួននៅចំពោះមុខ ការធ្វើបែបនេះ គឺដើម្បីការពារការភាន់ច្រឡំណាមួយដែលអាចកើតឡើងជាយថាហេតុ។ ជាពិសេសត្រូវផ្ទៀងផ្ទាត់លើអត្តសញ្ញាណរបស់ជនដែលនាំមកបង្ហាញខ្លួនទៅនឹងអត្តសញ្ញាណដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម មួយវិញទៀតដើម្បីដឹងពីស្ថានភាពរបស់ជននោះដូចជាជនត្រូវចោទនោះជាអនីតិជនជាដើម។

សិទ្ធិក្នុងការទទួលពីមូលហេតុនៃការចាប់ខ្លួន ការឃាត់ខ្លួន ជាសិទ្ធិមូលដ្ឋានដែលត្រូវធានា និងត្រូវតែទទួលបានដោយជនត្រូវចោទដែលទទួលស្គាល់ដោយច្បាប់ជាតិ និងលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ។ ជនណាដែលត្រូវបានចាប់ខ្លួន ជននោះមានសិទ្ធិឱ្យគេប្រាប់ឱ្យដឹងអំពីមូលហេតុនៃការចាប់ខ្លួន និងត្រូវប្រាប់ឱ្យដឹងភ្លាមអំពីមូលហេតុនៃការចោទប្រកាន់[73]។ នៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទ ប្រាប់ជននោះឱ្យដឹងពីរឿងរ៉ាវដែលបានចោទប្រកាន់ និងឈ្មោះបទល្មើសចាត់ទុកថាជាការគោរពសិទ្ធិដល់ជនត្រូវចោទ ក្នុងការអនុញ្ញាតឱ្យជនត្រូវចោទនោះអាចត្រៀមខ្លួនក្នុងការការពារខ្លួន ក៏ដូចជាពឹងពាក់មេធាវីដើម្បីជួយការពារជាដើម។

ចៅក្រមស៊ើបសួរត្រូវប្រាប់ដល់ជនត្រូវចោទឱ្យបានដឹងថាខ្លួនមានសិទ្ធិក្នុងការឆ្លើយ ឬមិនឆ្លើយដោយសេរីនូវរាល់សំណួរដែលត្រូវបានសួរ។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថាខ្លួនមានសិទ្ធិក្នុងការឆ្លើយ ឬ មិនឆ្លើយដោយសេរី។ និទ្ទេសស្តីពីការប្រាប់នេះត្រូវចុះនៅក្នុងកំណត់ហេតុពេលចូលបង្ហាញខ្លួនលើកដំបូង។

---

72 មាត្រា១៤៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

73 មាត្រា៩ កថាខណ្ឌទី២, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ប្រកាសឱ្យប្រើនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២។

ប្រសិនបើជនត្រូវចោទចង់ឆ្លើយនោះ ចៅក្រមស៊ើបសួរត្រូវទទួលយកចម្លើយនោះភ្លាម។ រាល់ចម្លើយទាំងឡាយណាដែលទទួលបានមកពីការធ្វើទារុណកម្មលើជនត្រូវចោទនឹងត្រូវទុកជាមោឃៈ។

ចៅក្រមស៊ើបសួរត្រូវប្រាប់ជនត្រូវចោទឱ្យបានដឹងអំពីសិទ្ធិក្នុងការមានមេធាវីដើម្បីការពារសិទ្ធិដោយការមានមេធាវីនេះ ជនត្រូវចោទអាចធ្វើបានតាមរយៈការជ្រើសរើសមេធាវី ឬ ក្នុងការសុំឱ្យមានការចាត់តាំងមេធាវីឱ្យខ្លួនដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី[74]។ ក្រោយពីទទួលបាន ឬ បានដឹងអំពីសិទ្ធិហើយ ជនត្រូវចោទអាចស្វែងរកមេធាវីក្នុងការការពារសិទ្ធិបាន ឬអាចពឹងពាក់មេធាវីតាមរយៈសាច់ញាតិដោយសេរីនៅគ្រប់មេធាវីទាំងឡាយដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះសមាជិកគណៈមេធាវី។ ប៉ុន្តែប្រសិនបើជនត្រូវចោទពុំមានលទ្ធភាពក្នុងការពឹងពាក់មេធាវីទេ ជនត្រូវចោទអាចស្នើសុំឱ្យមានការចាត់តាំងមេធាវីតាមច្បាប់ស្តីពីលក្ខខន្តិកៈមេធាវី។ ហើយក្នុងករណីដែលជនត្រូវចោទជាអនីតិជនវិញ ជននោះត្រូវតែមានមេធាវីអមនៅគ្រប់ដំណាក់កាលទាំងអស់ដើម្បីធានាថាមិនមានការបំពានសិទ្ធិណាមួយរបស់អនីតិជន។

ក្នុងករណីអនីតីជនត្រូវការកិច្ចការពារ និងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានីខេត្តដើម្បីចាត់វិធានការសមស្របទៅតាមសុខមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន[75]។

### ខ. ការពិភាក្សាដេញដោលចំពោះមុខ

កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ ត្រូវបានធ្វើបន្ទាប់ពីជនត្រូវចោទបាននាំយកមកបង្ហាញខ្លួន[76]។ កិច្ចពិភាក្សាដេញដោលចំពោះមុខអំពីការឃុំខ្លួន ឬមិនឃុំជាកិច្ចការដឹកនាំដោយចៅក្រមស៊ើបសួរក្នុងការស្តាប់ និងសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន ឬ មិនឃុំហើយកិច្ចនេះត្រូវចុះនៅក្នុងកំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ។ កិច្ចនេះមានលក្ខណៈ ប្រហែលទៅនឹងការពិភាក្សាដេញដោលចំពោះមុខដែរ ប៉ុន្តែធ្វើឡើងក្នុងគោលបំណងសម្រេចពីការឃុំ ឬមិនឃុំខ្លួនបណ្តោះអាសន្នតែប៉ុណ្ណោះ ។

ចៅក្រមស៊ើបសួរត្រូវប្រាប់ ឬជូនដំណឹងជនត្រូវចោទពីការសម្រេចឃុំខ្លួនដែលខ្លួនបានសម្រេចក្រោយពីកិច្ចពិភាក្សាដេញដោលបានបញ្ចប់[77]។

---

[74] មាត្រា១៤៣ កថាខណ្ឌទី៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[75] មាត្រា៣៩ កថាខណ្ឌទី៤, យុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦។

[76] មាត្រា២០៦, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[77] មាត្រា១៣៦, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ការទទួលការកត់សម្គាល់របស់ជនត្រូវចោទ ដែលអាចធ្វើឡើងដោយសេរីថាខ្លួនមានសិទ្ធិឆ្លើយ ឬមិនឆ្លើយនៅក្នុងអំឡុងពេលនៃកិច្ចនោះ។ ប៉ុន្តែប្រសិនបើជនត្រូវចោទចង់ឆ្លើយ ចៅក្រមស៊ើបសួរត្រូវទទួលនូវចម្លើយនោះ ។

បង្ហាញមធ្យោបាយការពារខ្លួនរបស់មេធាវីជនត្រូវចោទ (បើមាន) ដូចបានបញ្ជាក់ពីចំណុចខាងលើ ប្រសិនបើមានមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទមេធាវីនោះត្រូវបង្ហាញនូវមធ្យោបាយផ្សេងៗដើម្បីការពារសិទ្ធិកូនក្តីរបស់ខ្លួនឱ្យបាននៅក្រៅឃុំ ។

ព្រះរាជអាជ្ញាអាចមានវត្តមាននៅគ្រប់កិច្ចស៊ើបសួរ ជាពិសេសក្នុងការសួរចម្លើយជនត្រូវចោទក្នុងការសួរតទល់ ឬ ក្នុងការស្តាប់ចម្លើយ[78]។ បើយើងពិនិត្យទៅលើការប្រើប្រាស់ពាក្យ **អាចមានវត្តមាន** មានន័យថាមិនមែនចងជាកាតព្វកិច្ចចំពោះវត្តមានរបស់តំណាងអយ្យការនៅគ្រប់កិច្ចស៊ើបសួរនោះទេ។ ដូចនេះព្រះរាជអាជ្ញាដែលជាតំណាងអង្គការអយ្យការអាចចូលរួម ឬ មិនចូលរួមក៏បានចំពោះការពិភាក្សាដេញដោលចំពោះមុខនេះ ។ ចំពោះ ការឃុំខ្លួនបណ្តោះអាសន្ននេះដែរ ព្រះរាជអាជ្ញាដែលមានគំនិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទនោះគាត់អាចធ្វើដីកាសន្និដ្ឋានស្នើសុំឱ្យឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទដោយសំអាងទៅលើកាលទេសៈណាមួយតាមដែលខ្លួនយល់ឃើញដោយសេរី។ ប៉ុន្តែបើព្រះរាជអាជ្ញាចូលរួមនៅក្នុងកិច្ចនីតិវិធីនេះហើយ ការធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ដែលគាត់បានធ្វើក៏ភាគច្រើនមិនខុសពីសេចក្តីសន្និដ្ឋានដែលគាត់បានធ្វើជាលាយលក្ខណ៍អក្សរដែរ ។

ក្រោយពីបានបញ្ចប់ការពិភាក្សាដេញដោយដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននឹងត្រូវបានចេញដោយចៅក្រមស៊ើបសួរ កាលបើយល់ឃើញថាការឃុំខ្លួនបណ្តោះអាសន្នជាមធ្យោបាយចុងក្រោយ និងចាំបាច់ ។ បន្ទាប់ពីការចេញដីកានេះហើយ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទ និងព្រះរាជអាជ្ញា។ ក្រោយពីការចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នហើយ ចៅក្រមស៊ើបសួរត្រូវចេញដីកាបង្គាប់ឱ្យឃុំខ្លួនទៅប្រធានពន្ធនាគារ ព្រោះដីកាសម្រេចឃុំបណ្តោះអាសន្នពុំមានអានុភាពបង្គាប់ឱ្យមណ្ឌលឃុំខ្លួន, ពន្ធនាគារទទួល និងឃុំជនត្រូវចោទឡើយ។

ក្រោយពីបានសិក្សាអំពីនីតិវិធីនៃការសម្រេចឃុំខ្លួនបណ្តោះអាសន្នរួចមកហើយនោះ ជាកិច្ចបន្ទាប់មកទៀតយើងនឹងធ្វើការសិក្សាអំពី **ការតាក់តែងដីកាសម្រេច និងបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ព្រមទាំងអានុភាពនៃដីកាទាំងពីរនេះផងដែរ** ។

---

[78] មាត្រា១៣៦, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

### ១.៣.៣ ការតាក់តែងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន

ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ននេះនៅក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ គឺពុំមានចែងអំពីទម្រង់ជាក់លាក់នៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ននេះឡើយ។ ប៉ុន្តែនាពេលកន្លងមកទាក់ទិនទៅនឹងការប្រើប្រាស់ទម្រង់ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នត្រូវបានចៅក្រមបង្កើតឡើងដើម្បីប្រើប្រាស់ក្នុងការឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទនៅពេលដែលគាត់យល់ឃើញថា វាជាវិធានការចាំបាច់និងចុងក្រោយបំផុត។ ដោយសារតែការតាក់តែងបែបនេះហើយ ដែលធ្វើឱ្យទម្រង់នៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នពុំមានការឯកភាពគ្នាឡើយដែលនាំឱ្យមានការលំបាកនៅក្នុងការអនុវត្តការឃុំខ្លួនបណ្ដោះអាសន្ន។ ដើម្បីជាការដោះស្រាយបញ្ហានេះនាដើមឆ្នាំ២០១៤ ក្រសួងយុត្តិធម៌បានចេញការណែនាំពីការអនុវត្តដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នលេខៈ ១២០កយ.រប/១៤ ចុះថ្ងៃទី២៣ខែមករា ឆ្នាំ២០១៤ កើតចេញពីសន្និសីទថ្នាក់ជាតិមួយស្ដីពីការអនុវត្តនីតិវិធីព្រហ្មទណ្ឌ ដែលបានរៀបចំឡើងនៅក្នុងឆ្នាំ២០១២ និងកិច្ចពិភាក្សាតុមូលនានាស្ដីពីកិច្ចការតុលាការដែលត្រូវបានរៀបចំឡើងដោយក្រសួងយុត្តិធម៌ និងការិល័យ UN-OHCHR ។ រូបមន្តថ្មីនេះ ត្រូវបានកែសម្រួលដោយចៅក្រមកម្ពុជាដោយផ្អែកលើការអនុវត្តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលមានស្រាប់ (អវតក) និងអនុលោមតាមលិខិតបទដ្ឋានអន្តរជាតិ ។

រូបមន្តថ្មីនេះ បានកំណត់អំពីបែបបទ និងនីតិវិធីនៃការឃុំខ្លួនបណ្ដោះអាសន្ន ប៉ុន្តែទោះបីជាយ៉ាងក៏ដោយយើងឃើញថានៅមានឧបសគ្គក្នុងការអនុវត្តមួយចំនួនដូចខាងក្រោមៈ

- ជនជាប់ចោទ ឬ មេធាវីការពារដាក់ពាក្យស្នើសុំនៅក្រៅឃុំជាមួយនឹងទឡ្ហីករណ៍ និងភស្តុតាងជាលាយលក្ខណ៍អក្សរ
- តំណាងអយ្យការមិនបានផ្ដល់ទឡ្ហីករណ៍អំពីការឃុំខ្លួន ជាទូទៅគ្រាន់តែស្នើសុំនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ
- កម្រមានសវនាការតូចមួយសម្រេចអំពីការឃុំខ្លួននេះ
- រូបមន្តប្រើដោយតុលាការភាគច្រើន គឺមានប្រអប់ចំនួន៦ សម្រាប់មូលហេតុទាំង៦ ក្នុងមាត្រា២០៥
- ចៅក្រមស៊ើបសួរជាធម្មតាតែងតែគូសលើប្រអប់១ ឬ ច្រើន នៅពេលសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ។

ទោះជាយ៉ាងណាក៏ដោយបន្ទាប់ពីការដាក់ឱ្យប្រើរូបមន្តថ្មីនេះនៅតែមានចំណុចខ្វះខាតនៅឡើយ ហេតុនេះហើយទើបរូបមន្តថ្មីនេះត្រូវបានកែសម្រួលម្ដងទៀត ហើយបញ្ជូនទៅគ្រប់តុលាការតាមរយៈលិខិតលេខៈ ២៩៥ កយ.រប/១៤ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៤ ដោយសម្រេចកែសម្រួលចំណុចខ្វះខាតចំនួន ២ ចំណុចៈ

១. នៅក្នុងលិខិតណែនាំដូចជម្រាបជូនខាងលើនៅបន្ទាត់ទី៩ រាប់ពីក្រោមឡើងលើ ទំព័រចុងក្រោយបានសរសេរថា "ចៅក្រមស៊ើបសួរត្រូវចុះហត្ថលេខា និងចុះកាលបរិច្ឆេទលើដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន" ឃ្លានេះសុំកែតម្រូវដោយដាក់ថា "ចៅក្រមស៊ើបសួរ និង ក្រឡាបញ្ជីត្រូវចុះហត្ថលេខា និងចុះកាលបរិច្ឆេទលើដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន" ។

២. នៅលើគម្រូរូបមន្ត ដែលបានជូនភ្ជាប់ជាមួយលិខិតខាងលើនេះ ក៏ពុំមានដាក់ឱ្យក្រឡាបញ្ជីចុះហត្ថលេខាដែរ ហើយក៏មានចំណុចខ្វះខាតមួយចំនួនទៀតផងដែរ។ ដូច្នេះ ក្រសួងសូមភ្ជាប់ជាមួយរូបមន្តថ្មីជាមួយនឹងលិខិតនេះដើម្បីប្រើប្រាស់ជាផ្លូវការជំនួសវិញ។

ត្រង់ចំណុចនេះ ក្រសួងហាក់បីជាមានកំហុសបច្ចេកទេសនៃការចុះនិទ្ទេស ដែលត្រូវចុះជាកាតព្វកិច្ចលើដីការបស់ចៅក្រមស៊ើបសួរដោយហេតុថាក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានបញ្ញត្តិគ្រប់ដីការបស់ចៅក្រមស៊ើបសួរទំព័រនីមួយៗនៃដីការត្រូវចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី[79]។

ដោយសារតែលិខិតខាងលើបំពេញបន្ថែម និងបានភ្ជាប់មកជាមួយនឹងគម្រូរូបមន្តថ្មីបែបនេះចំណុចបន្ទាប់យើងខ្ញុំសូមធ្វើការសិក្សាអំពីទម្រង់នៃដីកាសម្រេចឃុំជាបីដូចតទៅ៖

### ១.៣.៣.១ ដើមដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

នៅក្នុងដើមដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននៅក្នុងគម្រូនៃរូបមន្តដែលតាក់តែងដោយក្រសួងយុត្តិធម៌តាមរយៈការភ្ជាប់មកជាមួយលិខិតលេខៈ ១២០ កយ.រប/ ២០១៦ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ត្រូវសរសេរនូវចំណុចមួយចំនួនដូចខាងក្រោម៖

- ឈ្មោះនៃតុលាការ (សាលាដំបូងរាជធានី-ខេត្ត)
- លេខ និងកាលបរិច្ឆេទសំណុំរឿងព្រហ្មទណ្ឌ និងសំណុំរឿងស៊ើបសួរ
- ឈ្មោះចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីអម
- មាត្រាដែលពាក់ព័ន្ធ និងការឃុំខ្លួន
- លេខ និងកាលបរិច្ឆេទនៃដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការ
- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ឈ្មោះបទល្មើស និងអត្ថបទច្បាប់ដែលត្រូវផ្តន្ទាទោស
- យោងលើកំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង
- យោងលើកំណត់ហេតុនៃការពិភាក្សាដេញដោល និងការកត់សម្គាល់របស់ភាគីជាដើម ។

[79] មាត្រា២៤៣ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

### ១.៣.៣.២ ស្ថានភាពអង្គហេតុ និងអង្គច្បាប់

១. ចំណុចលេខ១តូចនេះចៅក្រមស៊ើបសួរត្រូវដាក់បញ្ចូលឈ្មោះបទល្មើសដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការ ។

២. ចំណុចលេខ២តូចនេះ ចៅក្រមស៊ើបសួរត្រូវសង្ខេបពីអង្គហេតុនៃរឿងក្តី ។

៣. ចំណុចលេខ៣តូចនេះ ចៅក្រមស៊ើបសួរត្រូវសង្ខេបពីសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ២ ឬ ៣ បន្ទាត់ដាក់បញ្ចូល។ តើតំណាងអយ្យការមានសំអាងអ្វីខ្លះដែលស្នើសុំឱ្យឃុំ ឬ មិនឃុំខ្លួន ធ្វើយ៉ាងនេះដើម្បីបង្ហាញថា ចៅក្រមស៊ើបសួរបានពិចារណាទៅលើមូលហេតុដែលតំណាងអយ្យការបានលើកឡើង ។

៤. ចំណុចលេខ៤តូចនេះ ចៅក្រមស៊ើបសួរត្រូវធ្វើសេចក្តីសង្ខេបពីការកត់សម្គាល់អះអា របស់ជនត្រូវចោទ ឬ មេធាវីរបស់ជនត្រូវចោទ ២ ឬ ៣ បន្ទាត់ ។[80]

### ១.៣.៣.៣ សំអាងហេតុសម្រេចឃុំខ្លួនបណ្តោះអាសន្ន

១. ត្រង់ចំណុចតូចនេះ ចៅក្រមស៊ើបសួរត្រូវតែប្រាកដថាជនត្រូវចោទពីបទឧក្រិដ្ឋដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពី១ឆ្នាំ (យោងតាមមាត្រា២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។ អាស្រ័យហេតុនេះ ចៅក្រមស៊ើបសួរត្រូវពិនិត្យមើលថា ប្រសិនបើរកឃើញពិរុទ្ធភាពក្រោយពេលសវនាការទោសជាប់ពន្ធនាគារស្មើ ឬ លើសពី១ឆ្នាំ ឬ អត់ ។

២. រីឯចំណុចនេះចៅក្រមស៊ើបសួរត្រូវសរសេរនូវការយល់ឃើញរបស់ខ្លួនឆ្លើយតបនឹងសំអាងនានាដែលបានលើកឡើងដោយភាគីដូចជា តំណាងអយ្យការ ជនត្រូវចោទ ឬ មេធាវីរបស់ជនត្រូវចោទ ។[81] ទន្ទឹមនេះ នៅក្នុងចំណុចនេះដែរ ចៅក្រមស៊ើបសួរត្រូវបង្ហាញមូលហេតុនៃការឃុំខ្លួនចំនួនមួយ ឬ ច្រើនដែលមានចែងនៅក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយពន្យល់បង្ហាញពីអង្គហេតុគាំទ្រទៅលើមូលហេតុនីមួយៗ ដែលចៅក្រមស៊ើបសួរបានលើក ។

### ១.៣.៣.៤ ការសម្រេចឃុំខ្លួនបណ្តោះអាសន្ន

ក្រោយពីបានធ្វើការដេញដោលចំពោះមុខរួចហើយ ចៅក្រមស៊ើបសួរចាំបាច់ត្រូវធ្វើសេចក្តីសម្រេចមួយថាតើត្រូវឃុំខ្លួនបណ្តោះអាសន្នចំពោះជនត្រូវចោទនោះ ឬមួយក៏សម្រេចមិនឃុំខ្លួនជនត្រូវចោទនោះជាបណ្តោះអាសន្ននោះទេ។ ក្នុងករណីដែលចៅក្រមស៊ើបសួរដែលទទួលបណ្តឹងតាមសេចក្តីសន្និដ្ឋានរបស់ព្រះ

[80] សេចក្តីណែនាំលេខ៖ ១២០កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ត្រង់ចំណុច ១។
[81] សេចក្តីណែនាំលេខ៖ ១២០កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ត្រង់ចំណុច ២។

រាជអាជ្ញាដែលសុំឱ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ននោះមិនព្រមធ្វើតាមការសុំឱ្យឃុំខ្លួននោះទេ ចៅក្រមស៊ើបសួរត្រូវចេញក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ នូវដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នដោយមិនចាំបាច់មានសំអាងហេតុទេ។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់អ្នកប្តឹងសុំប្រសិនបើចៅក្រមស៊ើបសួរដែលនឹងត្រូវសម្រេចជំនួសចៅក្រមស៊ើបសួរ។[82]

ផ្ទុយទៅវិញ ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ចៅក្រមស៊ើបសួរអាចសម្រេចឃុំជនត្រូវចោទជាបណ្តោះអាសន្នតាមដីកាដោយមានសំអាងហេតុ ហើយនៅក្នុងដីកានេះចៅក្រមស៊ើបសួរត្រូវយោងតាមបញ្ញត្តិនៃមាត្រា២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនេះ ហើយត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។[83]

ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចថានឹងឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នដោយគំនិតផ្តើមរបស់ខ្លួនផ្ទាល់ ឬ តាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជននេះ។ កាលណាជនត្រូវចោទមានមេធាវីអមផងនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួន។

ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នតាមដីកាដោយមានសំអាងហេតុ។ ក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងតាមបញ្ញត្តិនៃមាត្រា២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន)។ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នត្រូវបានជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។[84]

នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវបង្ហាញអំពីមូលហេតុនៃការឃុំខ្លួនចំនួនមួយ ឬច្រើនដែលមានកំណត់នៅក្នុងមាត្រា២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយពន្យល់ពីសំអាងហេតុគាំទ្រទៅនឹងមូលហេតុនីមួយៗ ដែលចៅក្រមស៊ើបសួរលើកឡើង ឬមិនត្រូវយកមកអនុវត្តដែលមានជាអាទិ៍ដូចខាងក្រោម[85]៖

- ចៅក្រមស៊ើបសួរ ត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចបញ្ចប់បទល្មើស ឬ បង្ការបទល្មើសកុំឱ្យកើតជាថ្មីថា តើមានហេតុផលសមរម្យដើម្បីជឿជាក់ថាជនត្រូវចោទអាចនឹងប្រព្រឹត្តបទល្មើសដែលខ្លួនត្រូវចោទឬទេ? និងថាតើមានហេតុផលសមរម្យដើម្បីជឿជាក់ថាជនត្រូវចោទអាចបន្តប្រព្រឹត្តបទល្មើស ឬប្រព្រឹត្តបទល្មើសនោះជាថ្មីឬទេ?

[82] មាត្រា២០៧, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[83] មាត្រា២០៦ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[84] មាត្រា២០៦ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[85] លិខិតលេខ១២០ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់របមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នផ្នែកII ចំណុចទី៦។

- ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចរារាំងដល់ការគាបសង្កត់សាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងជនសមគំនិត ថាតើមានហេតុផលសមរម្យ ដើម្បីជឿជាក់ថាជនត្រូវចោទអាចនឹងគាបសង្កត់សាក្សី ឬជនរងគ្រោះដែរឬទេ? និងថាតើជនសមគំនិតនៅតែមានសេរីភាព ឬទេ?
- ចៅក្រមស៊ើបសួរ ត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចរារាំងជនត្រូវចោទពីការធ្វើឱ្យខូចភស្តុតាង ឬតម្រុយជាសម្ភារៈថា តើនៅតែមានភស្តុតាង ឬតម្រុយជាសម្ភារៈដែលនគរបាលមិនទាន់មានដែរឬទេ? និងថាតើមានហេតុផលសមរម្យដើម្បីជឿជាក់ថាជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬបំផ្លាញភស្តុតាងឬតម្រុយជាសម្ភារៈឬទេ?
- ចៅក្រមស៊ើបសួរ ត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចធានារក្សាវត្តមានជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធីថា តើមានហេតុផលសមរម្យដើម្បីជឿជាក់ថាជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬភៀសខ្លួនទៅក្រៅប្រទេសដែរឬទេ?
- ចៅក្រមស៊ើបសួរ ត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចការពារសន្តិសុខឱ្យជនត្រូវចោទថា តើមានយោបល់ណាមួយដែលថាជនរងគ្រោះ ឬជនផ្សេងទៀតអាចចង់បង្កគ្រោះថ្នាក់ដល់ជនត្រូវចោទដែលឬទេ?
- ចៅក្រមស៊ើបសួរ ត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនជនត្រូវចោទអាចរក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានភាពច្របូកច្របល់ណាមួយដែលបណ្តាលមកពីបទល្មើសនេះ។
- ចៅក្រមស៊ើបសួរ គួរពិចារណាពីធាតុផ្សំហានិភ័យជាសក្តានុពលដើម្បីជាយុត្តិធម៌ដល់ការដាក់នរណាម្នាក់ក្នុងការឃុំខ្លួនជាបណ្តោះអាសន្ន ហើយក៏ពិចារណាផងដែរពីធាតុផ្សំដែលអាចបំបាត់ហានិភ័យនេះ។

ម្យ៉ាងទៀតយើងសង្កេតឃើញថា នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌពុំបានកំណត់ពីទម្រង់នៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននោះទេ តែទម្រង់នៃដីកាសម្រេច[86]នេះត្រូវបានក្រសួងយុត្តិធម៌ប្រកាសដាក់ឱ្យប្រើប្រាស់តាមរយៈលិខិតណែនាំលេខ៖ ២៩៥ កយ.រប/១៤ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការសុំកែសម្រួលលិខិតលេខ៖ ១២០ កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌។

[86] ឧបសម្ព័ន្ធទី២ ទម្រង់ដីកាសម្រេចដែលមាននៅក្នុងសេចក្តីណែនាំលេខ៖ ២៩៥ កយ.រប/១៤ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការសុំកែសម្រួលលិខិតលេខ៖ ១២០ កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌។

មិនតែប៉ុណ្ណោះ បើទោះបីជាមានដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នក៏ដោយដើម្បីមានអានុភាពបញ្ជាឱ្យប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំខ្លួនលើជនត្រូវចោទចាំបាច់ត្រូវមានដីកាបង្គាប់ឱ្យឃុំខ្លួនមួយទៀតភ្ជាប់ជាមួយនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

## ១.៣.៤ ការបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឱ្យឃុំខ្លួន។[87]

ដីកាបង្គាប់ឱ្យឃុំខ្លួន គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំឱ្យទទួល និងឱ្យឃុំខ្លួនជនត្រូវចោទ[88]។

ចៅក្រមស៊ើបសួរអាចនឹងចេញដីកាបង្គាប់ឱ្យឃុំខ្លួនបានលុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំបណ្តោះអាសន្ន។[89]

នៅក្នុងក្រមនីតិព្រហ្មទណ្ឌបានកំណត់យ៉ាងជាក់លាក់នូវនិទ្ទេសដែលត្រូវចុះនៅក្នុងដីកាបង្គាប់ឱ្យឃុំខ្លួនដែលមានដូចតទៅ៖[90]

- អត្តសញ្ញាណជនត្រូវចោទ។
- ប្រភេទនៃបទល្មើសដែលត្រូវចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ។
- ឈ្មោះ និងឋានៈរបស់ចៅក្រមស៊ើបសួរ ដែលចេញដីកា។

ដីកាបង្គាប់ឱ្យឃុំខ្លួនត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រា។

ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឱ្យឃុំខ្លួនរហូតទាល់ តែបានទទួលការឱ្យដំណឹងអំពីការដោះលែងឱ្យមានសេរីភាពវិញ។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនរក្សាទុកដើមដីកាបង្គាប់ឱ្យឃុំខ្លួន ឬ ចុងដីកានេះដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម[91]។

### ១.៣.៤.១ ដីកាបង្គាប់ឱ្យឃុំខ្លួន

ដីកាបង្គាប់ឱ្យឃុំខ្លួន គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនឱ្យទទួល និងឱ្យឃុំខ្លួនជនត្រូវចោទ។ ចៅក្រមស៊ើបសួរអាចនឹងចេញដីកាបង្គាប់ឱ្យឃុំខ្លួនបានលុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន ។

---

[87] មាត្រា២១៩, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[88] មាត្រា២២០ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[89] មាត្រា២២០ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[90] មាត្រា២២១, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[91] មាត្រា២២២, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

### ក. និទ្ទេសដែលត្រូវចុះបញ្ជីលើដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន

ដីកាបង្គាប់ឱ្យឃុំខ្លួនត្រូវចុះនិទ្ទេសដូចតទៅ៖[92]

- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ប្រភេទនៃបទល្មើសដែលត្រូវចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- ឈ្មោះ និងឋានៈចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឱ្យឃុំខ្លួន ត្រូវចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រា។

### ខ. ការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន

ដីកាបង្គាប់ឱ្យឃុំខ្លួនមានចែងក្នុងមាត្រា ២១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដីកានេះ មានន័យថាគឺជាការបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឱ្យឃុំខ្លួនជនត្រូវចោទ។ ចៅក្រមស៊ើបសួរអាចចេញដីកាឱ្យឃុំខ្លួនបានលុះត្រាជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន។ ការសម្រេចឃុំខ្លួនជនត្រូវចោទត្រូវផ្អែកលើមូលហេតុ ដូចមានចែងនៅមាត្រា ២០៥ គឺដើម្បីបញ្ចប់បទល្មើសកុំឱ្យគាបសង្កត់ដល់សាក្សី រក្សាភស្តុតាង រក្សាជនល្មើសទុកឱ្យតុលាការចាត់ការតាមនីតិវិធី ការពារសុវត្ថិភាពជូនជនល្មើស និងរក្សាសណ្តាប់ធ្នាប់សង្គម។

ការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួននេះ គឺជាការផ្ទេរជនត្រូវចោទដែលកំពុងមានវត្តមាននៅចំពោះមុខចៅក្រមស៊ើបសួរដើម្បីយកទៅដាក់នៅពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន។ ដើម្បីអាចអនុវត្តដីកានេះបានជាគោលការណ៍ចៅក្រមត្រូវប្រគល់ដីកា និងជនដែលជាកម្មវត្ថុនៃការឃុំខ្លួនបណ្តោះអាសន្នទៅមន្ត្រីនគរបានយុត្តិធម៌ ឬ/និងកងកម្លាំងសាធារណៈផ្សេងទៀត ដើម្បីការពារហានិភ័យដែលអាចកើតមានឡើងដូចជារត់គេចខ្លួនរបស់ជនត្រូវចោទ ការការពារសុវត្ថិភាព ក៏ដូចជាការលួចធ្វើឃាតជនត្រូវចោទជាដើម។ ហេតុនេះហើយមន្ត្រីនគរបាលយុត្តិធម៌ ឬ/និងកងកម្លាំងសាធារណៈទាំងនោះមានភារកិច្ចជាអ្នកនាំជនត្រូវចោទដែលជាកម្មវត្ថុនៃការឃុំខ្លួនពីចំពោះមុខចៅក្រមស៊ើបសួរយកទៅអនុវត្តការឃុំខ្លួនបណ្តោះអាសន្នពីតុលាការទៅប្រគល់ឱ្យប្រធានពន្ធនាគារ ឬ មន្ត្រីឃុំខ្លួនដើម្បីអនុវត្តដីកាឃុំខ្លួនតែប៉ុណ្ណោះ[93]។

[92] មាត្រា២២១, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[93] ប្រកាសលេខ៖ ២៧ កយធ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១១ ស្តីពីរបៀបរបបធ្វើការរបស់មន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងយុត្តិធម៌។

ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឱ្យឃុំខ្លួនរហូតទាល់តែបានទទួលការឱ្យដំណឹងអំពីការដោះលែងឱ្យមានសេរីភាពវិញ។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនរក្សាទុកដើមដីកាបង្គាប់ឱ្យឃុំខ្លួន ឬចុងដីកានេះដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម។[94]

### ១.៣.៤.២ សិទ្ធិរបស់ជនត្រូវចោទដែលមានក្នុងដំណាក់កាលឃុំខ្លួនបណ្តោះអាសន្ន

នៅក្នុងរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយការឃុំខ្លួននោះ គឺគ្រាន់តែជាការរក្សាជនត្រូវចោទនៅក្នុងពន្ធនាគារដើម្បីរង់ចាំការកាត់ក្តីស្វែងរកទោសតែប៉ុណ្ណោះថាតើជនត្រូវចោទនោះមានទោស ឬក៏គ្មានទោស[95]។ មួយវិញទៀត ជនត្រូវចោទត្រូវចាត់ទុកថាពុំមានទោសឡើយដរាបណាមិនទាន់មានការប្រកាសទោសជាស្ថាពរដោយតុលាការ[96]។ ហេតុដូចនេះហើយទើបច្បាប់ នៃព្រះរាជាណាចក្រកម្ពុជាក៏ដូចជាលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀតនៅតែទទួលស្គាល់នូវសិទ្ធិរបស់ជនត្រូវចោទ។

### ក. សិទ្ធិស្នើសុំឱ្យបំពេញកិច្ច

ជនត្រូវចោទដែលកំពុងស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន មានសិទ្ធិស្នើសុំឱ្យចៅក្រមស៊ើបសួរបំពេញកិច្ចផ្សេងៗដែលជនត្រូវចោទយល់ថាចាំបាច់ ដើម្បីបញ្ជាក់នត្ថិភាពនៃទោសរបស់ខ្លួនបាន។

នៅគ្រប់ពេលនៃការស៊ើបសួរ ជនត្រូវចោទអាចស្នើសុំឱ្យចៅក្រមស៊ើបសួរបំពេញកិច្ចមួយចំនួនដូចជា[97]៖

- ការសួរចម្លើយខ្លួន (ជនត្រូវចោទខ្លួនឯង)
- ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ការស្តាប់ចម្លើយសាក្សី
- ការសួរតទល់
- ការចុះទៅទីកន្លែងកើតហេតុ។

ចំពោះទម្រង់នៃការស្នើសុំនេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដើម្បីបញ្ជាក់ពីភាពប្រាកដច្បាស់លាស់និងត្រូវសរសេរបញ្ជាក់អំពីសំអាងហេតុឱ្យបានត្រឹមត្រូវ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យស្នើសុំរបស់ជនត្រូវចោទទេនោះ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធនៅក្នុងថេរវេលា ១(មួយ)ខែ បន្ទាប់ពី

[94] មាត្រា២២២, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[95] សេចក្តីសម្រេច ក្រុមប្រឹក្សាធម្មនុញ្ញលេខ៖១៣ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៩។
[96] មាត្រា៣៨ កថាខណ្ឌទី៦, រដ្ឋធម្មនុញ្ញ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។
[97] មាត្រា១៣៣ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

បានទទួលពាក្យសុំ។ ដីកានេះត្រូវតែមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងថិរវេលា ១(មួយ)ខែ ទេ ជនត្រូវចោទអាចប្ដឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[98]

### ខ. សិទ្ធិស្នើសុំនៅក្រៅឃុំ

ជនត្រូវចោទអាចដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរបញ្ជូនពាក្យនោះភ្លាមទៅព្រះរាជអាជ្ញាដើម្បីផ្ដល់យោបល់ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់ក្នុងរយៈពេលខ្លីបំផុត។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃបន្ទាប់ពីពេលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។

ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំសាជាថ្មីម្ដងទៀតទៅចៅក្រមស៊ើបសួរ ឬ ទៅសភាស៊ើបសួរក្នុងរយៈពេល ១(មួយ)ខែ បន្ទាប់ពីមានសេចក្ដីសម្រេចបដិសេធពាក្យសុំលើកមុន។ ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរត្រូវសម្រេចលើពាក្យនេះក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ។

ដីកាដែលមិនព្រមដោះលែងឱ្យនៅក្រៅឃុំត្រូវមានសំអាងហេតុ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃទេ ជនត្រូវចោទអាចធ្វើពាក្យប្ដឹងផ្ទាល់ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ[99]។

### គ. សិទ្ធិជ្រើសរើស ឬ ស្នើសុំ ឬ ចាត់តាំង ឬ ផ្លាស់ប្ដូរមេធាវី

ជនត្រូវចោទដែលស្ថិតនៅក្នុងដំណាក់កាលនៃការឃុំខ្លួនបណ្ដោះអាសន្នមានសិទ្ធិក្នុងការស្វែងរកមេធាវីរបស់ខ្លួនក្នុងករណីដែលខ្លួនមិនទាន់មានមេធាវី ឬអាចស្នើសុំមេធាវីក្នុងករណីដែលខ្លួនពុំមានលទ្ធភាពក្នុងការប្រើប្រាស់សេវាមេធាវី ឬ អាចទទួលបានការការពារសិទ្ធិដោយតុលាការបានចាត់តាំង ហើយគាត់ក៏អាចធ្វើការផ្លាស់ប្ដូរមេធាវីផ្សេងបានដែរ។

- **សិទ្ធិស្នើសុំមេធាវី** គឺជាការស្នើសុំមេធាវីអាចធ្វើទៅបាន ប្រសិនបើជនត្រូវចោទជាជនក្រីក្រដែលគ្មានលទ្ធភាពក្នុងការប្រើប្រាស់សេវាមេធាវី។ ការស្នើសុំនេះ គឺត្រូវធ្វើឡើងដោយមានការស្នើសុំទៅកាន់គណៈ

---
[98] មាត្រា១៣៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[99] មាត្រា២១៧, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

មេធាវីដែលទទួលបន្ទុកការពារជនក្រីក្រ ឬ មួយតាមបណ្តាលអង្គការក្រៅរដ្ឋាភិបាលផ្សេងៗដែលមានផ្តល់ជំនួយផ្នែកច្បាប់ជាពិសេសសេវាមេធាវីដោយមិនគិតថ្លៃជាដើម។

➢ **សិទ្ធិជ្រើសរើសមេធាវី** នៅក្នុងករណីមុនពេលដែលការឃុំខ្លួនបណ្តោះអាសន្នត្រូវបានធ្វើឡើង ប្រសិនបើជនត្រូវចោទពុំទាន់បានជ្រើសរើសមេធាវីនៅឡើយខ្លួនអាចជ្រើសរើសមេធាវីដែលជាសមាជិកគណៈមេធាវីដើម្បីការពារសិទ្ធិឱ្យខ្លួនបាន។

➢ **សិទ្ធិទទួលបានការចាត់តាំងមេធាវីដោយតុលាការ** គឺជាការចាំបាច់ក្នុងករណីពិសេសមួយចំនួនដែលជនត្រូវចោទពុំមានលទ្ធភាពក្នុងការស្វែងរកមេធាវី។ បន្ទាប់ពីបានទទួលដំណឹងអំពីសិទ្ធិជ្រើសរើសមេធាវី និងសិទ្ធិស្នើសុំមេធាវី នោះមេធាវីនឹងត្រូវចាត់តាំងដោយតុលាការ។ ក្នុងករណីដែលជនត្រូវចោទជាអនីតិជននៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ នោះអនីតិជនត្រូវតែមានមេធាវីអមជានិច្ច។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ មេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលមានចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី[100]។

### ឃ. សិទ្ធិប្តឹងជំទាស់

**ការប្តឹងជំទាស់** គឺជាសិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងបដិសេធវត្តមានរបស់ចៅក្រមអាសនៈ **(អាចជាចៅក្រមស៊ើបសួរ ឬ ចៅក្រមជំនុំជម្រះ)** ដោយពុំអនុញ្ញាតឱ្យគាត់ទទួលបន្ទុករឿងក្តីណាមួយ។

បណ្តឹងជំទាស់ អាចត្រូវទទួលបានពាក់ព័ន្ធតែចៅក្រមអាសនៈប៉ុណ្ណោះ។

ចៅក្រមទាំងឡាយ អាចត្រូវប្តឹងជំទាស់ដោយមូលហេតុដូចខាងក្រមនេះ៖

- កាលណាចៅក្រម ឬសហព័ទ្ធរបស់ចៅក្រម ឬអតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្តី។
- កាលណាចៅក្រមជាញាតិលោហិតរហូតដល់ថ្នាក់ទី៦ ឬញាតិពន្ធរហូតដល់ថ្នាក់ទី៣ ឬអតីតញាតិពន្ធរហូតដល់ថ្នាក់ទី៣ របស់ភាគីណាមួយ។
- កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ។
- កាលណាចៅក្រមដែលទទួលបន្ទុករឿងក្តីធ្លាប់ ឬ កំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ។
- កាលណាចៅក្រមបានធ្វើជាសាក្សី ឬ អ្នកជំនាញក្នុងរឿងក្តី។
- កាលណាចៅក្រមជា ឬ ធ្លាប់ជាអ្នកតំណាង ឬ ជាអ្នកជំនួយឱ្យភាគីចំពោះរឿងក្តី ឬ

[100] មាត្រា១៤៣ កថាខណ្ឌទី៤, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

- កាលណាចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្តីក្នុងនាមជាមជ្ឈត្តករចំពោះរឿងក្តី ឬបានចូលរួមក្នុងការសម្រេចសេចក្តីនៅសាលាដំបូងដែលបានប្តឹងឧបាស្រ័យ ឬការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ដែលបានឧបាស្រ័យ ឬ បង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ចំពោះរឿងក្តី។

ការកំណត់បែបនេះ គឺក្នុងគោលបំណងជាការការពារសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះក្តីរបស់ខ្លួនប្រកបដោយយុត្តិធម៌។ ចៅក្រមអាចធ្វើការស្វែងរកយុត្តិធម៌បាន លុះត្រាណាតែគាត់អាចជៀសវាងនូវ **អគតិទាំង៤**(ឆន្ទាគតិ, ទោសាគតិ, មោហាគតិ, ភយាគតិ) និងធានារក្សាឱ្យបាន **សុគតិធម៌ទាំង៥** (វិរិយសម្បយុត្ត, សុចរិតយុត្តិធម៌, បញ្ញត្តិគារវោ, សមទណ្ឌោ, បញ្ញាវុធវិនិច្ឆ័យ)។

ជនត្រូវចោទដែលចង់ប្តឹងជិតចិត្តចៅក្រមអាសនៈណាមួយត្រូវជូនពាក្យប្តឹងតាំងពីពេលដែលខ្លួនបានដឹងពីមូលហេតុនៃការប្តឹងជិតចិត្ត បើពុំដូច្នេះទេមិនអាចទទួលបានឡើយ។ ប៉ុន្តែនៅក្រោយពេលបិទការពិភាក្សាដេញដោលពាក្យប្តឹងជិតចិត្តចៅក្រមមិនអាចធ្វើបានឡើយ[101]។

### ង. សិទ្ធិទទួលដំណឹងពីការបិទបញ្ចប់សំណុំរឿង

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់ចៅក្រមស៊ើបសួរជូនព័ត៌មាននេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី[102]។ ហើយនៅក្នុងរយៈពេល ២(ពីរ)ថ្ងៃបន្ទាប់ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀតនោះ ព្រះរាជអាជ្ញាត្រូវធ្វើការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញាតាមមាត្រា ១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[103]។

ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវឃុំខ្លួន និង ១(មួយ)ខែ ក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផង។ ចិរវេលានេះត្រូវគិតពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿង។

ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែលថា ការស៊ើបសួរត្រូវបញ្ចប់នោះ ព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬ ក៏លើកលែងចោទប្រកាន់។

[101] មាត្រា៥៥៧, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[102] មាត្រា២៤៦ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[103] មាត្រា១៣២, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

### ច. សិទ្ធិទទួលបានដំណឹងពីដីកាដំណោះស្រាយ

បន្ទាប់ពីការជូនព័ត៌មានអំពីការបិទការស៊ើបសួរ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែលថាការស៊ើបសួរត្រូវបញ្ចប់នោះ ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ នៅក្នុងសេចក្តីសន្និដ្ឋានស្ថាពរនេះ ព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទទៅតុលាការជំនុំជម្រះ ឬ ក៏លើកលែងចោទប្រកាន់។

ក្រោយពីធ្វើដីកាសន្និដ្ឋានស្ថាពររួច ព្រះរាជអាជ្ញាត្រូវបញ្ជូនដីកានោះដោយភ្ជាប់ជាមួយសំណុំរឿងទៅកាន់ចៅក្រមស៊ើបសួរ។ បន្ទាប់ពីបានទទួលដីកាសន្និដ្ឋានស្ថាពររួច ចៅក្រមស៊ើបសួរត្រូវធ្វើដីកាដំណោះស្រាយហើយដីកានេះអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងការចោទប្រកាន់[104]។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយការធ្វើដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ[105]។

ក្រោយពីធ្វើដីកាដំណោះស្រាយរួច ដីកានោះត្រូវជូនដំណឹងដល់ជនត្រូវចោទក្នុងរយៈពេលខ្លីបំផុត។ ចំពោះរយៈពេលដ៏ខ្លីនេះច្បាប់មិនបានកំណត់ជាក់លាក់នោះទេ ប៉ុន្តែចៅក្រមត្រូវគិតគូពីរយៈពេលដែលសមរម្យ។

### ឆ. សិទ្ធិស្នើសុំឱ្យបិទសំណុំរឿង

នៅពេលផុតចិរវេលា ១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចោទប្រកាន់ ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរបិទការស៊ើបសួរ។ ក្នុងរយៈពេល ១(មួយ)ខែ គិតចាប់ពីថ្ងៃទទួលពាក្យសុំនេះ ចៅក្រមស៊ើបសួរត្រូវតែសម្រេច។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចនៅក្នុងរយៈពេលនេះទេ ជនត្រូវចោទអាចប្តឹងទៅប្រធានសភាស៊ើបសួរដែលធ្វើអធិបញ្ជាដល់ចៅក្រមស៊ើបសួរឱ្យសម្រេច។ នេះជាសិទ្ធិមួយដែលផ្តល់ដោយក្រមនីតិវិធីព្រហ្មទណ្ឌដល់ជនត្រូវចោទ ដើម្បីជៀសវាងការខ្ជីខ្ជារបស់ចៅក្រមស៊ើបសួរដែលអាចកើតមានឡើង។

អំណាចដែលទទួលស្គាល់អំពីការប្តឹងសុំបិទសំណុំរឿងដល់ជនត្រូវចោទនេះ អាចត្រូវបានប្រើប្រាស់ដោយមេធាវីរបស់ជនត្រូវចោទ[106]។

---

[104] មាត្រា២៤៧ កថាខណ្ឌទី១, ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៣។

[105] មាត្រា២៤៧ កថាខណ្ឌទី៤, ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៣។

[106] មាត្រា២៨៦ កថាខណ្ឌទី៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

# ជំពូកទី២

# ការអនុវត្តជាក់ស្តែង

# និង

# ការប្រៀបធៀបជាមួយនឹងទ្រឹស្តីគតិយុត្ត

# ជំពូកទី២
# ការអនុវត្តជាក់ស្តែង និង ការប្រៀបធៀបជាមួយនឹងទ្រឹស្តីគតិយុត្ត

## ២.១ ការអនុវត្តជាក់ស្តែង

### ២.១.១ ការដាក់ឱ្យស្ថិតក្រោមការពិនិត្យ

នៅក្នុងការអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តកណ្តាល នៅពេលដែលជនត្រូវចោទបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរតាមដីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញារក្លាម ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនសង្ស័យ ហើយចៅក្រមស៊ើបសួរដាក់ជនដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឱ្យស្ថិតក្រោមការពិនិត្យនូវបទល្មើសដែលតំណាងអយ្យការបានចោទប្រកាន់នោះ តាមរយៈការជូនដំណឹងឱ្យដឹងពីរឿងរ៉ាវដែលបានចោទប្រកាន់ និងប្រាប់ពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់ព្រមទាំងសិទ្ធិផ្សេងៗមួយចំនួនទៀត។

ជាក់ស្តែងនៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ៖ ០៦៩ អក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ តំណាងអយ្យការបានធ្វើការចោទប្រកាន់ជនសង្ស័យ ០១នាក់ ពីបទ៖ ហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោសដោយសារមរណៈភាពនៃជនរងគ្រោះ) តាមបញ្ញត្តិមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ[107]។ ក្នុងសំណុំរឿងនោះ នៅពេលដែលសំណុំរឿងនោះបានចូលមកដល់ចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរបានបង្គាប់ឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង[108] ដោយក្នុងនោះឃើញថា ចៅក្រមស៊ើបសួរបានជូនដំណឹងនូវចំណុចមួយចំនួនដូចខាងក្រោម៖

- ប្រាប់ជននោះឱ្យបានដឹងពីរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលបានបណ្តឹង។
- សិទ្ធិក្នុងការជ្រើសរើសមេធាវី ឬសិទ្ធិក្នុងការសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួន។
- ប្រាប់ជនត្រូវចោទថា នៅថ្ងៃនេះយើងសម្រេចឃុំខ្លួនគាត់បណ្តោះអាសន្ន។
- ជូនដំណឹងដល់ជនត្រូវចោទ អំពីការដាក់ជននោះស្ថិតក្រោមការពិនិត្យ។

ក្នុងការបង្ហាញខ្លួនលើក ដំបូងចៅក្រមស៊ើបសួរបង្គាប់ឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុបង្ហាញខ្លួនលើកដំបូងដែលកំណត់ហេតុនោះ ក្រឡាបញ្ជីកត់ត្រានូវចំណុចសំខាន់ៗដែលចៅក្រមស៊ើបសួរជូនដំណឹងទៅជនត្រូវចោទនោះ។

[107] ឧបសម្ព័ន្ធទី៣ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ០៣៨ ដស.សស ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល។

[108] ឧបសម្ព័ន្ធទី៦ កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ សំណុំរឿងស៊ើបសួរលេខ៖ ០៣២ សស ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

### ២.១.២ កិច្ចពិភាក្សាដេញដោលចំពោះការឃុំខ្លួនបណ្ដោះអាសន្ន

អ្វីដែលគួរកត់សម្គាល់នោះចំពោះការអនុវត្តជាក់ស្ដែង គឺថាការធ្វើកិច្ចសន្យាពិភាក្សាដេញដោលចំពោះការឃុំខ្លួនបណ្ដោះអាសន្ននោះ មិនឃើញវត្តមានរបស់តំណាងអយ្យការចូលរួមក្នុងនីតិវិធីដេញដោលនោះទេ។ ក្នុងករណីនេះ យើងឃើញថា ព្រះរាជអាជ្ញាគ្រាន់តែស្នើសុំឱ្យឃុំខ្លួនបណ្ដោះអាសន្នតាមរយៈដីកាសន្និដ្ឋានសុំឱ្យឃុំខ្លួនបណ្ដោះអាសន្នប៉ុណ្ណោះ[109]។ ក្នុងន័យនេះ នៅក្នុងនីតិវិធីនៃការដេញដោលចំពោះមុខត្រូវបានធ្វើឡើងរវាងតែចៅក្រមស៊ើបសួរ និងជនត្រូវចោទ ឬមេធាវី ក្នុងករណីជនត្រូវចោទមានមេធាវីការពារសិទ្ធិ ព្រមទាំងក្រឡាបញ្ជីដែលជាអ្នកធ្វើកំណត់ហេតុតែប៉ុណ្ណោះ។ មិនតែប៉ុណ្ណោះ នៅក្នុងនីតិវិធីនេះចៅក្រមស៊ើបសួរមិនបានធ្វើការដេញដោលអ្វីនោះទេ ពោលគឺចៅក្រមស៊ើបសួរគ្រាន់តែធ្វើការបំពេញនូវទម្រង់បែបបទដែលមានស្រាប់តែប៉ុណ្ណោះ។

ជាក់ស្ដែងនៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខៈ ០៦៩ អក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ នៅក្នុងកំណត់ហេតុស្ដីពីការពិភាក្សាដេញដោលចំពោះមុខ[110] បង្ហាញឱ្យឃើញថា ការធ្វើពិជាក្សាដេញដោលចំពោះការឃុំខ្លួននេះ ចៅក្រមស៊ើបសួរបានធ្វើកិច្ចនេះដោយគ្រាន់តែបំពេញនូវទម្រង់ដែលមានស្រាប់តែប៉ុណ្ណោះ ពោលគឺមិនបានធ្វើការដេញដោលដោយឱ្យមានការអះអាងពីភាពចាំបាច់ ឬមិនចាំបាច់នៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះជនត្រូវចោទនោះទេ។ ក្នុងករណីនេះបង្ហាញយ៉ាងច្បាស់ថា នៅក្នុងការអានុវត្តជាក់ស្ដែងការសម្រេចឃុំខ្លួនជនត្រូវចោទណាម្នាក់ ចៅក្រមស៊ើបសួរមិនបានធ្វើការដេញដោលពីភាពចាំបាច់នៃការឃុំខ្លួនបណ្ដោះអាសន្ននោះទេ។ នៅក្នុងនីតិវិធីនៃការសួរដេញដោលនោះទៀតសោត ក្រឡាបញ្ជីបានចុះក្នុងកំណត់ហេតុស្ដីពីការពិភ្សាដេញដោលចំពោះមុខ ដែលមានផ្ដិតមេដៃដោយជនត្រូវចោទ ហត្ថលេខាដោយមេធាវីការពារសិទ្ធឱ្យជនត្រូវចោទ។

### ២.១.៣ ការសម្រេចឃុំខ្លួនបណ្ដោះអាសន្ន

ក្រោយពីចៅក្រមស៊ើបសួរជូនដំណឹងដល់ជនត្រូវចោទឱ្យបានដឹងពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទល្មើសណាមួយហើយនោះ កិច្ចដែលចៅក្រមស៊ើបសួរត្រូវធ្វើជាបន្តទៀតនោះ គឺការសម្រេចថា តើគួរតែឃុំជនត្រូវចោទជាបណ្ដោះអាសន្ន ឬ មួយក៏ត្រូវឱ្យជននោះមានសេរីភាពដោយមិនធ្វើការឃុំខ្លួនបណ្ដោះអាសន្ន។ ដូចដែលបានដឹងហើយថា នៅក្នុងការអនុវត្តជាក់ស្ដែង ការពិភាក្សាដេញដោលចំពោះការឃុំខ្លួនបណ្ដោះអាសន្ននោះ គឺមិនបានធ្វើការដេញដោលចំពោះមុខ ដោយមានការចូលរួមពីតំណាងអយ្យការនោះទេ ដូចនេះទាក់ទង

---

[109] ឧបសម្ព័ន្ធទី៤ ដីកាសន្និដ្ឋានសុំឱ្យឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

[110] ឧបសម្ព័ន្ធទី៧ កំណត់ហេតុស្ដីពីការពិភាក្សាដេញដោលចំពោះមុខ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ក្នុងសំណុំរឿងស៊ើបសួរលេខៈ ០៣២ សស ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

នឹងការសម្រេចពីការឃុំខ្លួន ឬមិនឃុំខ្លួនបណ្ដោះអាសន្ននោះ វាអាស្រ័យទៅលើថាតើតំណាងអយ្យការបានធ្វើការស្នើសុំឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន ឬទេ។

ដីកាសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្នត្រូវបានព្រាងឡើងដោយក្រឡាបញ្ជីរបស់ចៅក្រមស៊ើបសួរដែលទទួលបន្ទុកលើសំណុំរឿងមួយនោះ ហើយក្រឡាបញ្ជីយកដីកាសម្រេចដែលខ្លួនបានព្រាងនោះទៅឱ្យចៅក្រមស៊ើបសួរដើម្បីធ្វើការពិនិត្យ និងចុះហត្ថលេខាលើសេចក្ដីសម្រេចនោះ។

មួយវិញទៀត នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ននោះយើងសង្កេតឃើញថា ក្នុងការសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ននោះ ចៅក្រមស៊ើបសួរបានចេញសេចក្ដីសម្រេចមួយដែលមានសំអាងហេតុត្រឹមត្រូវ ដោយក្នុងសំអាងហេតុនោះ ចៅក្រមស៊ើបសួរបានលើកឡើងនូវទឡ្ហីករណ៍មួយចំនួនដែលជាលក្ខខណ្ឌដែលអាចឃុំខ្លួនជនត្រូវចោទនោះបានតាមមាត្រា**២០៤** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ព្រមទាំងមូលហេតុផ្សេងៗដែលមាននៅក្នុងមាត្រា**២០៥** នៃក្រមនីតិវិធីព្រហ្មទណ្ឌផងដែរ។ ជាក់ស្ដែងនៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ៖ **០៦៩ អក** ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ចៅក្រមស៊ើបសួរបានសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្នតាមដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន[111] លេខ៖ **១១២(ន)** ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។ នៅក្នុងជំពូកសំអាងហេតុនៃសេចក្ដីសម្រេចនៃដីកាសម្រេចនោះ ចៅក្រមស៊ើបសួរបានធ្វើសំអាងហេតុដូចខាងក្រោម៖

- ជនត្រូវចោទបានចោទពីបទមជ្ឈិមដែលច្បាប់កំណត់ដាក់ពន្ធនាគារស្មើ ឬលើសពី០១(មួយ)ឆ្នាំ។
- តាមចម្លើយសារភាពរបស់ជនត្រូវចោទឈ្មោះ....... បានឆ្លើយសារភាពចំពោះអង្គហេតុដែលតំណាងអយ្យការចោទប្រកាន់ពីបទ៖ **ហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោសដោយសារមរណៈភាពនៃជនរងគ្រោះ)**
- យល់ឃើញថា សេចក្ដីសន្និដ្ឋានស្នើសុំឱ្យឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្នរបស់តំណាងអយ្យការមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីតុលាការពិនិត្យពិចារណាចំពោះការប្ដឹងសុំនេះ។
- យល់ឃើញថា ចំពោះការកត់សម្គាល់របស់ជនត្រូវចោទ ដែលយល់ព្រមឱ្យតុលាការឃុំខ្លួនបណ្ដោះអាសន្នមានលក្ខណៈសមហេតុផល។
- យល់ឃើញថា ដើម្បីធានាដល់ការស៊ើបសួរឱ្យបានល្អក្នុងការប្រមូលភស្តុតាង ដើម្បីបញ្ចប់ និងបង្ការកុំឱ្យកើតមានបទល្មើសថ្មីទៀត និងដើម្បីរក្សាសណ្ដាប់ធ្នាប់សាធារណៈ និង ដើម្បីកុំឱ្យមានការច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស ព្រមទាំងធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិ

[111] ឧបសម្ព័ន្ធទី៨ ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នលេខ៖១១២(ន) ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ នៃសំណុំរឿងស៊ើបសួរលេខ៖ ០៣២ សស ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

វិធី គប្បីតុលាការសម្រេចឃុំខ្លួនជនត្រូវចោទឈ្មោះ............ ជាបណ្ដោះអាសន្នដោយសារមិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយដែលមានលក្ខណៈតឹងរឹង និង អាចធានាឱ្យមានការបំពេញប្រកបដោយប្រសិទ្ធិភាពចំពោះស្ថានភាពតម្រូវទាំងនេះ ហើយមានតែការឃុំខ្លួនដែលជាមធ្យោបាយមួយគត់ ដើម្បីសម្រេចគោលដៅនេះ។[112]

### ២.១.៤ ការបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន

នៅក្នុងការអនុវត្តជាក់ស្ដែង ក្នុងករណីចៅក្រមសម្រេចថា ត្រូវឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្នក្រោយពីចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នហើយ ចៅក្រមស៊ើបសួរចេញនូវដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នផងដែរ។ ក្នុងករណីនេះ តុលាការត្រូវចេញដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នមួយផ្សេងទៀតពីដីសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ពីព្រោះថាលុះត្រាតែមានដីកាបង្គាប់ឱ្យឃុំខ្លួនទើបពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនទទួល និងឃុំខ្លួនជនត្រូវចោទនោះ។

នៅក្នុងដីកាបង្គាប់ឱ្យឃុំខ្លួន ចៅក្រមស៊ើបសួរបានចុះនូវព័ត៌មានសំខាន់ៗដែលច្បាប់បានកំណត់ផងដែរដូចជា៖ អត្តសញ្ញាណជនត្រូវចោទ ប្រភេទបទល្មើសដែលចោទប្រកាន់ កាលបរិច្ឆេទ ទីកន្លែង និងកាលបរិច្ឆេទប្រព្រឹត្តបទល្មើស ព្រមទាំងឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកានោះ។ លើសពីនេះ នៅក្នុងដីកាបង្គាប់នោះក៏មានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផងដែរ។ ជាក់ស្ដែងនៅក្នុងដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នលេខ៖ **១២៣(ន)**[113] ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ នៃសំណុំរឿងព្រហ្មទណ្ឌលេខ៖ **០៦៩ អក** ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ដដែលនោះ ចៅក្រមស៊ើបសួរបានចុះនូវនិទ្ទេសសំខាន់មួយចំនួនដូចជា៖

- អត្តសញ្ញាណជនត្រូវចោទ ដោយបានសរសេរពីឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត សញ្ជាតិ សាសនា ទីកន្លែងកំណើត ទីលំនៅបច្ចុប្បន្ន កម្រិតវប្បធម៌ ស្ថានភាពគ្រួសារ មុខរបរ ឈ្មោះឪពុកម្ដាយ និងប្រវត្តិនៃការផ្ដន្ទាទោសជាដើម។
- ប្រភេទបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសដោយបានសរសេរថា "*ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ពីបទលួចមានស្ថានទម្ងន់ទោសដោយសារ*

[112] ឧបសម្ព័ន្ធទី៩ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៖ ១២២(ន) ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ នៃសំណុំរឿងស៊ើបសួរលេខ៖ ០៣២ សស ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

[113] ឧបសម្ព័ន្ធទី៩ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៖ ១២២(ន) ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ នៃសំណុំរឿងស៊ើបសួរលេខ៖ ០៣២ សស ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

*ការកាប់គាស់ទម្លុះទម្លាយ ប្រព្រឹត្តនៅភូមិព្រែកតាប្រែង ឃុំព្រែកនរិន្ទ ស្រុកឯកភ្នំ ខេត្តកណ្តាល កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងតាមមាត្រា ៣៥៣ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។"*

- ចំណែកឯត្រង់ចំណុចឈ្មោះ និងឋានៈរបស់ចៅក្រមដែលបានចេញដីកាត្រូវបានសរសេរថាចៅក្រមស៊ើបសួរ។

## ២.២ ការវិភាគប្រៀបធៀបជាមួយនឹងទ្រឹស្តីគតិយុត្ត

ឆ្លងតាមការសិក្សាទៅលើជំពូកទ្រឹស្តីគតិយុត្ត នៃការឃុំខ្លួនបណ្តោះអាសន្នក្នុងដំណាក់កាលស៊ើបសួរ ព្រមទាំងការសិក្សាលើការអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តកណ្តាលរួចមក យើងសង្កេតឃើញថា នៅក្នុងការអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តកណ្តាល ដំណើរការនីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងរឿងក្តីព្រហ្មទណ្ឌ តុលាការបានអនុវត្តស្ទើរតែទាំងស្រុងស្របតាមបទប្បញ្ញត្តិដែលក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់។

តែទោះបីជាយ៉ាងណា យើងក៏សង្កេតឃើញនូវចំណុចមួយចំនួនដែលតុលាការអនុវត្តមិនបានពេញលេញស្របតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌដែរ។ ក្នុងករណីនេះ យើងសង្កេតឃើញថាចំណុចដែលតុលាការអនុវត្តមិនបានពេញលេញនោះ គឺអនុវត្តទៅលើគ្រប់រឿងក្តីទាំងអស់។

ដូចនេះ យើងនឹងធ្វើការពិនិត្យទៅលើចំណុចមួយចំនួនតាមលំហូរនៃនីតិវិធីដើម្បីឱ្យដឹងថា តើចំណុចណាខ្លះដែលតុលាការអនុវត្តបានពេញលេញ និងថាតើចំណុចណាខ្លះដែលតុលាការអនុវត្តមិនទាន់បានពេញលេញស្របតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ២.២.១ ចំណុចដែលតុលាការអនុវត្តបានពេញលេញ

#### ២.២.១.១ ការដាក់ឱ្យស្ថិតក្រោមការពិនិត្យ

ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ គឺជាចំណុចមួយដែលយើងរកឃើញថា ការអនុវត្តជាក់ស្តែងតុលាការបានអនុវត្តបានត្រឹមត្រូវស្របតាមការកំណត់របស់ច្បាប់។ ក្នុងករណីនេះ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ឱ្យចៅក្រមស៊ើបសួរត្រូវតែដាក់ជនដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលតំណាងអយ្យការបានធ្វើការចោទប្រកាន់។ បើយើងក្រឡេកទៅមើលលើការអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តកណ្តាលវិញ ក្រោយពីចៅក្រមស៊ើបសួរទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលតំណាងអយ្យការបានធ្វើការចោទប្រកាន់មកហើយ ចៅក្រមស៊ើបសួរតែងតែដាក់បុគ្គលដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះឱ្យស្ថិតក្រោមការពិនិត្យជានិច្ច។

មួយវិញទៀត អ្វីដែលយើងរកឃើញថា ការអនុវត្តជាក់ស្តែងចៅក្រមស៊ើបសួរអនុវត្តបានត្រឹមត្រូវតាមការកំណត់របស់ច្បាប់នោះ គឺនៅពេលចូលបង្ហាញខ្លួនលើកដំបូងរបស់ជនត្រូវចោទនៅចំពោះមុខចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរបានពិនិត្យអត្តសញ្ញាណជនត្រូវចោទ ប្រាប់ជននេះឱ្យបានដឹងពីរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះនៃបទល្មើសដែលកំណត់ដោយច្បាប់។ លើសពីនេះចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថាខ្លួនអាចឆ្លើយ ឬមិនឆ្លើយបានដោយសេរី។ ចៅក្រមស៊ើបសួរបានប្រាប់ជនត្រូវចោទឱ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួនដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

**២.២.១.២ ការសម្រេចឃុំខ្លួនបណ្តោះអាសន្ន**

ការសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន ក៏ជាចំណុចមួយដែលចៅក្រមស៊ើបសួរអនុវត្តបានយ៉ាងត្រឹមត្រូវតាមការកំណត់របស់ច្បាប់ផងដែរ មុននឹងការសម្រេចឃុំខ្លួនជនត្រូវចោទ ចៅក្រមស៊ើបសួរពិនិត្យយ៉ាងហ្មត់ចត់ នូវមូលហេតុនៃការឃុំខ្លួន លក្ខខណ្ឌនៃការឃុំខ្លួន និងថាតើមានការស្នើសុំពីតំណាងអយ្យការ ឬទេ។ ក្នុងនោះយើងសង្កេតឃើញថា នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានតម្រូវឱ្យតុលាការចេញនូវដីកាពីរ បើកាលណាតុលាការសម្រេចឃុំខ្លួនជនត្រូវចោទនោះ ពោលគឺ តុលាការត្រូវចេញដីកាសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន និងដីបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន។ ជាក់ស្តែងនៅក្នុងការអនុវត្តជាក់ស្តែងនៅក្នុងសាលាដំបូងខេត្តកណ្តាលវិញ ក្រោយពីតុលាការបានធ្វើនីតិវិធីនៃការដេញដោលចំពោះមុខហើយ តុលាការយល់ឃើញថាត្រូវឃុំខ្លួនជនត្រូវចោទ តុលាការបានចេញដីកាពីរប្រភេទ គឺដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន។

លើសពីនេះទៅទៀត យើងសង្កេតឃើញថានៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌពុំបានកំណត់ជាក់លាក់នូវទម្រង់នៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននោះទេ ក៏ប៉ុន្តែក្រសួងយុត្តិធម៌បានចេញលិខិតលេខ៖ **១២០ កយ.រប/១៤** ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់រូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងលិខិតលេខ៖ **២៩៥** ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការសុំកែសម្រួលលិខិតលេខ៖ **១២០ កយ.រប/១៤** ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ហើយការអនុវត្តជាក់ស្តែងវិញនៅសាលាដំបូងខេត្តកណ្តាលបានអនុវត្តដូចគ្នាស្ទើរតែទាំងស្រុងតាមការណែនាំនោះ។

**២.២.១.៣ ការបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន**

នៅក្នុងការអនុវត្តជាក់ស្តែង ក្នុងករណីចៅក្រមសម្រេចថា ត្រូវឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ក្រោយពីចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នហើយ ចៅក្រមស៊ើបសួរចេញនូវដីកាបង្គាប់ឱ្យឃុំខ្លួន

បណ្ដោះអាសន្នផងដែរ ព្រោះថាលុះត្រាតែមានដីកាបង្គាប់ឱ្យឃុំខ្លួនទើបពន្ធនាគារ ឬមណ្ឌលឃុំខ្លួនទទួល និងឃុំខ្លួនជនត្រូវចោទនោះ។

នៅក្នុងដីកាបង្គាប់ឱ្យឃុំខ្លួន ចៅក្រមស៊ើបសួរបានចុះនូវព័ត៌មានសំខាន់ៗដែលច្បាប់បានកំណត់ផងដែរដូចជា៖ អត្តសញ្ញាណជនត្រូវចោទ ប្រភេទបទល្មើសដែលចោទប្រកាន់ កាលបរិច្ឆេទ ទីកន្លែង និងកាលបរិច្ឆេទប្រព្រឹត្តបទល្មើស ព្រមទាំងឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកានោះ។ លើសពីនេះ នៅក្នុងដីកាបង្គាប់នោះក៏មានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផងដែរ។ ជាក់ស្ដែងនៅក្នុងដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នលេខ៖ **១២៣(ន)**[114] ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ នៃសំណុំរឿងព្រហ្មទណ្ឌលេខ៖ **០៦៩ អក** ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ដដែលនោះ ចៅក្រមស៊ើបសួរបានចុះនូវនិទ្ទេសសំខាន់មួយចំនួនដូចជា៖

- អត្តសញ្ញាណជនត្រូវចោទ ដោយបានសរសេរពីឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត សញ្ជាតិ សាសនា ទីកន្លែងកំណើត ទីលំនៅបច្ចុប្បន្ន កម្រិតវប្បធម៌ ស្ថានភាពគ្រួសារ មុខរបរ ឈ្មោះឪពុកម្ដាយ និងប្រវត្តិនៃការផ្ដន្ទាទោសជាដើម។
- ប្រភេទបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសដោយបានសរសេរថា *"ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ពីបទលួចមានស្ថានទម្ងន់ទោសដោយសារការកាប់គាស់ទម្លុះទម្លាយ ប្រព្រឹត្តនៅភូមិព្រែកតាច្រែង ឃុំព្រែកនរិន្ទ ស្រុកឯកភ្នំ ខេត្តកណ្ដាល កាលពីថ្ងៃ ទី២០ ខែកញ្ញា ឆ្នាំ២០២១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងតាមមាត្រា ៣៥៣ និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។"*
- ចំណែកឯត្រង់ចំណុចឈ្មោះ និងឋានៈរបស់ចៅក្រមដែលបានចេញដីកាត្រូវបានសរសេរថាចៅក្រមស៊ើបសួរ។

ដែលចំណុចទាំងនេះ សាលាដំបូងខេត្តកណ្ដាលបានអនុវត្តពេញលេញតាមច្បាប់កំណត់ផងដែរ។

### ២.២.២ ចំណុចដែលតុលាការអនុវត្តមិនបានពេញលេញ

ក្រៅពីចំណុចដែលតុលាការអនុវត្តបានពេញលេញស្របតាមបញ្ញត្តិដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលយើងបានរកឃើញតាមការប្រៀបធៀបរវាងការអនុវត្តជាក់ស្ដែង ទៅនឹងទ្រឹស្ដីគតិយុត្តទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ននៅដំណាក់កាលស៊ើបសួរ យើងក៏បានរកឃើញនូវចំណុចដែលតុលាការអនុវត្ត

[114] ឧបសម្ព័ន្ធទី៩ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៖ ១២២(ន) ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ នៃសំណុំរឿងស៊ើបសួរលេខ៖ ០៣២ សស ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

មិនបានពេញលេញមួយចំនួនផងដែរ។ ក្នុងនោះយើងរកឃើញថា តុលាការអនុវត្តមិនបានពេញលេញស្រប តាមការកំណត់របស់ច្បាប់ទៅលើចំណុចនៃការដេញដោលចំពោះការឃុំខ្លួនបណ្ដោះអាសន្ន។

ការដេញដោលចំពោះការឃុំខ្លួនបណ្ដោះអាសន្នជាចំណុចមួយដែលយើងសង្កេតឃើញថា ការអនុវត្ត នៅសាលាដំបូងខេត្តកណ្ដាលធ្វើមិនទាន់ពេញលេញស្របតាមសេចក្ដីណែនាំរបស់ក្រសួងយុត្តិធម៌នោះទេ។ ដោយផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានបញ្ជាក់ច្បាស់ទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន តម្រូវឱ្យ តុលាការធ្វើនីតិវិធីដេញដោលមួយ ដោយផ្ដល់ឱកាសឱ្យជនត្រូវចោទ ឬមេធាវីលើកឡើងពីទឡ្ហីករណ៍ ទាំងឡាយដែលគាំទ្រដល់នត្ថិភាពនៃមូលហេតុ និងភាពមិនចាំបាច់នៃការឃុំខ្លួនបណ្ដោះអាសន្ននោះទេ។ ដូច្នេះ បើផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌសាលាដំបូងខេត្តកណ្ដាល មិនបានធ្វើខុសនីតិវិធីនោះទេ ក៏ប៉ុន្តែបើផ្អែកតាម លិខិតណែនាំលេខ៖ ១២០ កយ.រប/១៤ របស់ក្រសួងយុត្តិធម៌ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ស្ដីពីការដាក់ឱ្យ ប្រើប្រាស់រូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន នោះសាលាដំបូងខេត្តកណ្ដាលបានអនុវត្តប្រាសចាកពី លិខិតណែនាំនោះប្រាកដមែន ពោលគឺតុលាការបានធ្វើនីតិវិធីនៃការឃុំខ្លួនបណ្ដោះអាសន្នក៏ពិតមែន ក៏ប៉ុន្តែការ ដេញដោលអំពីការឃុំខ្លួននោះ ចៅក្រមស៊ើបសួរមិនបានធ្វើនីតិវិធីមួយ ដែលមានការចូលរួមពីតំណាងអយ្យការ នោះទេ ដែលជាហេតុនាំឱ្យគ្មានការដេញដោលពីមូលហេតុ និងភាពចាំបាច់នៃការឃុំខ្លួននោះទេ។

មួយវិញទៀតទាក់ទងនឹងការដេញដោលពីការឃុំខ្លួនបណ្ដោះអាសន្ននេះទៀតសោត យើងឃើញថា ចៅក្រម ស៊ើបសួរមិនត្រឹមតែមិនបានធ្វើការដេញដោលចំពោះការឃុំខ្លួនបណ្ដោះអាសន្ននោះទេ ផ្ទុយទៅវិញ ដោយផ្អែកតាមលិខិតណែនាំលេខ១២០ កយ.រប/១៤ របស់ក្រសួងយុត្តិធម៌ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ ២០១៤ ស្ដីពីការដាក់ឱ្យប្រើប្រាស់រូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរត្រូវសាកសួរនូវព័ត៌មាន មួយចំនួនទាក់ទងទៅនឹងស្ថានភាពរស់នៅរបស់ជនត្រូវចោទ ដើម្បីជាមូលដ្ឋានក្នុងការសម្រេចឃុំខ្លួន ឬមិនឃុំ ខ្លួន ដូចជាជនត្រូវចោទជាអនីតិជនជាស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូចៗនៅ ជាមួយដោយគ្មានអ្នកណាផ្សេង ទៀតជួយមើលថែរក្សាកូនតូចៗទាំងនោះ ឬជនត្រូវចោទជាចាស់ជរា ។ ក៏ប៉ុន្តែនៅក្នុងការអនុវត្តវិញ យើងដឹង ហើយថាចៅក្រមស៊ើបសួរមិនបានធ្វើការដេញដោលពីការឃុំខ្លួនបណ្ដោះ អាសន្ននោះទេ ហើយការឃុំខ្លួនប ណ្ដោះអាសន្ន គឺផ្អែកទៅលើការយល់ឃើញរបស់ចៅក្រមស៊ើបសួរ ដូចនេះ ការសួរពីព័ត៌មានមួយចំនួនទាក់ទង ទៅនឹងចំណុចខាងលើនោះក៏ចៅក្រមមិនបានធ្វើនោះទេ ។ តែក្នុងករណីនេះយើងសង្កេតឃើញថា ចៅក្រមស៊ើប សួរបានបង្គាប់ឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុដេញដោលចំពោះមុខ ។

# សេចក្តីសន្និដ្ឋាន

ដូចយើងបានដឹងហើយថា នៅក្នុងដំណើរការនៃនិតិវិធីព្រហ្មទណ្ឌមានដំណាក់កាលផ្សេងៗពីគ្នាជាច្រើនដូចជា៖ ដំណាក់មន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ ដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់កាលនៃការជំនុំជម្រះ។ នៅក្នុងការសិក្សានៃអត្ថបទសារណានេះ យើងធ្វើការសិក្សានៅក្នុងដំណាក់កាលនៃចៅក្រមស៊ើបសួរហើយជ្រើសយកតែផ្នែកតូចមួយនៃដំណាក់របស់ចៅក្រមស៊ើបសួរនេះតែប៉ុណ្ណោះគឺ **ការឃុំខ្លួនបណ្តោះ អាសន្ននៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ។**

ឆ្លងតាមការបកស្រាយខាងលើ ក៏ដូចជាអត្ថន័យនៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ រួចមក យើងអាចធ្វើសេចក្តីសន្និដ្ឋានបានថាការស្វែងយល់ពីនីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន គឺមានភាពចាំបាច់ណាស់ក្នុងនាមជាចៅក្រមស៊ើបសួរពីព្រោះថាការឃុំខ្លួនបណ្តោះអាសន្ន គឺជាការដកហូតនូវសិទ្ធិសេរីភាពរបស់បុគ្គលដែលវាមានភាពប៉ះពាល់យ៉ាងខ្លាំងនូវគោលការណ៍ជាអន្តរជាតិពោលគឺគោលការណ៍សន្មតជាមុនថាគ្មានទោស។ តាមរយៈគោលការណ៍នេះបុគ្គលម្នាក់ត្រូវបានសន្មតទុកជាមុនថាគ្មានទោស ដរាបណាបុគ្គលនោះមិនទាន់ត្រូវបានតុលាការប្រកាសពីពិរុទ្ធភាព ហើយសាលក្រមផ្តន្ទាទោសបុគ្គលនោះមិនទាន់ចូលជាស្ថាពរនៅឡើយទេ។ យ៉ាងនេះហើយបានជានៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់យ៉ាងជាក់លាក់នូវលក្ខខណ្ឌ ក៏ដូចជាមូលហេតុមួយចំនួនដែលជាមូលដ្ឋានក្នុងការសម្រេចឃុំខ្លួនបណ្តោះអាសន្នលើបុគ្គលណាម្នាក់បាន។ ម្យ៉ាងទៀតការសម្រេចឃុំខ្លួនបណ្តោះ អាសន្នចំពោះបុគ្គលណាម្នាក់នោះទៀតសោតចាំបាច់ត្រូវឆ្លងកាត់នូវនីតិវិធីមួយដែលត្រូវមានការសន្និដ្ឋានពីតំណាងអយ្យការ មេធាវីការពារសិទ្ធិ ក៏ដូចជាជនត្រូវចោទផងដែរ ដើម្បីផ្តល់ឱកាសឱ្យភាគីទាំងសងខាងធ្វើការដេញដោលពីភាពចាំបាច់ ឬមិនចាំបាច់នៃការឃុំខ្លួនបណ្តោះអាសន្ន។

មួយវិញទៀតការឃុំខ្លួនបុគ្គលណាម្នាក់ដោយមានមូលដ្ឋានត្រឹមត្រូវនោះ ថ្វីត្បិតតែវាប៉ះពាល់នូវសិទ្ធិសេរីភាពរបស់បុគ្គលក៏ពិតមែន ក៏ប៉ុន្តែការសម្រេចឃុំខ្លួននោះនឹងបំពារបំពាននូវសិទ្ធិសេរីភាពជាមូលដ្ឋានផ្សេងៗដែលមនុស្សម្នាក់ៗមានស្របតាមច្បាប់ជាតិ និងអន្តរជាតិផងដែរ។ លើសពីនេះទៅទៀតការសម្រេចនោះនឹងធ្វើឱ្យសង្គមមានសណ្តាប់ធ្នាប់ របៀបរៀបរយ ហើយការអនុវត្តច្បាប់នឹងមានប្រសិទ្ធភាព។ ផ្ទុយទៅវិញ ប្រសិនបើការសម្រេចឃុំខ្លួនបុគ្គលណាម្នាក់ធ្វើឡើងដោយមិនត្រឹមត្រូវតាមការកំណត់របស់ច្បាប់នោះទេ ប្រាកដណាស់វានឹងនាំឱ្យមានការបំពារបំពាននូវសិទ្ធិសេរីភាពរបស់បុគ្គលដែលទទួលស្គាល់ដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ ហើយសង្គមនឹងគ្មានសណ្តាប់ធ្នាប់នោះទេ។

# អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវផ្នែកទ្រឹស្តី និងតាមរយៈការសាកសួរមន្ត្រីដែលអនុវត្តច្បាប់នៅតាមសាលាដំបូងរួចមក យើងអាចសង្កេតឃើញថាគប្បីមានការកែតម្រូវនូវចំណុចមួយចំនួនដូចខាងក្រោម៖

- ចៅក្រមស៊ើបសួរមុននឹងសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ត្រូវធ្វើការស្រាវជ្រាវទៅលើស្ថានភាពជាក់ស្ដែងរបស់ជនត្រូវចោទឱ្យបានច្រើនជាងនេះ ជាពិសេសបញ្ហាសុខភាព និងជីវភាពរបស់ជនត្រូវចោទ ដើម្បីធានាឱ្យបានគោលការណ៍សេរីភាពរបស់ជនត្រូវចោទ ពោលគឺជៀសវាងនៅក្នុងករណីមួយចំនួនដូចជាការឃុំខ្លួនបណ្ដោះអាសន្នមិនមែនជាការចាំបាច់។
- ព្រះរាជអាជ្ញា គប្បីត្រូវមានវត្តមានគ្រប់នីតិវិធីនៃការសួរដេញដោលចំពោះមុខ។
- ចំពោះកិច្ចនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ស្ថាប័នមានសមត្ថកិច្ចគួរតែអនុម័តច្បាប់កំណត់រយៈពេលនៃការស៊ើបសួរ ថាមានរយៈពេលប៉ុន្មាន ការស៊ើបសួរត្រូវតែបញ្ចប់ដើម្បីធានាកុំឱ្យប៉ះពាល់ដល់សិទ្ធិបុគ្គល។
- ធានាឱ្យបាននូវនីត្យានុកូលនៃការឃុំខ្លួនបណ្ដោះអាសន្ន លើជនត្រូវចោទពោលគឺត្រូវគោរពទៅតាមការណ៍កំណត់របស់ច្បាប់។

# ឯកសារយោង

# ឯកសារយោង

## I. ប្រភពជាតិ

១. រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៣។

២. ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

៣. ក្រមព្រហ្មទណ្ឌ ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

៤. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦។

៥. លិខិតលេខ១២០ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់រូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

៦. លិខិតណែនាំលេខ២៩៥ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការសុំកែសម្រួលលិខិតលេខ ១២០ កយ.របក/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌។

## II. ប្រភពអន្តរជាតិ

១. កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុម័តនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ និងចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦។

២. សេចក្តីប្រកាសជាសកលស្តីពី សិទ្ធិមនុស្ស អនុម័ត និងប្រកាសតាមសេចក្តីសម្រេចលេខ 217A(III) ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។

## III. សំណុំរឿងនៃសាលាដំបូងខេត្តកណ្តាល

១. សំណុំរឿងព្រហ្មទណ្ឌលេខៈ ០៦៩ អ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

២. សំណុំរឿងស៊ើបសួរលេខៈ ០៣២ សស ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

## IV. គេហទំព័រ

១. គេហទំព័រ https://freshnewsasia.com/index.php/en/localnews/140568-2019-11-24-02-39-20.html

២. គេហទំព័រ https://freshnewsasia.com/index.php/en/freshnewsplus/202190-2021-06-20-09-50-18.html

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

**១.ឧបសម្ព័ន្ធទី១៖** ទម្រង់ដីកាសម្រេចដែលមាននៅក្នុងសេចក្តីណែនាំលេខ: **២៩៥កឃ.រប/១៤** ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការសុំកែសម្រួលលិខិតលេខ: **១២០ កឃ.រប/១៤** ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ ២០១៤ របស់ក្រសួងយុត្តិធម៌ ។

**២.ឧបសម្ព័ន្ធទី២៖** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លេខ: **០៣៨ ដស.សស** នៃសំណុំរឿងព្រហ្មទណ្ឌលេខ: ០៦៩ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ។

**៣.ឧបសម្ព័ន្ធទី៣៖** ដីកាសន្និដ្ឋានសុំឱ្យឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ នៃសំណុំរឿងព្រហ្មទណ្ឌលេខ: ០៦៩ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ។

**៤.ឧបសម្ព័ន្ធទី៤៖** ដីកាចាត់តាំងចៅក្រមស៊ើបសួរ លេខ: **០៤៤ ដកចត/២១** ចុះថ្ងៃទី១១ ខែមករា ឆ្នាំ ២០២១ ។

**៥.ឧបសម្ព័ន្ធទី៥៖** កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ នៃសំណុំរឿងស៊ើបសួរលេខ: **០៣២ សស** ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

**៦.ឧបសម្ព័ន្ធទី៦៖** កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ នៃសំណុំរឿងស៊ើបសួរលេខ: **០៣២ សស** ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

**៧.ឧបសម្ព័ន្ធទី៧៖** លិខិតអញ្ជើញមេធាវី ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១។

**៨.ឧបសម្ព័ន្ធទី៨៖** កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ នៃសំណុំរឿងស៊ើបសួរលេខ: **០៣២ សស** ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

**៩.ឧបសម្ព័ន្ធទី៩៖** ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន លេខ: **១២២(ឧ)** ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ នៃសំណុំរឿងស៊ើបសួរលេខ: **០៣២ សស** ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ។

**១០.ឧបសម្ព័ន្ធទី១០៖** ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន លេខ: **១២៣**(**ឧ**) ចុះថ្ងៃ១១ ខែមករា ឆ្នាំ ២០២១ សំណុំរឿងស៊ើបសួរលេខ:**០៣២ សស** ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ។

# ឧបសម្ព័ន្ធទី១

ទម្រង់ដីកាសម្រេចដែលមាននៅក្នុងសេចក្តីណែនាំលេខ: ២៩៥កយ.រប/១៤ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការសុំកែសម្រួលលិខិតលេខ: ១២០ កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌

# ឧបសម្ព័ន្ធទី២

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: **០៣៨ ដស.សស**

ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១

នៃសំណុំរឿងព្រហ្មទណ្ឌលេខ: ០៦៩ អក

ចុះថ្ងៃទី១១ ខែមករា  ឆ្នាំ២០២១។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌលេខ ០៦៩ អ.ក

ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១

លេខ៖ ០៣៨ ដកសស

# ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

យើង តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

បានឃើញសំណុំរឿងលេខ ០០៥/២០២១ របក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ របស់កងរាជអាវុធហត្ថខេត្តកណ្តាល ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា មានតម្រុយសន្និដ្ឋានបានថា ៖

| | |
|---|---|
| នាមត្រកូល | ៖ នាមខ្លួន ៖ ភេទប្រុស ជា ជនសង្ស័យ ។ |
| អាយុ | ៖ ១៩ឆ្នាំ (កើតឆ្នាំ២០០២) |
| ទីកន្លែងកំណើត | ៖ ភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ។ |
| លំនៅបច្ចុប្បន្ន | ៖ ភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ។ |
| មុខរបរ | ៖ ជាងដែក |
| នៅលីវ ☑ | ឬ រៀបការ ☐ |
| សញ្ជាតិ | ៖ ខ្មែរ |
| ឪពុកឈ្មោះ | ៖ "រស់" ម្តាយឈ្មោះ ៖ "រស់" ។ |
| ទោសពីមុន | ៖ គ្មាន ។ |

**បានប្រព្រឹត្តអំពើដូចតទៅ៖**

កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ១៦ និង ០០ នាទី ស្ថិតនៅក្នុងភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល មានជនរងគ្រោះឈ្មោះ បានផឹកស្រានៅផ្ទះអ្នកជិតខាងឈ្មោះ បន្ទាប់មកឈ្មោះ បានបន្តទៅផឹកស្រានៅផ្ទះរបស់ឈ្មោះ ត្រូវជាឪពុករបស់ជនសង្ស័យឈ្មោះ

ពេលនោះក៏មានការឈ្លោះប្រកែកគ្នារវាងជនសង្ស័យឈ្មោះ ជាមួយឈ្មោះ និងឈ្មោះ

ភ្លាមនោះក៏មានអ្នកភូមិ និងអ្នកជិតខាងមកជួយឃាត់ ។ ក្រោយមកជនរងគ្រោះឈ្មោះ បានដើរមកឈ្លោះប្រកែកជាមួយជនសង្ស័យម្តងទៀត ពេលនោះជនសង្ស័យឈ្មោះ បានយកដុំឥដ្ឋប្រហោងគប់ក្បាលជនរងគ្រោះ ពីក្រោយបណ្តាលឱ្យដួលផ្កាប់មុខទៅលើថ្ម ហើយត្រូវបានបងប្អូនបញ្ជូនជនរងគ្រោះទៅមន្ទីរ

ពេទ្យ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១ ជនរងគ្រោះបានស្លាប់បាត់បង់ជីវិតតែម្តង ។ ក្រោយបានទទួលពាក្យបណ្តឹងពីឪពុកជនរងគ្រោះ កម្លាំងជំនាញកងរាជអាវុធហត្ថខេត្តកណ្តាល និងស្រុកស្អាង នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០២១ បានធ្វើការស្រាវជ្រាវរហូតឃាត់ខ្លួនជនសង្ស័យឈ្មោះ បញ្ជូនមកតុលាការដើម្បីចាត់ការតាមនីតិវិធីច្បាប់តែម្តង ។

**អំពើខាងលើជាបទល្មើស៖**

ជាបទល្មើស ហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ) ប្រព្រឹត្តនៅភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ ។

បានឃើញមាត្រា៤៤ និងមាត្រា១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## សម្រេច

**បើកការស៊ើបសួរលើអង្គហេតុខាងលើ និង ៖**

☑ ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ

- ឈ្មោះ ភេទប្រុស អាយុ ១៩ឆ្នាំ (មានខ្លួន)

☑ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន

- ឈ្មោះ ភេទប្រុស អាយុ ១៩ឆ្នាំ (មានខ្លួន)

☐ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ថ្ងៃចន្ទ ១៣រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤

កណ្តាល ថ្ងៃទី១១ ខែមករា ឆ្នាំ២០២១

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ ០៦៩ អ.ក
ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១
លេខ ...៦៤.... (ន)

# ដីកាបញ្ជូន

## ផ្ញើជូនៈ លោកស្នងការនគរបាលខេត្តកណ្ដាល

| ល.រ | រាយឈ្មោះលិខិត | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ០១ | ដីកាកោះឈ្មោះ | ០២ច្បាប់ | (ដើម្បីចាត់ការជាសមត្ថកិច្ច) |
| | សរុប | ០២ច្បាប់ | |

ថ្ងៃព្រហស្បតិ៍......៦រោច...... ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស២៥៦៤
កណ្ដាល, ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១
**ចៅក្រមស៊ើបសួរ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**
សំណុំរឿងព្រហ្មទណ្ឌលេខៈ ០៦៩ អ.ក
ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១

# ដីកាកោះ

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល

អញ្ជើញឈ្មោះ ភេទប្រុស អាយុ ៥៨ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល **ជាដើមបណ្តឹង** ។

ឱ្យចូលមកកាន់ សាលាដំបូងខេត្តកណ្តាល **នៅថ្ងៃទី...១៧...... ខែ មីនា ឆ្នាំ២០២១ នៅវេលាម៉ោង០៩ និង០០ នាទីព្រឹក** នៅបន្ទប់ស៊ើបសួរអក្សរ «ន» ។

**ដើម្បី** ៖ស្តាប់ចម្លើយ

**ពីដំណើររឿង ៖ ហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ)** ប្រព្រឹត្តនៅភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា **២២៤** នៃក្រមព្រហ្មទណ្ឌ ។

សូមលោក លោកស្រី អញ្ជើញទៅកាន់សាលាដំបូងខេត្តកណ្តាល ឲ្យទាន់ពេលវេលា តាមកាល បរិច្ឆេទខាងលើជាកំណត់ និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើ មកជាមួយផង ប្រសិនបើមាន។

ថ្ងៃ...ព្រហស្បតិ៍...១...រោច...ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស២៥៦៤
កណ្តាល ថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០២១
**ចៅក្រមស៊ើបសួរ**

យើង..............................................................បានប្រគល់លិខិតអញ្ជើញនេះអោយឈ្មោះ.........................................

ទីលំនៅសព្វថ្ងៃនៅភូមិ.............................ឃុំ-សង្កាត់.....................ស្រុក-ក្រុង.........................រាជធានី/ខេត្ត............
..............................នៅថ្ងៃទី.......ខែ..........ឆ្នាំ២០២០ ផ្ទាល់រួចហើយ ដោយយើងបាន ទុកចុងដីកានេះមួយច្បាប់អោយសាមីខ្លួនហើយប្រាប់អោយសាមីខ្លួនប្រគល់ចុងដីកានេះដល់ក្រឡាបញ្ជីនៅពេលខ្លួនចូលដល់តុលាការ ។

**អ្នកប្រគល់** **អ្នកទទួលលិខិត**

# ឧបសម្ព័ន្ធទី៣

ដីកាសន្និដ្ឋានសុំឱ្យឃុំខ្លួនបណ្ដោះអាសន្ន

ចុះថ្ងៃទី១១ ខែ មករា ឆ្នាំ២០២១

នៃសំណុំរឿងព្រហ្មទណ្ឌលេខ: ០៦៩ អក

ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ ០៦៩ អ.ក

ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១

# ដីកាសន្និដ្ឋានសុំឱ្យឃុំខ្លួនបណ្ដោះអាសន្ន

យើង តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ០៣៨ ដកសស ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ដែលបើកការស៊ើបសួរពីបទ **ហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ)** ។

បានឃើញដីកាបញ្ជូនឱ្យឆ្លើយ ចុះថ្ងៃទី............. ខែ.......... ឆ្នាំ...............របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល ។

ានឃើញមាត្រា ២០៣, មាត្រា ២០៥ និងមាត្រា ២០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**ដោយហេតុថា ការឃុំខ្លួនបណ្ដោះអាសន្នជាមូលហេតុតែមួយគត់ ដើម្បី ៖**

- ☐ បញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី ។
- ☐ រារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាង ជនត្រូវចោទ និង អ្នកសមគំនិត ។
- ☐ រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ ។
- ☐ ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី ។
- ☐ ការពារសន្តិសុខឱ្យជនត្រូវចោទ
- ☐ ធានារក្សាសណ្ដាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស

## យល់ឃើញថា

ការឃុំខ្លួនបណ្ដោះអាសន្ន ជាមធ្យោបាយសម្រាប់បញ្ចប់ភាពចលាចល ធ្ងន់ធ្ងរ និង យូរអង្វែង ចំពោះសណ្ដាប់ធ្នាប់សាធារណៈដោយមូលហេតុថា ៖

- ☐ ភាពធ្ងន់ធ្ងរនៃបទល្មើស ។
- ☐ កាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ។
- ☐ ទំហំនៃព្យសនកម្មដែលបទល្មើសបានបង្កឡើង

## ហេតុដូច្នេះ

**ប្តឹងសុំឱ្យ ចៅក្រមស៊ើបសួរ សម្រេចឃុំខ្លួនបណ្តោះអាសន្នលើ ÷**

| | | | |
|---|---|---|---|
| នាមត្រកូល | ៖ | នាមខ្លួន ៖ | ភេទប្រុស ជា ជនសង្ស័យ ។ |
| អាយុ | ៖ ១៩ឆ្នាំ (កើតឆ្នាំ២០០២) | | |
| ទីកន្លែងកំណើត | ៖ ភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ។ | | |
| លំនៅបច្ចុប្បន្ន | ៖ ភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ។ | | |
| មុខរបរ | ៖ ជាងដែក | | |
| នៅលីវ ☑ | ឬ រៀបការ ☐ | | |
| សញ្ជាតិ | ៖ ខ្មែរ | | |
| ឪពុកឈ្មោះ | ៖ "រស់" | ម្តាយឈ្មោះ ៖ | "រស់" ។ |
| ទោសពីមុន | ៖ គ្មាន ។ | | |

ថ្ងៃចន្ទ ១៣រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤

កណ្តាល, ថ្ងៃទី១១ ខែមករា ឆ្នាំ២០២១

**តំណាងអយ្យការ**

# **ឧបសម្ព័ន្ធទី៤**

ដីកាចាត់តាំងចៅក្រមស៊ើបសួរ លេខ: **០៤៤ ដកចត/២១**

ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

សាលាដំបូងខេត្តកណ្តាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: 044 ដកចត/២១

## ដីកាចាត់តាំងចៅក្រមស៊ើបសួរ

យើង ប្រធានសាលាដំបូងខេត្តកណ្តាល

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: 069 អក ចុះថ្ងៃទី 11 ខែ មករា ឆ្នាំ២០21 របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: 038 ដកសស ចុះថ្ងៃទី 11 ខែ មករា ឆ្នាំ២០២1 របស់លោក ជាតំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

**សម្រេច**

ចាត់តាំងលោក ជាចៅក្រមស៊ើបសួរលើសំណុំរឿងព្រហ្មទណ្ឌខាងលើដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

ថ្ងៃ.......................ខែ...........................ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
កណ្តាល,ថ្ងៃទី 11 ខែ 01 ឆ្នាំ២០២១
ប្រធាន

# **ឧបសម្ព័ន្ធទី៥**

កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង

ចុះថ្ងៃទី១១ ខែ មករា ឆ្នាំ២០២១

នៃសំណុំរឿងស៊ើបសួរ លេខៈ **០៣២ សស**

ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌលេខ ០៦៩ អក
ចុះថ្ងៃទី ១១-មករា-២០២១
សំណុំរឿងស៊ើបសួរលេខ......សស
ចុះថ្ងៃទី ......-...........-២០២១

# កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង

(មាត្រា ១៤៣. ១៤៤. ២៤០ និងមាត្រា ២៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ម្ភៃមួយ ខែមករា ថ្ងៃទីដប់មួយ វេលាម៉ោងប្រាំបី និងសូន្យនាទីព្រឹក។

យើង **ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល**

អមដោយលោក ជាក្រឡាបញ្ជី ។

បុគ្គលដែលនៅចំពោះមុខយើង បានផ្តល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម ៖

ឈ្មោះ ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ ជាងដែក ទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួនភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ឪពុកឈ្មោះ រស់ ម្តាយឈ្មោះ រស់ នៅលើវ ជានីតិជន កម្រិតវប្បធម៌ថ្នាក់ទី ០៧។

ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ (ដប់) ឆ្នាំ ដែលស្ថិតនៅ លំនៅបច្ចុប្បន្ន ។

☑ជននេះ បានប្រាប់ថា ចេះអាន និងចេះសរសេរភាសាខ្មែរ

☐ជននេះ បានប្រាប់ថា មិនចេះអាន និងមិនចេះសរសេរភាសាខ្មែរ

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះឱ្យដឹង យ៉ាងច្បាស់អំពីរឿងក្តី ដែលតំណាងអយ្យការបានប្តឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ៖ ០៣៨ ដក.សសចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ដែលជាហេតុនាំឲ្យមានការបង្ហាញខ្លួនជន នេះចំពោះមុខយើង ព្រមទាំងប្រាប់ជននេះអោយដឹង អំពីបទចោទប្រកាន់ ចំពោះរឿងក្តីដូចខាងក្រោម ៖

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

យើងបានជូនដំណឹងដល់ជននេះថា យើងគ្រោងនឹងដាក់ជននេះឲ្យស្ថិតនៅក្រោមការពិនិត្យ ចំពោះរឿងក្តីដែលយើងទើបនឹងរៀបរាប់អោយជននេះដឹងយ៉ាងច្បាស់ ។

លោក-លោកស្រី....................................ជាមេធាវី នៃជនត្រូវចោទដែលត្រូវបាន

កោះហៅនៅ ថ្ងៃទី...........ខែ.............ឆ្នាំ.............ហើយដើម្បីឱ្យលោក-លោកស្រីមេធាវីអាច

ត្រៀមរៀបចំការពារកូនក្តីខ្លួនបាន ។

យើងបានប្រាប់ដល់ជននេះអំពីសិទ្ធិទទួលបានជំនួយមេធាវី ដែលជននេះអាចជ្រើសរើសពឹងមេធាវីដោយខ្លួនឯង ឬ អាចសុំឱ្យគេចាត់តាំងមេធាវីណាម្នាក់ឱ្យរូបគាត់ ។

យើងបានប្រាប់ផងដែរដល់ជននេះថាប្រសិនបើមិនធ្វើការជ្រើសរើសពឹងមេធាវីដោយខ្លួនឯងទេ មេធាវីមួយរូប នឹងត្រូវចាត់តាំងដោយឯកឯង ដោយសារតែជននេះជាអនីតិជន។

ជននេះ បានប្រកាសប្រាប់ថា៖

☐ខ្ញុំជ្រើសរើសមេធាវីដោយខ្លួនឯង

☑ខ្ញុំស្នើសុំឱ្យចាត់តាំងមេធាវីមួយរូបឱ្យរូបខ្ញុំ

☐ខ្ញុំបដិសេធជំនួយពីមេធាវី

យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់មានសិទ្ធិអាចនៅស្ងៀមមិនផ្តល់ចម្លើយក៏បាន ឬ អាចធ្វើសេចក្តីប្រកាសផ្សេងៗ ឬ អាចឱ្យយើងសួរចម្លើយក៏បាន ។

ជននេះ បានប្រកាសប្រាប់ថា៖ ខ្ញុំនឹងអាចផ្តល់ចម្លើយបាន [illegible] ដោយ មានមេធាវីសិន ។

លោក-លោកស្រី មេធាវី៖ ..........................................បានផ្តល់សេចក្តី កត់សម្គាល់ការពារថា

..........................................................................................................

យើងបានជូនដំណឹងដល់ជននេះថា យើងសម្រេចដាក់គាត់ឱ្យ ស្ថិតនៅក្រោមការ ពិនិត្យ៖

ចំពោះអង្គហេតុទាំងអស់ដែលយើងបានប្រាប់ឱ្យដឹង ។

ចំពោះតែអង្គហេតុដែលរៀបរាប់ខាងក្រោម ដែលយើងបញ្ជាក់ប្រាប់ជននេះអំពីឈ្មោះ នៃបទល្មើស៖

បទ៖ ហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោស [illegible])......

យើងបានប្រាប់ដល់ជនត្រូវចោទ អំពីសិទ្ធិក្នុងការសុំឱ្យយើងធ្វើកិច្ចស៊ើបសួរមួយ ឬ ច្រើន ឬ ក៏អាចធ្វើពាក្យប្តឹងសុំមោឃភាពនៃកិច្ចស៊ើបសួរ ដោយផ្អែកតាមមូលដ្ឋាន នៃមាត្រា ២៥៣ ប្តឹងឧទ្ធរណ៍ តាមបញ្ញត្តិមាត្រា ២៦៧ នៅក្នុងពេល នៃដំណើរការនៃការស៊ើបសួរក្នុងលក្ខ ខណ្ឌ ដែលមានចែងក្នុងមាត្រា ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

យើងបានប្រាប់ដល់ជនត្រូវចោទអំពីសិទ្ធិ ក្នុងការជ្រើសរើសមេធាវីសម្រាប់នីតិវិធី បន្ទាប់មកទៀត ហើយប្រសិនបើមិនបានធ្វើការជ្រើសរើសមេធាវីដោយខ្លួនឯងទេ និងបើសិន ជាមានសំណើសុំ យើងនឹងចាត់តាំងមេធាវីមួយរូបជូន ( សម្រាប់តែក្នុងករណី ដែលជនត្រូវចោទមិនបានជ្រើសរើសពឹងពាក់មេធាវីដោយខ្លួនឯង និងមិនបានស្នើសុំឱ្យ ចាត់តាំងមេធាវី ឱ្យ ) ។

☐ជនជាប់ចោទ បានប្រកាសប្រាប់ថា៖

☐ខ្ញុំជ្រើសរើសពឹងពាក់មេធាវីដោយខ្លួនឯង

☑ខ្ញុំស្នើសុំឱ្យចាត់តាំងមេធាវីមួយរូបឱ្យរូបខ្ញុំ

☐ខ្ញុំបដិសេធជំនួយពីមេធាវី

យើងបានប្រាប់ដល់ជនត្រូវចោទថាគាត់អាចសុំឱ្យបិទការស៊ើបសួរបាននៅក្រោយ ពេលផុតរយៈពេលមួយឆ្នាំ ដោយអនុវត្តតាមបទបញ្ញត្តិនៃមាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

យើងបានប្រាប់ដល់ជនត្រូវចោទថា នៅថ្ងៃនេះ យើងសម្រេចឃុំខ្លួនគាត់បណ្តោះអាសន្ន ។

យើងបានប្រាប់ដល់ជនត្រូវចោទថា នៅថ្ងៃនេះ យើងសម្រេចដាក់គាត់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនិងប្រាប់ឱ្យគាត់អំពីកាតព្វកិច្ចទាំងឡាយដែលគាត់ត្រូវគោរព។

យើងបានប្រាប់ដល់ជនត្រូវចោទថា យើងសម្រេចមិនឃុំខ្លួន (ឱ្យនៅក្រៅឃុំ) ។

យើងបានប្រាប់ដល់ជនត្រូវចោទថា៖

-គាត់ត្រូវប្រកាសប្រាប់អំពីអាសយ័ដ្ឋានដែលអាចជាអាសយ័ដ្ឋានផ្ទាល់ខ្លួនឬជាអាសយដ្ឋានរបស់តតិយជនណាម្នាក់ដែលទទួលបន្ទុកទទួលយកលិខិតដែលបញ្ជូនទៅឱ្យគាត់ប្រសិន បើគាត់អាចផ្តល់ឱ្យភ្លាមនូវការព្រមព្រៀង ជាលាយល័ក្ខណ៍អក្សររបស់តតិយជននោះ ។

-អាសយដ្ឋានដែលត្រូវប្រកាសប្រាប់ត្រូវមានទីតាំងស្ថិតនៅ..............................................................................

..............................................................................................................................................

ជនត្រូវចោទបានប្រកាសអាសយ័ដ្ឋានដូចខាងក្រោម៖

អាសយដ្ឋាននេះជា៖ អាសយដ្ឋានផ្ទាល់ខ្លួន

អាសយដ្ឋានរបស់ ៖ ..........................................................................

យើងបានប្រាប់ដល់ជនត្រូវចោទបន្ថែមថា៖

-រហូតដល់ការបិទការស៊ើបសួរ គាត់ត្រូវប្រាប់ដល់ យើងគ្រប់ការផ្លាស់ប្តូរអាស័យដ្ឋាន ដែលបានប្រកាសប្រាប់ខាងលើដោយការប្រកាសជាថ្មី ឬដោយលិខិតអនុសិដ្ឋ ។

-គ្រប់ការជូនដំណឹង ឬ ការឱ្យដំណឹងដែលបញ្ជូនទៅអាសយដ្ឋាន ដែលបានប្រកាស ប្រាប់ចុងក្រោយបង្អស់ត្រូវចាត់ទុកថា ជូនដំណឹងដល់បុគ្គលជនត្រូវចោទ ។

យើងបានឱ្យជនត្រូវចោទឱ្យអានឡើងវិញ នូវសេចក្តីប្រកាសទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះហើយបើមិនបដិសេធត្រង់ចំណុចណាទេឱ្យចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនេះ។

បានអានឱ្យស្តាប់ចប់សព្វគ្រប់ ហើយជនជាប់មិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខា ឬផ្តិតមេដៃជាមួយយើង និងក្រឡាបញ្ជី ។

បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខា ឬ ផ្តិតមេដៃជាមួយយើង ក្រឡាបញ្ជី និងអ្នកបកប្រែ ។

**អ្នកបកប្រែ ជនត្រូវចោទ មេធាវី ក្រឡាបញ្ជី ចៅក្រមស៊ើបសួរ**



# **ឧបសម្ព័ន្ធទី៦**

កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ

ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១

នៃសំណុំរឿងសុើបសួរលេខៈ **០៣២ អ.ក**

ចុះថ្ងៃទី១១  ខែមករា ឆ្នាំ២០២១។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌ ០៦៩ អ ក.

ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១

សំណុំរឿងស៊ើបសួរលេខ........... សស

:ថ្ងៃទី ...... ខែមករា ឆ្នាំ២០២១

# កំណត់ហេតុស្តីពី
# ការពិភាក្សាដេញដោលចំពោះមុខ

(មាត្រា ២០៣ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ម្ភៃមួយ ខែមករា ថ្ងៃទីដប់មួយ វេលាម៉ោងប្រាំបី និងសែសិបនាទីព្រឹក ។

**យើង** ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល

អមដោយលោក ជាក្រឡាបញ្ជី ។

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ៖ ០៣៨ ដក.សស ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

បុគ្គលដែលនៅចំពោះមុខយើង បានផ្តល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម៖

-ឈ្មោះ ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ ជាងដែក ទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួនភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ឪពុកឈ្មោះ "រស់ "ម្តាយឈ្មោះ "រស់ "នៅលីវ ជានីតិជន កម្រិតវប្បធម៌ថ្នាក់ទី ០៧។

អ្នកឯងចេះអាននិងសរសេរភាសាខ្មែរដែរឬទេ?...ខ្ញុំបាទចេះអាន និងសរសេរភាសាខ្មែរខ្លះៗ....។

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **ហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោសដោយសារមរណៈភាពនៃជនរងគ្រោះ)** ប្រព្រឹត្តនៅភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា **២២៤** នៃក្រមព្រហ្មទណ្ឌ ។

ដោយមានលោក-លោកស្រីមេធាវី..................................................ដែលជនត្រូវចោទបានជ្រើសរើសពឹងពាក់ដោយខ្លួនឯង ឬ ដែលត្រូវបានចាត់តាំងដោយគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បានមក បង្ហាញខ្លួននៅក្នុងបន្ទប់នៅចំពោះមុខយើង បន្ទាប់ពីបានពិគ្រោះមើលសំណុំរឿង និងបានធ្វើទំនាក់ទំនង ដោយសេរីជាមួយនឹងជនត្រូវចោទ នៅពេលបង្ហាញខ្លួនជាលើកដំបូង ។

យើងបានប្រាប់ជនត្រូវចោទថា៖

☑ យើងមានបំណងសម្រេចឃុំខ្លួន ជនត្រូវចោទជាបណ្តោះអាសន្ន។

☑ ជនជាប់ចោទអាចស្នើសុំពន្យាពេល ដើម្បីរៀបចំការពារខ្លួន ។

☑ យើងនឹងសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃនេះ។ ជនត្រូវចោទបានប្រកាសប្រាប់ថា៖ ខ្ញុំបាទយល់ព្រមតាមការស្នើសុំឃុំខ្លួន។

ការពិភាក្សាដេញដោលចំពោះមុខទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន៖

☑ ត្រូវបានធ្វើ

☐ ត្រូវបានលើកទៅថ្ងៃទី..........ខែ............ឆ្នាំ២០...........តាមសំណូមពររបស់................................

តំណាងអយ្យការបានបង្ហាញនូវសេចក្តីសន្និដ្ឋានរបស់ខ្លួនដូចខាងក្រោម៖

ស្នើសុំចៅក្រមសម្រេចឃុំខ្លួនជននេះជាបណ្តោះអាសន្ន ។

ជនត្រូវចោទបានបង្ហាញសេចក្ដីសង្កេតរបស់ខ្លួន ដូចខាងក្រោម៖

ខ្ញុំបាទ មិនអាចឆ្លើយបាន ហេតុតែគ្មានមេធាវីអមពេលនេះទេ ដូចនេះ ខ្ញុំបាទ យល់ព្រមឱ្យចោទ ទៅក្រោយ សម្រេចឃុំខ្លួនខ្ញុំបាទ របស់បាន តាមចាត់តាំងមេធាវី ។

លោក-លោកស្រីមេធាវី..............................បានបង្ហាញសេចក្ដីសន្និដ្ឋានការពារដូចខាងក្រោម៖

........................................................................................................................................................

........................................................................................................................................................

........................................................................................................................................................

យើងបានប្រាប់ដល់ជនត្រូវចោទថា យើងសម្រេចចេញដីកាសម្រេចឱ្យឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន ដោយមានសំអាងហេតុ ហើយយើងសម្រេចចេញដីកាបង្គាប់ឱ្យឃុំខ្លួននៅថ្ងៃនេះ ។

យើងបានអញ្ជើញជនជាប់ចោទឱ្យអានឡើងវិញ នូវសេចក្ដីប្រកាសទាំងអស់របស់ខ្លួន ដែលយើង បានកត់ចម្លងចូលក្នុងកំណត់ហេតុនេះហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឱ្យចុះហត្ថលេខា ឬផ្ដិតមេដៃនៅលើកំណត់ហេតុនេះ ។

បានអានចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខា ឬ ផ្ដិតមេដៃជាមួយយើង និងក្រឡាបញ្ជី ។

□បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនជាប់ចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខា ឬ ផ្ដិតមេដៃជាមួយយើង ក្រឡាបញ្ជី និងអ្នកបកប្រែ ។

| **អ្នកបកប្រែ** | **ជនត្រូវចោទ** | **មេធាវី** | **ក្រឡាបញ្ជី** | **ចៅក្រមស៊ើបសួរ** |
|---|---|---|---|---|

# ឧបសម្ព័ន្ធទី៧

លិខិតអញ្ជើញមេធាវី ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ០៦៩ អ.ក
ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១

# **<u>លិខិតអញ្ជើញមេធាវី</u>**

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល

**<u>សូមអញ្ជើញ</u>**

លោកមេធាវី ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវឈ្មោះ ភេទប្រុស អាយុ១៩ឆ្នាំ ។

ដែលជាប់ចោទពីបទៈ **ហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោសដោយសាមរណៈភាពនៃជនរងគ្រោះ)** ប្រព្រឹត្តនៅភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ។

ឱ្យចូលមកកាន់សាលាដំបូងខេត្តកណ្ដាល នៅថ្ងៃទី១៦ ខែកុម្ភៈ.... ឆ្នាំ២០២០ **វេលាម៉ោង**០៩ និង.៣០.នាទី ព្រឹក.....នៅបន្ទប់អក្សរ "**ន**" ។

ដើម្បី ៖ **ចូលរួមស្ដាប់ការសួរចម្លើយជនត្រូវចោទ**

ពីដំណើររឿង ៖ **ហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោសដោយសាមរណៈភាពនៃជនរងគ្រោះ)** ប្រព្រឹត្តនៅភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ។

សូមលោក អញ្ជើញទៅកាន់សាលាដំបូងខេត្តកណ្ដាល ឱ្យបានទាន់ពេលវេលាតាមកាល បរិច្ឆេទខាងលើជាកំណត់ព្រមទាំងយកឯកសារនានាដែលពាក់ព័ន្ធមកជាមួយផងប្រសិនបើមាន។

ថ្ងៃច័ន្ទ ១១រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
កណ្ដាល ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១
**ចៅក្រមស៊ើបសួរ**

**បានទទួល**
ថ្ងៃទី........ខែ...........ឆ្នាំ២០២០
**មេធាវី**

# **ឧបសម្ព័ន្ធទី៨**

កំណត់ហេតុស្ដីពីការសួរចម្លើយជនត្រូវចោទ

ចុះថ្ងៃទី១៦ កុម្ភៈ ឆ្នាំ២០២១

នៃសំណុំរឿងស៊ើបសួរលេខៈ **០៣២ សស**

ចុះថ្ងៃទី១១  ខែមករា ឆ្នាំ២០២១។

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ ០៦៩ អក
ចុះថ្ងៃទី ១១-មករា-២០២១
សំណុំរឿងស៊ើបសួរលេខ ០៣២ សស
ចុះថ្ងៃទី ១១-មករា -២០២១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**កំណត់ហេតុស្ដីពីការសួរចម្លើយជនត្រូវចោទ**

(មាត្រា ១៤៥ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ម្ភៃ ខែកុម្ភៈ ថ្ងៃទីដប់ប្រាំមួយ វេលាម៉ោង ០៩ និងសូន្យនាទីព្រឹក

នៅសាលាដំបូងខេត្តកណ្ដាល ដោយមានសមាសភាពចូលរួមដូចខាងក្រោម៖

យើង , ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល

អមដោយលោក ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្ដាល

បានមកបង្ហាញខ្លួនក្នុងនាមជនត្រូវចោទ នៅក្នុងមន្ទីរស៊ើបសួរនៅចំពោះមុខយើងជនដែលមានសញ្ញាណ ដូចខាងក្រោម ៖

-ឈ្មោះ ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ ជាងដែក ទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួនភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល ឪពុកឈ្មោះ ៖ "រស់ "ម្ដាយឈ្មោះ "រស់ "នៅលីវ ជានីតិជន កម្រិតវប្បធម៌ថ្នាក់ទី ០៧។

ប្រវត្តិការផ្ដន្ទាទោសដោយតុលាការ **គ្មាន** ។

☐ ជននេះបានប្រកាសប្រាប់ថា ខ្លួនគ្មានអំណាចមេបាលើក្មេងអាយុក្រោម ១០ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន ។

☑ជននេះ៖ ☑ចេះនិយាយ ☑ចេះអាន ☑ចេះសរសេរអក្សរខ្មែរ

☐ជននេះ៖ ☐មិនចេះនិយាយ ☐មិនចេះអាន ☐មិនចេះសរសេរអក្សរខ្មែរ

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះឱ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវដែលព្រះរាជអាជ្ញាបានប្ដឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ០៣៨ **ដកសស** ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

ដែលជាហេតុនាំឱ្យជននេះ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ☐ និងការឃុំខ្លួនបណ្ដោះអាសន្ន☐ តាមដីកាសម្រេចលេខ ................ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

អមដោយលោក **សរ ស៊ីតា** ជាមេធាវីការពារក្ដីឱ្យជនត្រូវចោទ ។

យើងបានសួរចម្លើយឈ្មោះនេះ ហើយឈ្មោះនេះបានឆ្លើយប្រាប់យើងដូចខាងក្រោមថា ៖

យើងចៅក្រមស៊ើបសួរបានប្រាប់បទចោទប្រកាន់ និងប្រាប់ពីសិទ្ធិដល់ជននេះរួចហើយ ។

**ឆ.ស** ខ្ញុំបាទសូមរក្សាចម្លើយរបស់ខ្ញុំបាទដែលបានឆ្លើយនៅកងរាជអាវុធហត្ថខេត្តកណ្ដាលចុះថ្ងៃ១០ ខែមករា ឆ្នាំ២០២១ និងចំពោះមុខតំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ទុកជាបានការដដែល។

ឆ.ស កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ វេលាម៉ោងប្រហែល០២ជាងខ្ញុំបាទកំពុងអង្គុយនៅក្រោមផ្ទះរបស់ខ្ញុំ បានឮឈ្មោះ កំពុងតែឈ្លោះប្រកែកគ្នាជាមួយឪពុករបស់ខ្ញុំឈ្មោះ នៅផ្ទះអ៊ុំទល់មុខផ្ទះរបស់ខ្ញុំ ហើយឈ្មោះ បានប្រមាថមើលងាយមកលើឪពុករបស់ខ្ញុំ ពេលនោះខ្ញុំមានការខឹងទៅលើឈ្មោះ យ៉ាងខ្លាំង ហើយខ្ញុំបាទបានយកដុំឥដ្ឋប្រហោងមួយដុំគប់ទៅលើឈ្មោះ ត្រូវចំក្បាលខាងក្រោយបណ្តាលឱ្យគាត់ដួលបោកក្បាលទៅលើផ្លូវបេតុងមុខផ្ទះអ៊ុំឈ្មោះ ពេលនោះខ្ញុំមិនបាននៅមើលគាត់ទេ គឺខ្ញុំបានរត់គេចខ្លួនទៅផ្ទះអ៊ុំនៅឃុំស្វាយប្រទាល ស្រុកគៀនស្វាយ បានចំនួនមួយយប់។ បន្ទាប់មកខ្ញុំក៏បានបន្តដំណើរទៅផ្ទះអ៊ុំនៅភូមិត្រាំប៉ោង ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តមានជ័យ ដោយមិនបានដឹងថាឈ្មោះ ស្លាប់នោះទេ។

ឆ.ស លុះមកថ្ងៃទី០៩ ខែមករា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ០៧ ព្រឹកក៏មានសមត្ថកិច្ចបានទៅឃាត់ខ្លួនខ្ញុំតែម្តង។

ឆ.ស ពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទបានដកហូតយកទូរសព្ទ័ OPPO ពណ៌ក្រហម (ស៊ីមពីរ) ០១គ្រឿង។

សំណូមពរសុំឱ្យតុលាការជួយបន្ធូបន្ថយទោសខ្ញុំបាទផង ដោយខ្ញុំបាទមិនមានចេតនាធ្វើឱ្យជនរងគ្រោះស្លាប់ ។

□បាននអានចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងផ្តិតមេដៃជាមួយយើងនិងក្រឡាបញ្ជី ទុកជាសំអាងតាមផ្លូវច្បាប់ ។

បញ្ឈប់កំណត់ហេតុនៅវេលាម៉ោង០៩ និង៣០ នាទីព្រឹក នាថ្ងៃខែឆ្នាំដូចខាងលើ៕

| ជនត្រូវចោទ | មេធាវី | ក្រឡាបញ្ជី | ចៅក្រមស៊ើបសួរ |
|---|---|---|---|

# ឧបសម្ព័ន្ធទី៩

ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ:១២២ “**ន**”

នៃសំណុំរឿងស៊ើបសួរលេខ: **០៣២ សស**

ចុះថ្ងៃទី១១  ខែមករា ឆ្នាំ២០២១។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

**លេខៈ ១២២ (ខ)**

## <u>ដីកាសម្រេច</u>
## <u>ឲ្យឃុំខ្លួនបណ្ដោះអាសន្ន</u>

យើង ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល

-បានឃើញៈ មាត្រា២០៣, មាត្រា២០៤, មាត្រា២០៥ និងមាត្រា២០៦ នៃក្រមព្រហ្មទណ្ឌដែលទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខៈ ០៦៩ អ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ ០៣៨ ដកសស ចុះថ្ងៃទី១១ ខែមករា ឆ្នាំ ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ដែលបើកការស៊ើបសួរលើះ

ឈ្មោះ ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ ជាងដែក ទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួនភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល ឪពុកឈ្មោះ "រស់" ម្ដាយឈ្មោះ "រស់" នៅលីវ ជានីតិជន កម្រិតវប្បធម៌ថ្នាក់ទី ០៧។

ជននេះត្រូវជាក់ក្រោមការពិនិត្យពីបទៈ **ហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ)** ប្រព្រឹត្តនៅភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ ២០២១ តាមបញ្ញត្តិមាត្រា **២២៤** នៃក្រមព្រហ្មទណ្ឌ ។

-បានឃើញ កំណត់ហេតុស្ដីពីការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

-បានឃើញ កំណត់ហេតុស្ដីពីការសួរចម្លើយជនត្រូវចោទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

-បានឃើញ កំណត់ហេតុស្ដីពីការពិភាក្សាដេញដោលចំពោះមុខ និងការកត់សម្គាល់របស់ភាគី ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ២០២១។

## <u>ស្ថានភាពអង្គហេតុ និងអង្គច្បាប់</u>

១-ករណីបច្ចុប្បន្នជនត្រូវចោទឈ្មោះ ត្រូវបានចោទប្រកាន់ ពីបទៈ **ហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ)** ប្រព្រឹត្តនៅភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា **២២៤** នៃក្រមព្រហ្មទណ្ឌ ។

២-កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ វេលាម៉ោង១៦ និង០០ នាទីស្ថិតនៅក្នុងភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល មានជនរងគ្រោះឈ្មោះ បានផឹកស្រានៅផ្ទះអ្នកជិតខាងឈ្មោះ

បន្ទាប់មកឈ្មោះ បានបន្តទៅផឹកស្រានៅផ្ទះរបស់ឈ្មោះ ត្រូវជាឪពុករបស់ជនសង្ស័យឈ្មោះ ពេលនោះក៏មានការឈ្លោះប្រកែកគ្នារវាងជនសង្ស័យឈ្មោះ និងឈ្មោះ និងឈ្មោះ ភ្លាមនោះក៏មានអ្នកភូមិ និងអ្នកជិតខាងមកជួយឃាត់។ ក្រោយមកជនរងគ្រោះឈ្មោះ បានដើរមកឈ្លោះប្រកែកជាមួយជនសង្ស័យម្ដងទៀត ពេលនោះជនសង្ស័យឈ្មោះ បានយកដុំឥដ្ឋប្រហោងគប់ក្បាលជនរងគ្រោះ ពីក្រោយបណ្ដាលឱ្យដួលផ្កាប់មុខទៅលើថ្ម ហើយត្រូវបានបងប្អូន

**<u>លិខិតបញ្ជូន</u>**

យើង ជាក្រឡាបញ្ជីបានប្រគល់ដីកាសម្រេចឃុំបណ្ដោះអាសន្នលេខ..១៤៤.... ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ដល់ឈ្មោះខាងក្រោម នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

អ្នកប្រគល់

លេខ..0220..ដកសយខ
តំណាងអយ្យការ

អ្នកទទួល
មេធាវីជនត្រូវចោទ

ជនត្រូវចោទ

**ឧបសម្ព័ន្ធទី១០**

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ ១២៣ “**ឆ**”នៃសំណុំរឿង

សើុបសួរលេខៈ **០៣២ សស**

ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

# ដីកាបង្គាប់ឲ្យឃុំខ្លួន

**លេខ ១២៣ (ន)** យើង ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល

-**បានឃើញ**មាត្រា **២១៩** មាត្រា **២២០** មាត្រា **២២១** និងមាត្រា **២២២** នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ **នស/រកម/០៨០៧/០២៤** ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-**បានឃើញ**សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០៦៩ អ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ៖ ០៣៨ ដកសស ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ របស់តំណាង អយ្យការអមសាលាដំបូងខេត្តកណ្តាល។

-**បានឃើញសំណុំរឿងទាក់ទងនិង:**

ឈ្មោះ ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ មុខរបរ ជាងដែក ទីកន្លែងកំណើតនៅភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្នភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ឪពុកឈ្មោះ ម្តាយឈ្មោះ ជានីតិជន នៅលីវ ទោសពីមុនគ្មាន កម្រិតវប្បធម៌ថ្នាក់ទី**០៧**។

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទៈ **ហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោសដោយសារមរណៈភាពនៃជនរងគ្រោះ)** ប្រព្រឹត្តនៅភូមិទួលសុភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា **២២៤** នៃក្រមព្រហ្មទណ្ឌ ។

-**បានឃើញ**ៈ ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ **១២២ ដកសឃខ** ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

## សម្រេច

**១**-បញ្ជាឲ្យភ្នាក់ងារមានសមត្ថកិច្ចនៃកម្លាំងសាធារណៈធ្វើការនាំខ្លួនជនត្រូវចោទឈ្មោះ ទៅពន្ធនាគារខេត្តកណ្តាលដោយអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ ។

**២**-បង្គាប់ឲ្យប្រធានពន្ធនាគារខេត្តកណ្តាលទទួលនិងឃុំខ្លួនជននេះរហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ។

**៣**-បង្គាប់ឲ្យគ្រប់ភ្នាក់ងារមានសមត្ថកិច្ចនៃកម្លាំងសាធារណៈទាំងអស់នៅពេលត្រូវបានបង្ហាញដីកានេះសហការអនុវត្តឲ្យបានល្អក្នុងករណីចាំបាច់ ៕

ថ្ងៃច័ន្ទ ១៣រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
កណ្តាល, ថ្ងៃទី១១ ខែមករា ឆ្នាំ២០២១
**ចៅក្រមស៊ើបសួរ**

បញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១ ជនរងគ្រោះបានស្លាប់បាត់បង់ជីវិតតែម្តង។ ក្រោយបានទទួលពាក្យបណ្តឹងពីឪពុកជនរងគ្រោះ កម្លាំងជំនាញកងរាជអាវុធហត្ថខេត្តកណ្តាល និងស្រុកស្អាង នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០២១ បានធ្វើការស្រាវជ្រាវឃាត់ខ្លួនជនសង្ស័យឈ្មោះ បញ្ជូនមកតុលាការដើម្បីចាត់ការតាមនីតិវិធីច្បាប់តែម្តង។

៣.តំណាងអយ្យការបានស្នើសុំឲ្យឃុំខ្លួនលើជនត្រូវចោទឈ្មោះ ដោយផ្អែកលើអង្គហេតុ ដើម្បីធានាវត្តមានជនត្រូវចោទសម្រាប់នីតិវិធីតុលាការ។

៤. ជនត្រូវចោទឈ្មោះ បានធ្វើការកត់សម្គាល់ថា យល់ព្រមលើការឃុំខ្លួននេះ។

## **<u>សំអាងហេតុនៃសេចក្តីសម្រេច</u>**

១.យល់ឃើញថា ជនត្រូវចោទឈ្មោះ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ដែលច្បាប់កំណត់ដាក់ពន្ធនាគារស្មើ ឬលើស១ឆ្នាំ(មាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

២.យល់ឃើញថា តាមចម្លើយសារភាពរបស់ជនត្រូវចោទឈ្មោះ បានឆ្លើយសារភាពចំពោះអង្គហេតុដែលតំណាងអយ្យការចោទប្រកាន់ពីបទៈ **ហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនគ្រោះ)** ថាខ្លួនពិតជាបានប្រព្រឹត្ត ដូចការចោទប្រកាន់ពិតមែន។

៣.យល់ឃើញថា សេចក្តីសន្និដ្ឋានស្នើសុំឲ្យឃុំខ្លួនជនត្រូវចោទ ជាបណ្តោះអាសន្នរបស់តំណាងអយ្យការមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីតុលាការពិនិត្យពិចារណាចំពោះការប្តឹងសុំនេះ។

៤.យល់ឃើញថា ចំពោះការកត់សម្គាល់របស់ជនត្រូវចោទ ដែលយល់ព្រមឲ្យតុលាការឃុំខ្លួនបណ្តោះអាសន្ន មានលក្ខណៈសមហេតុផល។

៥.យល់ឃើញថា ដើម្បីធានាដល់ការស៊ើបសួរឲ្យបានល្អក្នុងការប្រមូលភស្តុតាង ដើម្បីបញ្ចប់ និងបង្ការកុំឲ្យ មានបទល្មើសថ្មីទៀត និងដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ ដើម្បីកុំឲ្យមានការច្របូកច្របល់ដែលបណ្តាលមកពី បទល្មើស ព្រមទាំងធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី គប្បីតុលាការសម្រេចឃុំខ្លួនជនត្រូវ ចោទឈ្មោះ ជាបណ្តោះអាសន្ន ដោយសារមិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយដែល មានលក្ខណៈតឹងរឹង និងអាចធានាឲ្យមានការបំពេញប្រកបដោយប្រសិទ្ធិភាពចំពោះស្ថានភាពតម្រូវទាំងនេះហើយមានតែឃុំខ្លួនដែលជាមធ្យោបាយមួយគត់ ដើម្បីសម្រេចនូវគោលដៅខាងលើ។

## **<u>ហេតុដូច្នេះសម្រេច</u>**

-ឃុំខ្លួនជនត្រូវចោទឈ្មោះ ជាបណ្តោះអាសន្ន ហើយយើងនឹងចេញដីកាបង្គាប់ឲ្យឃុំខ្លួនដើម្បីអនុវត្តការឃុំខ្លួននេះ។

ថ្ងៃច័ន្ទ ១៣រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

កណ្តាល ថ្ងៃទី១១ ខែមករា ឆ្នាំ២០២១

បានទទួលអនុវត្ត

**ក្រឡាបញ្ជី**

**ចៅក្រមស៊ើបសួរ**

យើង......................................ប្រធានពន្ធនាគារខេត្តកណ្តាលបានអនុវត្តឃុំខ្លួនឈ្មោះ.....................
ភេទ...........អាយុ..........ឆ្នាំ..........សញ្ជាតិ........... តាមអំណាចដីកាបង្គាប់ឲ្យឃុំខ្លួននេះ កាលពីថ្ងៃទី.........ខែ.....
..........ឆ្នាំ................ ត្រង់លេខខ្លួន..................................................។

កណ្តាល, ថ្ងៃទី...........ខែមករា ឆ្នាំ២០២០

ប្រធានពន្ធនាគារ